**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**
**និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

**របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា**

# ដំណើរការទីផ្សារមូលបត្រនៅកម្ពុជា

កម្មសិក្សាពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០

ឈ្មោះស្ថាប័ន៖ **គណៈកម្មការមូលបត្រកម្ពុជា** (**គ.ម.ក.**)

គាត់តែងឡើងដោយ
និស្សិតឈ្មោះ **សុធី មេត្តា**

សាស្ត្រាចារ្យណែនាំ
លោក **ឈាង ហ៊ុយ**

ថ្នាក់បរិញ្ញាបត្រ ធនាគារ និងហិរញ្ញវត្ថុ
ជំនាន់ទី ១៣

ឆ្នាំចូលសិក្សា ២០១៦
ឆ្នាំសរសេររបាយការណ៍ ២០២០

# **អារម្ភកថា**

របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សានេះ គឺជាលទ្ធផលដែលកើតចេញពីការស្រាវជ្រាវ និងចងក្រងយ៉ាងយកចិត្តទុកដាក់បំផុត ដោយផ្អែកទៅតាមចក្ខុវិស័យ និងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរបស់រដ្ឋាភិបាល ដែលបានបង្កើតអោយមានផ្សារមូលបត្រ ដើម្បីដើរតួជាមធ្យោបាយនៅក្នុងការប្រមូលមូលធន។ ម្យ៉ាងវិញទៀត របាយការណ៍ស្រាវជ្រាវមួយនេះបានសិក្សាលើប្រធានបទ "ដំណើរការទីផ្សារមូលបត្រនៅកម្ពុជា" ដែលផ្តោតសំខាន់ទៅលើប្រតិបត្តិការជួញដូរមូលបត្រនៅផ្សារមូលបត្រកម្ពុជា។

របាយការណ៍ស្រាវជ្រាវមួយនេះ នឹងឆ្លើយតបយ៉ាងសកម្មទៅនឹងតម្រូវការបច្ចុប្បន្នរបស់និស្សិត ដែលកំពុងបន្តសិក្សាផ្នែកធនាគារ និងហិរញ្ញវត្ថុ សេដ្ឋកិច្ច សាស្ត្រាចារ្យ និងសាធារណៈជន ជាពិសេសវិនិយោគិន ដែលមានចំណាប់អារម្មណ៍វិនិយោគក្នុងវិស័យមូលបត្រនៅកម្ពុជា។ ចំពោះបញ្ហាផ្សេងៗដែលអ្នកមិត្តនិស្សិត និងសាធារណៈជនទាំងអស់គ្នាចង់ដឹង និងមានចម្ងល់នោះ ខ្ញុំបាទនឹងធ្វើការបកស្រាយជូនតាមលទ្ធភាពដែលពួកខ្ញុំបាទរកបាន ដូចដែលបានចងក្រងនៅក្នុងអត្ថបទសិក្សាស្រាវជ្រាវមួយនេះ ។

នាងខ្ញុំសង្ឃឹមថាកិច្ចការស្រាវជ្រាវមួយនេះ នឹងអាចទុកធ្វើជាទៀនអុជបំភ្លឺដល់មិត្តនិស្សិតយើងទាំងឡាយណា ដែលមានបំណងចង់សិក្សាស្វែងយល់អំពីដំណើរការទីផ្សារមូលបត្រកម្ពុជា ដែលមាន តួអង្គពាក់ព័ន្ធ ក្រុមហ៊ុនចុះបញ្ជី ដំណើរការជួញដូរ នីតិវិធីលក្ខខណ្ឌតម្រូវ ក៏ដូចជាវិធានប្រតិបត្តការជួញដូរនៅក្នុងទីផ្សារ និងទិន្នន័យជួញដូរមូលបត្ររបស់ក្រុមហ៊ុនចុះបញ្ជីទាំង៥តាមត្រីមាសនីមួយៗនៅឆ្នាំ២០១៩ ផងដែរ។ នាងខ្ញុំក៏សូមអភ័យទោសទុកជាមុនផងដែរ នូវរាល់កំហុសឆ្គងដែលកើតមានឡើងដោយអចេតនា ព្រោះបើទោះបីជានាងខ្ញុំបានពិនិត្យយ៉ាងល្អិតល្អន់ម្តងជាពីរដងរួចហើយយ៉ាងណាក៏ដោយ ក៏វាច្បាស់ជានៅមានកំហុសបន្តិចបន្តួចឲ្យខានតែបាន។ នាងខ្ញុំរីករាយទទួលយកនូវរាល់មតិរិះគន់ដើម្បីស្ថាបនាពីសំណាក់មិត្តភក្តិទាំងអស់គ្នា ជាពិសេសមតិយោបល់ណែនាំបន្ថែមទៀតពីសំណាក់**លោកសាស្ត្រាចារ្យ ឈាង ហ៊ុយ** ដើម្បីធ្វើឱ្យរបាយការណ៍នេះកាន់តែមានភាពល្អប្រសើរឡើងជាងមុនជាកម្រិត។

ជាចុងក្រោយ ខ្ញុំបាទសូមថ្លែងអំណរគុណដល់មិត្តនិស្សិតអ្នកអាន និង សូមអោយមិត្តនិស្សិតទទួលបានជោគជ័យក្នុងការសិក្សា មានសុខភាពល្អ ដើម្បីបន្តជាសរសរទ្រូងនៃប្រទេសជាតិយើង និងប្រើប្រាស់របាយការណ៍ស្រាវជ្រាវមួយនេះឱ្យមានប្រសិទ្ធិភាពខ្ពស់ ដើម្បីអភិវឌ្ឍទីផ្សារមូលធននៅប្រទេសកម្ពុជា។

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំជានិស្សិតឈ្មោះ សុធី មេត្តា ដែលកំពុងសិក្សាថ្នាក់បរិញ្ញាបត្រធនាគារ និង ហិរញ្ញវត្ថុ ឆ្នាំទី៤ ក្រុម B4A2 ឆ្នាំសិក្សា ២០១៩-២០២០ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យា-សាស្ត្រសេដ្ឋកិច្ច បានធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទ ដំណើរការទីផ្សារមូលបត្រនៅកម្ពុជា ដើម្បីធ្វើជារបាយការណ៍សម្រាប់បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាត្រ។

ជាកិច្ចចាប់ផ្តើមដំបូង នាងខ្ញុំសូមថ្លែងនូវសេចក្តីគោរព ដឹងគុណ កត្តញ្ញូកតវេទី ដ៏ជ្រាល ជ្រៅបំផុតចំពោះ **លោកអ្នកមានគុណទាំងទ្វេ** គឺលោកឪពុក ស សុធី និង អ្នកម្តាយ គា លីដា ដែល បានផ្តល់នូវកំណើត ព្រមទាំងបានចិញ្ចឹម បីបាច់ថែរក្សា អប់រំទូន្មានប្រៀនប្រដៅ និង ជួយទំនុក បម្រុងឧបត្ថម្ភគាំពារសព្វគ្រប់បែបយ៉ាងដល់រូបនាងខ្ញុំទាំងផ្នែកស្មារតី និងហិរញ្ញវត្ថុតាំងពីកុមារ ភាពរហូតដល់ពេលនេះ ដោយជំនះនូវរាល់ឧបសគ្គដែលបានកើតមាន ដោយមិនគិតពីការនឿយ ហត់នោះឡើយ ។

ទន្ទឹមនឹងនេះដែរ យើងខ្ញុំទាំងពីរសូមថ្លែងអំណរគុណជាពិសេស ចំពោះជំនួយឧបត្ថម្ភជា ផ្នែកស្មារតីរបស់៖

- ឯកឧត្តមសាកលវិទ្យាធិការ លោកសាកលវិទ្យាការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង គ្រប់មហា វិទ្យាល័យ លោកលោកស្រីប្រធាន អនុប្រធាន គ្រប់ដេប៉ាតឺម៉ង់ លោក លោកស្រីប្រធាន អនុប្រធានការិយាល័យ លោកគ្រូ សាស្ត្រាចារ្យ និង បុគ្គលិកទាំងអស់នៃសាកលវិទ្យាល័ យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានផ្តល់ជាដំបូន្មានល្អៗ និងបង្ហាត់ បង្រៀនយើងខ្ញុំ ដោយយកចិត្តទុកដាក់អស់ពីកម្លាំងកាយចិត្ត ។
- លោកសាស្ត្រាចារ្យ **ឈាង ហ៊ុយ** ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការបង្ហាត់ បង្ហាញ ផ្តល់នូវដំបូន្មាន និងវិធីសាស្ត្រល្អៗ ក្នុងការសរសេររបាយការណ៍ស្រាវជ្រាវមួយ នេះឲ្យមានភាពល្អប្រសើរ និងមានខ្លឹមសារ ។
- មិត្តរួមថ្នាក់ $B_4A_2$ ដែលបានផ្តល់ជាគំនិត យោបល់ ព្រមទាំងការលើកទឹកចិត្តដល់យើងខ្ញុំ។

ជាទីបញ្ចប់ យើងខ្ញុំសូមគោរពជូនពរដល់ លោកអ្នកមានគុណទាំងពីរ ឯកឧត្តមសាកល វិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោកលោកស្រីសាស្ត្រាចារ្យព្រម ទាំងបុគ្គលិករបស់គណ:កម្មការមូលបត្រកម្ពុជាទាំងអស់ សូមអោយមានសុខភាពល្អ ជួប ប្រទះតែពុទ្ធពរទាំងបួនប្រការ និងទទួលបានជោគជ័យគ្រប់ភារកិច្ចការងារទាំងអស់។

# មាតិកា

ទំព័រ


បញ្ជីអក្សរកាត់ ..... v

បញ្ជីតារាង ..... vi

បញ្ជីរូបភាព ..... vii

បញ្ជីក្រាភិច ..... viii


## សេចក្តីផ្តើម


១. លំនាំបញ្ហានៃការស្រាវជ្រាវ ..... ១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ ..... ២

៣. គោលបំណងនៃការស្រាវជ្រាវ ..... ២

៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ..... ៣

៥. វិធីសាស្ត្រនៃការស្រាវជ្រាវ ..... ៣

៦. សារៈសំខាន់នៃការស្រាវជ្រាវ ..... ៤

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ..... ៥


## ជំពូកទី១

## ការរំលឹកទ្រឹស្តីក្នុងវិស័យមូលបត្រ


១.១. ប្រវត្តិទីផ្សារមូលបត្រ ..... ៦

១.២. និយមន័យ ..... ៧

១.២.១. មូលបត្រ ..... ៧

១.២.២ ទីផ្សារមូលបត្រ ..... ៧

១.៣. តួនាទីទីផ្សារមូលបត្រក្នុងសេដ្ឋកិច្ច ..... ៧

១.៤. សារៈសំខាន់នៃទីផ្សារមូលបត្រ ..... ៨

១.៤.១. អត្ថប្រយោជន៍ទីផ្សារមូលបត្រចំពោះវិនិយោគិន ..... ៨

១.៤.២. អត្ថប្រយោជន៍នៃទីផ្សារមូលបត្រចំពោះក្រុមហ៊ុនបោះផ្សាយ ..... ៩

១.៤.៣. អត្ថប្រយោជន៍នៃទីផ្សារមូលបត្រចំពោះសេដ្ឋកិច្ចជាតិ ..... ១១

១.៥. ប្រភេទផ្សេងៗនៃមូលបត្រ ..... ១២

១.៥.១. មូលបត្របំណុល ..... ១២

១.៥.២. មូលបត្រកម្មសិទ្ធ.......................................................................................១៣
១.៥.៣. ឧបករណ៍និស្សន្ទ.......................................................................................១៤
១.៦. ប្រភេទនៃទីផ្សារមូលបត្រ.......................................................................................១៤
១.៦.១. ទីផ្សារដំបូង.......................................................................................១៤
១.៦.២. ទីផ្សារបន្ទាប់.......................................................................................១៥
១.៧. តួអង្គសំខាន់ៗក្នុងទីផ្សារមូលបត្រ.......................................................................................១៥

## ជំពូកទី២

## ស្ថានភាពទូទៅនៃគណៈកម្មការមូលបត្រកម្ពុជា

២.១. ប្រវត្តិសង្ខេបរបស់គណៈកម្មការមូលបត្រកម្ពុជា.......................................................................................១៧
២.២. ចក្ខុវិស័យ និងបេសកកម្ម.......................................................................................១៧
២.២.១. ចក្ខុវិស័យ.......................................................................................១៧
២.២.២. បេសកកម្ម.......................................................................................១៧
២.៣. ទីតាំងរបស់គណៈកម្មការមូលបត្រកម្ពុជា.......................................................................................១៨
២.៤. រូបសញ្ញា និងអត្ថន័យនៃរូបសញ្ញា.......................................................................................១៨
២.៤.១. រូបសញ្ញា.......................................................................................១៨
២.៤.២. អត្ថន័យនៃរូបសញ្ញា.......................................................................................១៩
២.៤.៣. ត្រារបស់គណៈកម្មការមូលបត្រកម្ពុជា.......................................................................................២០
២.៥. មុខងាររបស់គណៈកម្មការមូលបត្រកម្ពុជា.......................................................................................២១
២.៦. សមាសភាពរបស់គណៈកម្មការមូលបត្រកម្ពុជា.......................................................................................២២
២.៧. រចនាសម្ព័ន្ធអង្គការចាត់តាំងរបស់គណៈកម្មការមូលបត្រកម្ពុជា.......................................................................................២៣

## ជំពូកទី៣

## ស្ថានភាពទូទៅនៃក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

៣.១. ប្រវត្តិនៃការបង្កើតទីផ្សារមូលបត្រកម្ពុជា.......................................................................................២៤
៣.២. ចក្ខុវិស័យ និងបេសកកម្ម.......................................................................................២៥
៣.២.១. ចក្ខុវិស័យ.......................................................................................២៥
៣.២.២. បេសកកម្ម.......................................................................................២៥
៣.៣. នាមករណ៍ និងផ្លាកសញ្ញារបស់ផ្សារមូលបត្រកម្ពុជា.......................................................................................២៦

៣.៤. ពត៌មានទំនាក់ទំនងរបស់ក្រុមហ៊ុនមូលបត្រកម្ពុជា ........................................................ ២៧
៣.៥. រចនាសម្ព័ន្ធនៃការគ្រប់គ្រង ........................................................ ២៧
៣.៦. ក្រុមប្រឹក្សាភិបាល ........................................................ ២៧

## ជំពូកទី៤
## ដំណើរការទីផ្សារមូលបត្រកម្ពុជា

៤.១. ក្របខ័ណ្ឌនិងបទប្បញ្ញត្តិពាក់ព័ន្ធនឹងមូលបត្រនៅកម្ពុជា ........................................................ ២៩
៤.២. តួអង្គសំខាន់ៗក្នុងទីផ្សារមូលបត្រកម្ពុជា ........................................................ ៣០
៤.២.១. គណៈកម្មការមូលបត្រកម្ពុជា ........................................................ ៣០
៤.២.២. ប្រតិបត្តិករមូលបត្រ ........................................................ ៣០
៤.២.២.១. ប្រតិបត្តិករទីផ្សារមូលបត្រ ........................................................ ៣១
៤.២.២.២. ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ ........................................................ ៣១
៤.២.២.៣. ប្រតិបត្តិកររក្សាទុកមូលបត្រ ........................................................ ៣១
៤.២.៣. អន្តរការីមូលបត្រ ........................................................ ៣១
៤.២.៣.១. ក្រុមហ៊ុនធានាទិញមូលបត្រ ........................................................ ៣១
៤.២.៣.២. ក្រុមហ៊ុនពាណិជ្ជករមូលបត្រ ........................................................ ៣៤
៤.២.៣.៣. ក្រុមហ៊ុនជើងសារមូលបត្រ ........................................................ ៣៤
៤.២.៣.៤. ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុ ........................................................ ៣៦
៤.២.៤. ភ្នាក់ងារក្រុមហ៊ុនមូលបត្រ ........................................................ ៣៦
៤.២.៤.១. ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ........................................................ ៣៦
៤.២.៤.២. ភ្នាក់ងារបញ្ជិកាមូលបត្រ ចុះបញ្ជីផ្ទេរមូលបត្រ និងទូទាត់មូលបត្រ ................ ៣៧
៤.២.៥. ក្រុមហ៊ុនបោះផ្សាយ ........................................................ ៣៨
៤.២.៥.១. ក្រុមហ៊ុនបោះផ្សាយមូលបត្រកម្មសិទ្ធិក្នុងទីផ្សារមូលបត្រកម្ពុជា ........................ ៣៩
៤.២.៥.២. ក្រុមហ៊ុនបោះផ្សាយមូលបត្របំណុលក្នុងទីផ្សារមូលបត្រកម្ពុជា ........................ ៤៤
៤.២.៦. វិនិយោគិន ........................................................ ៤៨
៤.៣. ការត្រៀមខ្លួនរបស់វិនិយោគិន ........................................................ ៤៨
៤.៤. ដំណើរការជួញដូរមូលបត្រនៅទីផ្សារមូលបត្រ ........................................................ ៥១
៤.៤.១. ដំណើរការជួញដូរនៅទីផ្សារដំបូង ........................................................ ៥១

៤.៤.១.១. ការធ្វើ ប៊ុក បៀលឌីង ............................................................................................ ៥១
៤.៤.១.២. ការធ្វើបរិវិសកម្ម ............................................................................................ ៥២
៤.៤.២. ប្រតិបត្តិការជួញដូរនៅទីផ្សារបន្ទាប់ .................................................................... ៥៣
៤.៤.២.១. ម៉ោងជួញដូរ ............................................................................................ ៥៣
៤.៤.២.២. ប្រភេទបញ្ជា ............................................................................................ ៥៤
៤.៤.២.៣. ការដាក់បញ្ជា ............................................................................................ ៥៥
៤.៤.២.៤. ព័ត៌មានលម្អិតនៃបញ្ជា .................................................................................. ៥៥
៤.៤.២.៥. ឯកតាគម្លាតតម្លៃ ............................................................................................ ៥៦
៤.៤.២.៦. ថ្លៃមូលដ្ឋាន ............................................................................................ ៥៦
៤.៤.២.៧. ថ្លៃពិសេស ............................................................................................ ៥៦
៤.៤.២.៨. វិធីសាស្ត្រជួញដូរមូលបត្រកម្មសិទ្ធិ និងមូលបត្របំណុល ................................ ៥៧
៤.៤.២.៩. យន្តការផាត់ទាត់ ............................................................................................ ៥៩
៤.៤.៣. ទិដ្ឋភាពទូទៅនៃការជួញដូរមូលបត្រនៅទីផ្សារមូលបត្រកម្ពុជា ................................ ៦៤
៤.៤.៣.១. ការជួញដូរមូលបត្រកម្មសិទ្ធិសម្រាប់ឆ្នាំ២០១៩ .................................................. ៦៤
៤.៤.៣.២. សកម្មភាពជួញដូរភាគហ៊ុនរបស់ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ ......... ៦៩
៤.៤.៣.៣.សកម្មភាពជួញដូរសញ្ញាបណ្ណរបស់ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្របំណុល .... ៧៩
៤.៤.៣.៤. ចំនួនវិនិយោគិន ............................................................................................ ៨០
៤.៥. ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយនៃការជួញដូរមូលបត្រនៅកម្ពុជា ................ ៨១
៤.៥.១ ចំណុចខ្លាំង ............................................................................................ ៨១
៤.៥.២. ចំណុចខ្សោយ ............................................................................................ ៨២

## សេចក្ដីសន្និដ្ឋាន និងការផ្ដល់អនុសាសន៍

១. សេចក្ដីសន្និដ្ឋាន ............................................................................................ ៨៣
២. ការផ្ដល់អនុសាសន៍ ............................................................................................ ៨៤

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

គ.ម.ក. : គណៈកម្មការមូលបត្រកម្ពុជា

ផ.ម.ក. : ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

CCP : Central Counter Party

CSA : Cash Settlement Agent (ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ)

CSD : Central Securities Depository

CSO : Clearing and Settlement Operator (ប្រតិបត្តិករប្រព័ន្ធជាត់ទាត់មូលបត្រ)

CSX : Cambodia Securities Exchange (ផ្សារមូលបត្រកម្ពុជា)

IPO : Initial Public Offering (ការបោះផ្សាយលក់មូលបត្រលើដំបូង)

SECC : Securities and Exchange Comission of Cambodia (គណៈកម្មការមូលបត្រកម្ពុជា)

SF : Securities Firm (ក្រុមហ៊ុនមូលបត្រ)

# បញ្ជីតារាង

តារាង 1.- តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង PWSA......................................................................................................................៣៩
តារាង 2.- តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណលើកដំបូង GTI......................................................................................................................៤០
តារាង 3.- តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង PPAP......................................................................................................................៤១
តារាង 4.- តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង PPSP...................................................................................................................... ៤២
តារាង 5.- តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង PAS ......................................................................................................................៤៣
តារាង 6.- តារាងព័ត៌មានសង្ខេបរបស់ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្របំណុល HKL ................៤៥
តារាង 7.- តារាងព័ត៌មានសង្ខេបរបស់ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្របំណុល LOLC..............៤៦
តារាង 8.- តារាងព័ត៌មានសង្ខេបរបស់ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្របំណុល ABA ...............៤៧
តារាង 9.- តារាងឯកតាគម្លាតថ្លៃ.......................................................................................៥៦
តារាង 10.- ទិដ្ឋភាពទូទៅនៃការជួញដូរមូលបត្រ.................................................................៦៥
តារាង 11.- ទិដ្ឋភាពទូទៅនៃការជួញដូរភាគហ៊ុន PWSA......................................................៦៩
តារាង 12.- ទិដ្ឋភាពទូទៅនៃការជួញដូរភាគហ៊ុន GTI .........................................................៧១
តារាង 13.- ទិដ្ឋភាពទូទៅនៃការជួញដូរភាគហ៊ុន PPAP...................................................... ៧៣
តារាង 14.- ទិដ្ឋភាពទូទៅនៃការជួញដូរភាគហ៊ុន PPSP.......................................................៧៥
តារាង 15.- ទិដ្ឋភាពទូទៅនៃការជួញដូរភាគហ៊ុន PAS ........................................................ ៧៧
តារាង 16.- ស្ថិតិបង្ហាញពីចំនួនវិនិយោគិននៅក្នុងឆ្នាំ២០១៨-២០១៩ ......................................៨០

## បញ្ជីរូបភាព


រូបភាព 1.- ទីតាំងរបស់គណៈកម្មការមូលបត្រកម្ពុជា ....................១៨
រូបភាព 2.- រូបសញ្ញាគណៈកម្មការមូលបត្រកម្ពុជា ....................១៩
រូបភាព 3.- ត្រារបស់គណៈកម្មការមូលបត្រកម្ពុជា .................... ២០
រូបភាព 4.- រចនាសម្ព័ន្ធចាត់តាំងរបស់គណៈកម្មការមូលបត្រកម្ពុជា....................២៣
រូបភាព 5.- ស្លាកសញ្ញាក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា .................... ២៦
រូបភាព 6.- រចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា....................២៧
រូបភាព 7.- ស្លាកសញ្ញា PWSA....................៣៩
រូបភាព 8.- ស្លាកសញ្ញា GTI ....................៤០
រូបភាព 9.- ស្លាកសញ្ញា PPAP....................៤១
រូបភាព 10.- ស្លាកសញ្ញា PPSP.................... ៤២
រូបភាព 11.- ស្លាកសញ្ញា PAS ....................៤៣
រូបភាព 12.- ដំណើរការជួញដូរមូលបត្រ ....................៥៣
រូបភាព 13.- ដំណើរការនៃប្រព័ន្ធផាត់ទាត់ និងទូទាត់....................៦១
រូបភាព 14.- ការទូទាត់សាច់ប្រាក់នៅក្នុងធនាគារតែមួយ .................... ៦២
រូបភាព 15.- ការទូទាត់សាច់ប្រាក់អន្តរធនាគារ .................... ៦២
រូបភាព 16.- ដំណើរការនៃប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ ....................៦៣

# បញ្ជីក្រាភិច

ក្រាហ្វិច 1.- ទំហំជួញដូររបស់ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ (គិតជាភាគរយ)........................៦៥
ក្រាហ្វិច 2.- សន្ទស្សន៍ ផ.ម.ក. និងទំហំជួញដូរសរុប..............................................................៦៦
ក្រាហ្វិច 3.- ចំនួនបញ្ជាទិញ-លក់ភាគហ៊ុនចុះបញ្ជីទាំង៥ ......................................................៦៧
ក្រាហ្វិច 4.- ចំនួនវិនិយោគិនបែងចែកតាមសញ្ជាតិខ្មែរ និងបរទេស .......................................៦៨
ក្រាហ្វិច 5.- ចំនួនវិនិយោគិនបែងចែកតាមប្រភេទរូបវន្តបុគ្គល និងនីតិបុគ្គល ..........................៦៨
ក្រាហ្វិច 6.- ថ្លៃភាគហ៊ុនធៀបនឹងទំហំជួញដូររបស់ភាគហ៊ុន PWSA.......................................៦៩
ក្រាហ្វិច 7.- បរិមាណបញ្ជាទិញ-លក់មូលបត្រ PWSA..........................................................៧០
ក្រាហ្វិច 8.- ថ្លៃភាគហ៊ុនធៀបនឹងទំហំជួញដូររបស់ភាគហ៊ុន GT...........................................៧១
ក្រាហ្វិច 9.- បរិមាណបញ្ជាទិញ-លក់មូលបត្រ GTI...............................................................៧២
ក្រាហ្វិច 10.- ថ្លៃភាគហ៊ុនធៀបនឹងទំហំជួញដូររបស់ភាគហ៊ុន PPAP ................................... ៧៣
ក្រាហ្វិច 11.- បរិមាណបញ្ជាទិញ-លក់មូលបត្រ PPAP .........................................................៧៤
ក្រាហ្វិច 12.- ថ្លៃភាគហ៊ុនធៀបនឹងទំហំជួញដូររបស់ភាគហ៊ុន PPSP ....................................៧៦
ក្រាហ្វិច 13.- បរិមាណបញ្ជាទិញ-លក់មូលបត្រ PPSP .........................................................៧៦
ក្រាហ្វិច 14.- ថ្លៃភាគហ៊ុនធៀបនឹងទំហំជួញដូររបស់ភាគហ៊ុន PAS.......................................៧៨
ក្រាហ្វិច 15.- បរិមាណបញ្ជាទិញ-លក់មូលបត្រ PAS............................................................៧៨

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជាត្រូវបានគេចាត់ទុកថាជាប្រទេសកំពុងអភិវឌ្ឍន៍ ដែលក្នុងនោះរាជរដ្ឋាភិបាលបាន នឹងកំពុងតែអនុវត្តន៍នូវគោលនយោបាយ និងយុទ្ធសាស្ត្រជាច្រើនដើម្បីឲ្យកំណើនសេដ្ឋកិច្ចជាតិបោះជំហានឈានទៅមុខជាលំដាប់។ ទន្ទឹមនឹងនេះដែរ ប្រព័ន្ធហិរញ្ញវត្ថុបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការអភិវឌ្ឍ និងដើម្បីធានានូវកំណើនសេដ្ឋកិច្ចនៃកម្ពុជា តាមរយៈការគៀងគរមូលធន ពីអ្នកដែលមានមូលធននៅទំនេរ និងទៅធ្វើការបែងចែកមូលធននោះឲ្យទៅដល់អ្នកដែលមានតម្រូវការមូលធនយ៉ាងមានប្រសិទ្ធភាព។ តាមរយៈការរីកលូតលាស់នៃប្រព័ន្ធហិរញ្ញវត្ថុនៅកម្ពុជានេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ឲ្យមានដំណើរការទីផ្សារមូលបត្រកម្ពុជា ដែលវត្តមាននៃទីផ្សារមូលបត្រនេះ គឺជាជម្រើសថ្មីមួយបន្ថែមទៀត សម្រាប់ការវិនិយោគលើវិស័យហិរញ្ញវត្ថុ ក្រៅពីការវិនិយោគជាមួយធនាគារ និងអចលនទ្រព្យ។ សម្រាប់ប្រទេសកម្ពុជាអាចចាត់ទុកជាទីផ្សារមួយដ៏វ័យក្មេងក្នុងវិស័យនេះ ដែលជាហេតុធ្វើឱ្យវិនិយោគិន និងសាធារណៈជនជាច្រើនមិនទាន់ស្គាល់ ហើយមិនទាន់យល់ដឹងអំពីនីតិវិធីជួញដូរ និងមិនបានអំពីអត្ថប្រយោជន៍ ក៏ដូចជាហានិភ័យនៅក្នុងវិស័យនេះផងដែរ។

ជាមួយគ្នានេះដែរ ដើម្បីផ្តល់ភាពរលូននៃដំណើរការរបស់ទីផ្សារមូលបត្រកម្ពុជា គណៈកម្មការមូលបត្រកម្ពុជា (**គ.ម.ក.**) ត្រូវបានបង្កើតឡើង និងដើរតួយ៉ាងសំខាន់ក្នុងការតាក់តែងច្បាប់ស្តីពីការប្រព្រឹត្តទៅនូវទីផ្សារមូលបត្រ លក្ខខណ្ឌក្នុងការចូលរួម នីតិវិធីក្នុងការជួញដូរមូលបត្រ ការធ្វើការផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹង ព័ត៌មានដល់សាធារណជនតាមរយៈ សិក្ខាសាលា វគ្គបណ្តុះ បណ្តាល ក៏ដូចជាបណ្តាញសង្គម និងលើគេហទំព័ររបស់ខ្លួនផងដែរ។ ក្រោយមកទៀត ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (**ផ.ម.ក.**) ក៏ត្រូវបានបង្កើតឡើងដែរដើម្បីធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុមូលបត្រ។ តាមរយៈការធ្វើសន្និសិទ្ទ សិក្ខាសាលា បណ្តុះបណ្តាល ព្រឹត្តិការណ៍នានា កម្មវិធីប្រកួតប្រជែងទាក់ទងនឹងមូលបត្រ យើងឃើញថា វិស័យថ្មីមួយនេះទទួលបានការចាប់អារម្មណ៍ច្រើនពីសាធារណជន និងក្រុមហ៊ុនឯកជនជាច្រើន។ ម្យ៉ាងទៀតការទាក់ទាញនេះ បានធ្វើឱ្យមហាជនចង់ដឹងចង់លឺអំពីដំណើរការ និងនីតិវិធីក្នុងការជួញដូរមូលបត្រ ជាពិសេសទិន្នន័យទីផ្សារដែលកំពុងជួញដូរនាពេលបច្ចុប្បន្ននៅក្នុងទីផ្សារមូលបត្រកម្ពុជា។

ដោយហេតុនេះហើយ បានជារូបនាងខ្ញុំសម្រេចចិត្តជ្រើសរើសយកប្រធានបទ "**ដំណើរការទីផ្សារមូលបត្រនៅកម្ពុជា**" មកធ្វើការសិក្សាស្រាវជ្រាវ និងបកស្រាយ ដើម្បីឱ្យសាធារណៈជនបានយល់ដឹងកាន់តែច្បាស់បន្ថែមទៀតអំពីដំណើរការទូទៅនៅក្នុងទីផ្សារមូលបត្រ សារៈប្រយោ- ជន៍នៃទីផ្សារ លក្ខខណ្ឌតម្រូវសម្រាប់វិនិយោគិន និងជាពិសេសចំពោះវិធានប្រតិបត្តិការទីផ្សាររបស់ផ្សារមូលបត្រកម្ពុជា។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ទីផ្សារមូលបត្រកម្ពុជា ជាទីផ្សារដែលពុំធ្លាប់មានពីមុនមកនៅកម្ពុជា ហើយទើបតែបានដំណើរការក្នុងរយៈពេលជិតមួយទសវត្សន៍តែប៉ុណ្ណោះ ម្យ៉ាងវិញទៀតធនធានមនុស្សក្នុងវិស័យនេះនៅមានកម្រិត ស្ថាប័នពាក់ព័ន្ធនៅមានកង្វះខាតខាងបច្ចេកវិទ្យាក្នុងការគ្រប់គ្រងឱ្យកាន់តែមានប្រសិទ្ធភាព ព្រោះវិស័យ មូលបត្រទើបតែបង្កើតឡើងឱ្យដំណើរការ ដូចនេះហើយវិស័យនេះនៅមានភាពវ័យក្មេង ហើយការលូតលាស់មិនទាន់ទូលំទូលាយនៅឡើយទេ។ បន្ថែមលើសពីនេះទៅទៀតនោះ ទីផ្សារមូលបត្រមានវិធានស្មុគស្មាញជាច្រើន ដែលទាមទារឲ្យមានចំណេះដឹងជំនាញ និងបទពិសោធន៍ខ្ពស់នៅក្នុងការវិនិយោគ ដើម្បីជៀសវាងហានិភ័យនានាដែលអាចកើតមានឡើង។ មួយវិញទៀត ប្រជាពលរដ្ឋកម្ពុជា និងវិនិយោគិនភាគច្រើនពុំទាន់យល់ឱ្យបានស៊ីជម្រៅនៅឡើយ ថាតើទីផ្សារមូលបត្រនេះ មានដំណើរការ ឬប្រព្រឹត្តទៅយ៉ាងនោះ។ ដោយមើលឃើញនូវចំណុចខ្វះខាតទាំងនេះ ហើយទើបនាងខ្ញុំសម្រេចជ្រើសរើសយកប្រធានបទ ដំណើរការទីផ្សារមូលបត្រនៅកម្ពុជានេះមកធ្វើការសិក្សាស្រាវជ្រាវ ដើម្បីបកស្រាយឲ្យច្បាស់បន្ថែមទៀតថា តើអ្វីទៅជាមូលបត្រ? តើលក្ខខណ្ឌតម្រូវអ្វីខ្លះដែលវិនិយោគិនត្រូវបំពេញដើម្បីធ្វើការវិនិយោគបាននៅផ្សារមូលបត្រ? និងតើការទិញ-លក់មូលបត្រនៅលើទីផ្សារមូលបត្រនៅកម្ពុជាប្រព្រឹត្តិទៅយ៉ាងដូចម្តេច?

## ៣. គោលបំណងនៃការស្រាវជ្រាវ

របាយការណ៍កម្មសិក្សាស្រាវជ្រាវអំពីប្រធានបទ "ដំណើរការទីផ្សារមូលបត្រនៅកម្ពុជា" នេះ គឺផ្តោតសំខាន់ទៅលើ ប្រតិបត្តិការជួញដូរមូលបត្រនៅផ្សារមូលបត្រកម្ពុជា ជាពិសេស ព្រមទាំង ក្រុមហ៊ុនចុះបញ្ជី លក្ខខណ្ឌចំពោះវិនិយោគិន និងតួអង្គចូលរួមក្នុងវិស័យមូលបត្រ។ ចំពោះគោលបំណងជាក់លាក់នៃការស្រាវជ្រាវវិញ អាចសង្ខេបបានដូចខាងក្រោម៖

- ស្វែងយល់អំពីទិដ្ឋភាពទូទៅរបស់គណៈកម្មការមូលបត្រ
- ស្វែងយល់អំពីស្ថានភាពទូទៅនៃក្រុមហ៊ុនផ្សារមូលបត្រ

- សិក្សាស្វែងយល់អំពីភាគីពាក់ព័ន្ធក្នុងវិស័យមូលបត្រ
- ស្វែងយល់អំពីប្រតិបត្តិការ នីតិវិធី និងលក្ខខណ្ឌចាំបាច់ក្នុងការជួញដូរមូលបត្រក្នុងទីផ្សារមូលបត្រកម្ពុជា។
- ស្វែងយល់អំពីទិដ្ឋភាពទូទៅនៃការជួញដូរមូលបត្រនៅទីផ្សារមូលបត្រកម្ពុជា

## ៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ជាក់ស្តែងណាស់ វិស័យមូលបត្របានកំពុងតែមានការរីកលូតលាស់គួរឲ្យកត់សម្គាល់ ប៉ុន្តែការវិវត្តនេះពុំមានលក្ខណៈរីកលូតលាស់ខ្លាំងក្លាដូចប្រទេសដទៃនៅឡើយទេ ព្រោះបើគិតត្រឹមដើមឆ្នាំ២០២០ ប្រតិបត្តិការជួញដូរមូលបត្រនៅផ្សារភាគហ៊ុននៅមានអាយុកាលតិចនៅឡើយ ហើយ វិនិយោគិនមិនទាន់មានភាពជឿទុកចិត្ត និងមិនទាន់មានចំណេះដឹងផ្នែកគ្រប់គ្រាន់ក្នុងវិស័យនេះ ហើយក្រុមហ៊ុនចុះបញ្ជីនូវមានកម្រិត ចំនែកឯចំណេះដឹងអំពីការជួញដូរមូលបត្ររឹតតែពុំទាន់ត្រូវបានគេយល់ច្បាស់។ ដូចនេះហើយនៅក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទ "ដំណើរការទីផ្សារមូលបត្រនៅកម្ពុជា" នេះ នាងខ្ញុំនឹងផ្តោតសំខាន់ទៅលើការប្រតិបត្តិការ ឬដំណើរការនៃការជួញដូរមូលបត្រនៅក្នុងទីផ្សារមូលបត្រផ្ទាល់ និងជាមួយទិន្នន័យការជួញដូរមូលបត្រនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជានៅចន្លោះឆ្នាំ ២០១៨ និង ២០១៩ តែប៉ុណ្ណោះ ។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

របាយការណ៍ស្រាវជ្រាវនេះ គឺពឹងផ្អែកលើប្រភពទិន្នន័យ និងការវិភាគដូចខាងក្រោម៖

### ក. ប្រភពទិន្នន័យ

របាយការណ៍ស្រាវជ្រាវនេះពឹងផ្អែកលើប្រភពទិន្នន័យដែលមានស្រាប់ (បន្ទាប់បន្សំ) រួមមាន ៖

- ឯកសារច្បាប់ អនុក្រឹត និងឯកសារពាក់ព័ន្ធដែលទទួលបានពីគណៈកម្មការមូលបត្រកម្ពុជា
- ឯកសារទាក់ទងនឹងប្រធានបទតាមរយៈការណែនាំរបស់សាស្ត្រាចារ្យណែនាំ
- ព័ត៌មានដែលទទួលបានពីគេហទំព័ររបស់ គណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា និងក្រុមហ៊ុនមូលបត្រផ្សេងទៀត
- ទិន្នន័យដែលស្វែងរកតាមប្រព័ន្ធអ៊ីនធើណែត និក្ខេបបទរបាយការណ៍កម្មសិក្សា និងសារណាបញ្ចប់ការសិក្សាដែលពាក់ព័ន្ធទៅនឹងប្រធានបទនេះ

## ខ. ការវិភាគទិន្នន័យ

របាយការណ៍ស្រាវជ្រាវលើប្រធានបទនេះត្រូវបានវិភាគតាមបែបគុណវិស័យ (ពិពណ៌នា)

## ៦. សារៈសំខាន់នៃការស្រាវជ្រាវ

ចំពោះការសិក្សាស្រាវជ្រាវអំពី ប្រធានបទដែលទាក់ទងទៅនឹង "ដំណើរការទីផ្សារមូលបត្រនៅកម្ពុជា" គឺមានសារៈសំខាន់ និងបានផ្តល់ផលប្រយោជន៍យ៉ាងច្រើនដូចជា៖

**សម្រាប់រូបខ្ញុំផ្ទាល់៖**

- ទទួលបានចំណេះដឹងកាន់តែស៊ីជម្រៅទៅលើវិស័យមូលបត្រនៅកម្ពុជា ដោយផ្សារភ្ជាប់ជាមួយនឹងទ្រឹស្តីដែលបានរៀនកន្លងមក។
- ចេះស្វែងរកឯកសារ និងទិន្នន័យផ្សេងៗ ព្រមទាំងរៀនបាននូវការប្រាស្រ័យទាក់ទងជាមួយនឹងបុគ្គលិកដែលធ្វើការនូវ គ.ម.ក. ដើម្បីចោទសួរពួកគាត់អំពីដំណើរទីផ្សារមូលបត្រ
- ចេះវិភាគ រៀបចំចងក្រងឯកសារឱ្យមានសណ្តាប់ធ្នាប់

**ចំពោះសិស្សនិស្សិត និងអ្នកស្រាវជ្រាវ៖**

- រំលឹកឡើងវិញនូវទ្រឹស្តីដែលបានសិក្សាកន្លងមក។
- ជំនួយស្មារតីដល់និស្សិតប្អូនជំនាន់ក្រោយ ដែលមានបំណងស្វែងយល់បន្ថែមអំពីដំណើរការទីផ្សារមូលបត្រនៅកម្ពុជា។
- ស្គាល់ពាក្យបច្ចេកទេសថ្មីៗទាក់ទងនឹងវិស័យមូលបត្រ។
- ជាឯកសារយោងសម្រាប់ការសិក្សាស្រាវជ្រាវបន្តទៀត។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីជាជំនួយដល់អ្នកអានសម្រាប់ស្វែងរកនូវខ្លឹមសារនៃប្រធានបទ និងងាយស្រួលយល់ពីអត្ថន័យ និងគំនិតសំខាន់ក្នុងរបាយការណ៍ស្រាវជ្រាវនេះ ការសិក្សាលើប្រធានបទស្តីពី "ដំណើរការទីផ្សារមូលបត្រនៅកម្ពុជា" នេះត្រូវបានបែងចែកជា៖


សេចក្តីផ្តើម
ជំពូកទី១ៈ ការរំលឹកទ្រឹស្តី ក្នុងវិស័យ មូលបត្រ
ជំពូកទី២ៈ ស្ថានភាពទូទៅ នៃគណៈកម្មការ មូលបត្រកម្ពុជា
ជំពូកទី៣ៈ ស្ថានភាពទូទៅ នៃក្រុមហ៊ុនផ្សារ មូលបត្រកម្ពុជា
ជំពូកទី៤ៈ ដំណើរការទីផ្សារ មូលបត្រកម្ពុជា
សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

# ជំពូកទី១
# រំលឹកត្រីកោណមាត្រ

# ជំពូកទី១
# រំលឹកទ្រឹស្តី

## ១.១. ប្រវត្តិទីផ្សារមូលបត្រ

មានឯកសារជាច្រើនស្តីអំពី ប្រវត្តិនៃការកកើតទីផ្សារមូលបត្រ ដែលជាក់ស្តែងទីផ្សារភាគ-ហ៊ុនមានតាំងពីយូរយារណាស់មកហើយ ប៉ុន្តែមានប្រទេសជាច្រើន នៅតែប្រើប្រាស់ពាក្យ "**ទីផ្សារភាគហ៊ុន**" ។ ទស្សនៈសម័យទំនើប ស្តីពីការបង្កើតទីផ្សារមូលបត្របានចាប់ផ្តើមតាំងពីចុងសតវត្សទី១៦។ ទីផ្សារភាគហ៊ុន បានផ្តើមនៅពេលបណ្តាប្រទេសនៅទ្វីបអាមេរិក (The New World) បានចាប់ផ្តើមធ្វើពាណិជ្ជកម្មជាមួយប្រទេសដទៃទៀតមានដូចជា ហូឡង់ ព័រទុយហ្គាល់ និងអេស្ប៉ាញ។ ខណៈពេលដែលឈ្មួញធំៗនៅអឺរ៉ុបមានបំណងចាប់ផ្តើមអាជីវកម្មទំហំធំ ដែលទាមទារឱ្យមានចំនួនទឹកប្រាក់ច្រើន ពុំមានឈ្មួញណាម្នាក់មានទឹកប្រាក់ច្រើនសន្ធឹកសន្ធាប់សម្រាប់ចាប់ផ្តើមអាជីវកម្មដ៏ធំបានតែម្នាក់ឯងនោះទេ។ ជាលទ្ធផល វិនិយោគិនបានយកប្រាក់សន្សំរបស់ពួកគេទៅដាក់ទុនរួម ហើយបានក្លាយជាដៃគូអាជីវកម្ម និងសហាកម្មសិទ្ធិជាមួយនឹងចំណែកភាគហ៊ុនរបស់ខ្លួន នៅក្នុងអាជីវកម្មមួយដែលមានទម្រង់រួមទុន។ ក្រុមហ៊ុនរួមទុន ដែលមានដើមកំណើតនៅប្រទេសហូឡង់ បានក្លាយជាគំរូអាជីវកម្មមួយសម្រាប់អាជីវកម្មមួយដែលកំពុងជួបការលំបាកផ្នែកហិរញ្ញវត្ថុ។ នៅក្នុងឆ្នាំ ១៦០២ ក្រុមហ៊ុន ឌឺ ឌាចហ៍ អីស ឥណ្ឌា (The Dutch East India Co.) បានបោះផ្សាយក្រដាសតំណាងភាគហ៊ុន មានភាពងាយស្រួលក្នុងការទិញ-លក់ និងធ្វើការជួញដូរ ភាគហ៊ុនរបស់ខ្លួន ជាមួយនឹងម្ចាស់ភាគហ៊ុនផ្សេងៗ និងវិនិយោគិនដទៃទៀត។

គំនិតនេះទទួលបានជោគជ័យ ដោយការលក់ភាគហ៊ុនបានរីករាលដាល ដល់ប្រទេសមហាអំណាចដែនសមុទ្រផ្សេងទៀតដូចជា ប្រទេសព័រទុយហ្គាល់ អេស្ប៉ាញ និងបារាំង។ នៅទីបំផុតការអនុវត្តគំនិតនេះក៏បានរីករាលដាលដល់ចក្រភពអង់គ្លេស។ ឧស្សាហកម្មដទៃទៀត ក្នុងកំឡុងពេលបដិវត្តន៍ឧស្សាហកម្ម បានចាប់ផ្តើមប្រើប្រាស់ការលក់ភាគហ៊ុនជាវិធីមួយ ដើម្បីប្រមូលមូលធនសម្រាប់ធ្វើអាជីវកម្ម។ ការហូរចូលនៃមូលធននេះបានបន្តឲ្យមានការរកឃើញ និងការអភិវឌ្ឍនៃពិភពលោកថ្មី (The New World) និងការរីកលូតលាស់នៃឧស្សាហកម្មសម័យទំនើប។

ការកើនឡើងនូវបរិមាណជួញដូរភាគហ៊ុនបានជំរុញឲ្យមានការបង្កើតនូវ ទីកន្លែងច្បាស់លាស់មួយសម្រាប់ជួញដូរ។ ជាលទ្ធផលពាណិជ្ជករភាគហ៊ុន បានសម្រេចចិត្តទៅជួបគ្នា នៅហាងកាហ្វេមួយនៅទីក្រុងឡុងដ៍។ ក្រោយមក ហាងកាហ្វេនោះក៏ត្រូវបានពាណិជ្ជករភាគហ៊ុនទិញយក

ហើយប្រែឈ្មោះជាទីផ្សារភាគហ៊ុនដែលមានការរៀបចំ និងគ្រប់គ្រងត្រឹមត្រូវនៅក្នុងឆ្នាំ ១៧៧៣។

ទីផ្សារភាគហ៊ុនទីក្រុងឡុងដ៍ (The London Stock Exchange) ជាទីផ្សារភាគហ៊ុនផ្លូវការដំបូងគេ។ គំនិតនៃការរៀបចំបែបនេះ ក៏បានហូរចូលទៅក្នុងប្រទេសអាមេរិក ហើយក៏បានចាប់ផ្តើមនៅទីក្រុង ភីឡាឌែលភីយ៉ា (Philadelphia) ក្នុងឆ្នាំ ១៧៩០ ។[1]

## ១.២. និយមន័យ

### ១.២.១. មូលបត្រ

មូលបត្រ គឺជាឧករណ៍ហិរញ្ញវត្ថុទាំងឡាយណាដែលតំណាងអោយភាពជាម្ចាស់កម្មសិទ្ធិលើក្រុមហ៊ុនសាធារណ: (មូលបត្រកម្មសិទ្ធិ) ឬជាម្ចាស់ឥណទានទៅលើស្ថាប័នរដ្ឋាភិបាល ឬក្រុមហ៊ុនសាជីវកម្ម (មូលបត្របំណុល) ។

### ១.២.២ ទីផ្សារមូលបត្រ

ទីផ្សារមូលបត្រត្រូវបានគេទទួលស្គាល់ថាជា កន្លែងសម្រាប់ធ្វើការជួញដូរលក់មូលបត្រ និងឧបករណ៍ហិរញ្ញវត្ថុដទៃទៀត។ យោងតាមនិយមន័យច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន "ទីផ្សារមូលបត្រ សំដៅដល់ទីផ្សារ ឬទីកន្លែងជួញដូរមូលបត្រ ឬប្រព័ន្ធដែលដែលផ្តល់មធ្យោបាយនៃការធ្វើសំណើលក់ ផ្ទេរ ឬស្នើការទិញ លក់មូលបត្រ ឧបករណ៍ហិរញ្ញវត្ថុដែលតែងតែត្រូវបានជួញដូរលើទីផ្សារនេះ រួមមានមូលបត្រកម្មសិទ្ធិ មូលបត្រកម្មបំណុល ព្រមទាំងឧបករណ៍និស្សន្ទជាដើម" ហើយវាក៏ជាទីផ្សារអន្តការី ផងដែរ។[2]

## ១.៣. តួនាទីទីផ្សារមូលបត្រក្នុងសេដ្ឋកិច្ច

ទីផ្សារមូលបត្រ មានមុខងារសំខាន់ៗជាមូលដ្ឋាន ពីរយ៉ាងគឺ ៖

- **មុខងារបង្កើតដើមទុន៖** ទីផ្សារមូលបត្រ ជាកន្លែងប្រជុំវិនិយោគិនទាំងអស់ដែលមានដើមទុន ដើម្បី វិនិយោគទៅក្នុងក្រុមហ៊ុនបោះផ្សាយមូលបត្រទាំងឡាយណា ដែលស្វែងរកទុនដើម្បីបង្កើន មូលធនរបស់ខ្លួន ។
- **មុខងារសន្ទនីយភាព៖** សំដៅដល់លទ្ធភាពនៅក្នុនឯការលក់ឧបករណ៍វិនិយោគនៅក្នុងទីផ្សារមូលបត្រ ទីផ្សារមូលបត្រផ្តល់សន្ទនីយភាពតាមរយ:ការផ្តល់ជាទីកន្លែង

---

[1] ហ៊ា លីគា និងផ្សេងទៀត. ២០១៧. ប្រវត្តិទីផ្សារភាគហ៊ុន. ព្រឹត្តបត្រមូលបត្រ គណ:កម្មការមូលបត្រកម្ពុជា, លេខ២, មករា ២០១៧ ទំព័រ ១២

[2] www.secc.gov.kh/khmer/m75.php?pn=2 (បានចូលទស្សនាថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២០)

ជួញដូរទាំងនៅទីកន្លែងផ្ទាល់ និងតាមប្រព័ន្ធអេឡិចត្រូនិចដែលក្នុងនោះ អ្នកទិញ និងអ្នកលក់ជួបគ្នាដើម្បីព្រមព្រៀងតម្លៃ និងធ្វើការជួញដូរមូលបត្រ ។

## ១.៤. សារៈសំខាន់នៃទីផ្សារមូលបត្រ

ទីផ្សារមូលបត្រ ជាសរសៃឈាមដ៏សំខាន់សម្រាប់ក្រុមហ៊ុនបោះផ្សាយ និងវិនិយោគិននានា ក៏ដូចជាសេដ្ឋកិច្ចជាតិទាំងមូលផងដែរ។ អាស្រ័យហេតុដូចនេះគ្រប់ប្រទេសទាំងអស់នៅលើពិភពលោកតែងតែផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការបង្កើត និងអភិវឌ្ឍទីផ្សារនេះដើម្បីធានាបាននូវការអភិវឌ្ឍន៍ប្រព័ន្ធហិរញ្ញវត្ថុប្រកបដោយភាពរឹងមាំ និងចីរភាពក្នុងទិសដៅរក្សានូវស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច។ ក្នុងរយៈពេលជាងមួយទសវត្សកន្លងទៅ ប្រទេសកម្ពុជាមានកំណើនសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់។ ទោះបីជាត្រូវជួបប្រឈមនឹងភាពមិនប្រាកដប្រជា និងហានិភ័យជាច្រើនទាំងក្នុងប្រទេស និងក្រៅប្រទេសយ៉ាងណាក៏ដោយ។ ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងស្ថាប័នសកលបានចាត់ទុកកម្ពុជាថា ជាប្រទេសមួយនៅក្នុងចំណោមប្រទេសទាំងប្រាំបី ដែលមានភាពនៃកំណើនសេដ្ឋកិច្ចខ្ពស់បំផុត។ ក្នុងន័យនេះ វិស័យមូលបត្រត្រូវបានអភិវឌ្ឍនិងដើរតួជាមធ្យោបាយនៃការកៀរគរមូលធន ប្រភពហិរញ្ញវត្ថុរយៈពេលវែង ដែលបង្កលក្ខណៈងាយស្រួលដល់ការធ្វើហិរញ្ញប្បទាន (Financing) ជាក់ស្តែង និងការបែងចែកមូលធននៅកម្ពុជាឱ្យកាន់តែសម្បូរបែប សម្រាប់គម្រោងវិនិយោគនានា ដែលជាចលករនៃកំណើនសេដ្ឋកិច្ចជាតិ។ ទីផ្សារមូលបត្រនេះ ហើយវាបានដើរតួនាទីយ៉ាងសំខាន់ដូចជា៖

### ១.៤.១. អត្ថប្រយោជន៍ទីផ្សារមូលបត្រចំពោះវិនិយោគិន

មានមតិមួយចំនួនលើកឡើងថា ការជួញដូរមូលបត្រប្រៀបបានទៅនឹងការលេងល្បែងស៊ីសង។ប៉ុន្តែបើយើងវិភាគឱ្យបានច្បាស់ ការវិនិយោគ និងការលេងល្បែងមានលក្ខណៈខុសគ្នាទាំងស្រុង។ ការលេងល្បែងពឹងលើព្រេងសំណាងដែលគ្មានអ្វីមកបញ្ជាក់ថាឈ្នះនោះទេ។ ដោយឡែកការវិនិយោគនៅលើវិស័យមូលបត្រគឺអាស្រ័យទៅលើការរកស៊ីរបស់ក្រុមហ៊ុន ហើយមុនពេលជ្រើសរើសទិញមូលបត្ររបស់ក្រុមហ៊ុនណាមួយគឺគេបានមើលពីស្ថានភាពហិរញ្ញវត្ថុ ព្រមទាំងសកម្មភាពក្រុមហ៊ុនរួចហើយ។ វិនិយោគិនអាចទទួលបាននូវអត្ថប្រយោជន៍ជាច្រើនពីការជួញដូរមូលបត្រនៅទីផ្សារមូលបត្រដូចជា៖

**ក. ទទួលបានភាគលាភ (ប្រាក់ចំណូលអកម្ម)៖** នៅពេលក្រុមហ៊ុនបោះផ្សាយទទួលបានជោគជ័យក្នុងការវិនិយោគ ម្ចាស់កាន់កាប់មូលបត្រកម្មសិទ្ធិនឹងទទួលបាននូវចំណែកភាគលាភទៅតាមសមាមាត្រនៃសិទ្ធិដែលខ្លួនមាននៅក្នុងក្រុមហ៊ុន និងទទួលបានការប្រាក់ថេរទោះបីក្រុម

ហ៊ុនបោះផ្សាយទទួលបានផលចំណេញ ឬខាតបង់ក៏ដោយចំពោះម្ចាស់ ឬអ្នកកាន់កាប់មូលបត្របំណុល។

**ខ. ប្រាក់ចំណេញពីការទិញ-លក់មូលបត្រ (ចំណេញមូលធន)**៖ វិនិយោគិននឹងទទួលបានផលចំណេញផ្នែកមូលធននៅពេលដែលតម្លៃមូលបត្ររបស់ខ្លួនឡើងថ្លៃក្នុងទីផ្សារមូលបត្រ។ ម្យ៉ាងវិញទៀតនោះ ការវិនិយោគជាមួយភាគហ៊ុនច្រើនក្រុមហ៊ុនផ្សេងៗពីគ្នានឹងជួយបង្កើនទ្រព្យសម្បត្តិរបស់វិនិយោគិន តាមរយៈឥទ្ធិពលកំណើនពីវិស័យផ្សេងៗក្នុងសេដ្ឋកិច្ច បើទោះបីជាថ្លៃភាគហ៊ុនខ្លះដែលវិនិយោគិនបានធ្លាក់ថ្លៃក៏ដោយ។

**គ. ការធ្វើពិពិធកម្មការវិនិយោគ (Diversification)**៖ វិនិយោគិនតែងមានការប្រើប្រាស់សាច់ប្រាក់សន្សំច្បាស់លាស់ ដោយតែងតែលៃបំរុងទុកពី ១៥% ទៅ២០% ដើម្បីវិនិយោគលើមូលបត្រធៀបនឹងការវិនិយោគសរុប។ សម្រាប់វិនិយោគិនដែលដាក់ប្រាក់វិនិយោគច្រើនប្រភេទផ្សេងៗគ្នា ការវិនិយោគក្នុងទីផ្សារមូលបត្រផ្តល់នូវអត្ថប្រយោជន៍សំខាន់មួយគឺពិពិធកម្ម។ ការវិនិយោគក្នុងទីផ្សារមូលបត្រថ្លៃប្រែប្រួលដោយមិនជាប់ទាក់ទងជាមួយការវិនិយោគផ្សេងៗទៀតដូចជា អចលនទ្រព្យនោះទេ។ ការវិនិយោគក្នុងទីផ្សារមូលបត្រអាចជួយកាត់បន្ថយការខាតបង់បានខ្លះក្នុងករណីវិនិយោគិនមានការខាតបង់ជាមួយការវិនិយោគផ្សេងទៀត។

**ឃ. ភាពជាម្ចាស់កម្មសិទ្ធិ**៖ ការទិញភាគហ៊ុនគឺមានន័យថា លោកអ្នកទទួលយកចំណែកនៃភាព ជាម្ចាស់កម្មសិទ្ធិពីក្រុមហ៊ុនដែលបានលក់ភាគហ៊ុន ហើយលោកអ្នកក៏មានសិទ្ធិទទួលបាននូវចំណែកនៃប្រាក់ចំណេញដែលក្រុមហ៊ុនទទួលបានផងដែរ។ ភាគហ៊ុនិកមានសិទ្ធិបោះឆ្នោត និងមាន សិទ្ធិចូលរួមប្រជុំសម្រេចចិត្តក្នុងអាជីកម្មរបស់ក្រុមហ៊ុនតាមសមាមាត្រនៃភាគហ៊ុនដែលខ្លួនកាន់កាប់។

### ១.៤.២. អត្ថប្រយោជន៍នៃទីផ្សារមូលបត្រចំពោះក្រុមហ៊ុនបោះផ្សាយ

**ក. ទទួលបានប្រភពហិរញ្ញប្បទានរយៈពេលវែង**៖ ការចុះបញ្ជីលក់មូលបត្រជាសាធារណៈផ្តល់លទ្ធភាពឱ្យក្រុមហ៊ុនបោះផ្សាយលក់មូលបត្រទទួលបាននូវប្រភពហិរញ្ញប្បទានថ្មីមួយ ដែលអនុញ្ញាតឱ្យក្រុមហ៊ុននេះ អាចប្រមូលបានមូលធនពីអ្នកវិនិយោគសាធារណៈសម្រាប់ពង្រីកការវិនិយោគ។ បន្ថែមពីនេះទៀត នៅពេលដែលក្រុមហ៊ុនបានបោះផ្សាយលក់មូលបត្រ និងចុះបញ្ជីលក់មូលបត្រ ក្រុមហ៊ុននឹងទទួលបាននូវកេរ្តិ៍ឈ្មោះល្អ និងការគាំទ្រពីច្បាប់ ដែលក្រុមហ៊ុនអាចពង្រឹងអំណាចក្នុងការចរចារជាមួយធនាគារពីលទ្ធភាពក្នុងការទទួលបានឥណទាន រួមចំណែកក្នុងការអនុវត្តផែនការអាជីវកម្មរយៈពេលវែងរបស់ក្រុមហ៊ុនផងដែរ។

**ខ. ទទួលបានការលើទឹកចិត្តពន្ធ៖** ក្រុមហ៊ុនទាំងអស់ដែលទទួលបាននូវការអនុញ្ញាតពី **គ.ម.ក.** បោះផ្សាយលក់មូលបត្រជាសាធារណៈ និងចុះបញ្ជីលក់នៅ **ផ.ម.ក.** នឹងត្រូវបានលើកទឹកចិត្តផ្នែកពន្ធដារ។ ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ទទួលបាននូវការលើកទឹកចិត្តផ្នែកពន្ធដារដោយបន្ថយពន្ធលើប្រាក់ចំណេញចំនួន ៥០ (ហាសិប) ភាគរយ ក្នុងរយៈពេលបីឆ្នាំដំបូង ហើយការលើកទឹកចិត្តនេះ នឹងត្រូវផ្តល់ជូនចំពោះការចុះបញ្ជីមុនខែមករា ឆ្នាំ២០២១។ ស្របពេលជាមួយគ្នានេះផងដែរ ក្រុមហ៊ុនក៏ទទួលបានការលើកលែងទាំងស្រុង ចំពោះបំណុលពន្ធលើប្រាក់ចំណេញ សម្រាប់រយៈពេល១០ឆ្នាំសារពើពន្ធកន្លងទៅដែលបានរកឃើញដោយស្នងការសវនកម្មឯករាជ្យ ក្រោយការធ្វើសវនកម្មពេញលេញរបស់អគ្គ-នាយកដ្ឋានពន្ធដារ។ បន្ថែមលើនេះទៀត ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ ១ (មួយ)ភាគរយ ប្រចាំខែ ត្រូវបានព្យួរជាបណ្តោះអាសន្នរយៈពេល៣ឆ្នាំ។

**គ. ទទួលបាននិរន្តរភាពអាជីវកម្ម ជាមួយនឹងអភិបាលកិច្ចសាជីវកម្ម និងការគ្រប់គ្រងផ្ទៃក្នុងដែលរឹងមាំជាងមុន៖** នៅពេលដែលក្រុមហ៊ុនបានក្លាយជាក្រុមហ៊ុនចុះបញ្ជី ពួកគេនឹងអាចធ្វើឱ្យប្រសើរឡើងនូវអភិបាលកិច្ចសាជីវកម្ម តាមរយៈការរៀបចំឱ្យមានរចនាសម្ព័ន្ធក្រុមប្រឹក្សាភិបាលដែល នឹងមានតួនាទីពិនិត្យលើការបំពេញមុខងាររបស់ថ្នាក់ដឹកនាំរបស់ក្រុមហ៊ុន។ បន្ថែមលើនេះទៀត ម្ចាស់អាជីវកម្មអាចពង្រឹងយន្តការគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុមហ៊ុន ដែលអាចកាត់បន្ថយការអនុវត្តការងារមិនត្រឹមត្រូវ ឬការគៃបន្លំផ្សេងៗក្នុងដំណើរការអាជីវកម្មប្រចាំថ្ងៃ។ ជាលទ្ធផលអភិបាលកិច្ចសាជីវកម្ម និងការគ្រប់គ្រងផ្ទៃក្នុងនឹងជួយដល់សហគ្រាសខ្នាតតូច និងមធ្យមឱ្យមានការរីកចំរើនប្រកបដោយនិរន្តរភាព។ ការទទួលយកការអនុវត្តអភិបាលកិច្ចសាជីវកម្ម នឹងអាចជួយដល់ការត្រៀមខ្លួនរបស់សហគ្រាសខ្នាតតូចនិងមធ្យមក្នុងការប្រកួតប្រជែងជាមួយគូប្រកួតប្រជែងក្នុងតំបន់អាស៊ាន។

**ឃ. ការធ្វើឱ្យប្រសើរឡើងនូវកេរ្តិ៍ឈ្មោះ និងសក្តានុពលរបស់ក្រុមហ៊ុន៖** ក្រុមហ៊ុនចុះបញ្ជីមួយជាទូទៅទាក់ទាញចំណាប់អារម្មណ៍របស់វិនិយោគិនទាំងក្នុងនិងក្រៅប្រទេស តាមរយៈប្រព័ន្ធព័ត៌មានវិទ្យានិងសាធារណជន រីឯប្រតិបត្តិការអាជីវកម្ម ឬប្រតិបត្តិការហិរញ្ញវត្ថុ តែងត្រូវបានផ្សព្វផ្សាយតាមរយៈកាសែត ទូរទស្សន៍ និងគេហទំព័រផ្សេងៗ ព្រមទាំងត្រូវបានលើកឡើងទាំងក្នុងនិងក្រៅប្រទេសផងដែរ។ប្រការនេះ អាចជួយកែលម្អនូវរូបភាព និងកេរ្តិ៍ឈ្មោះរបស់ក្រុមហ៊ុនដែលអាចឱ្យសាធារណជនស្គាល់កាន់តែច្រើនអំពីផលិតផល និងសេវាកម្មរបស់ក្រុមហ៊ុន។ តាមរយៈនេះក្រុមហ៊ុនក៏អាចពង្រឹងនូវឧត្តមានុភាពការប្រកួតប្រជែងរបស់ខ្លួនចំពោះដៃគូប្រកួតប្រជែង

ដែលមិនមែនជាក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រនៅក្នុងបរិបទនៃសេដ្ឋកិច្ចសកលភាវូបនីយកម្ម ដែលពោរពេញដោយការប្រកួតប្រជែងនេះ។

### ១.៤.៣. អត្ថប្រយោជន៍នៃទីផ្សារមូលបត្រចំពោះសេដ្ឋកិច្ចជាតិ

ទីផ្សារមូលបត្រជាឧបករណ៍វាស់ស្ទង់សេដ្ឋកិច្ច មានន័យថា ទីផ្សារមូលបត្រ ត្រូវបានគេចាត់ទុកជាជីពចរនៃសេដ្ឋកិច្ច ឬជាកញ្ចក់ដែលឆ្លុះបញ្ចាំងពីស្ថានភាពសេដ្ឋកិច្ចរបស់ប្រទេស ត្បិតទីផ្សារមូលបត្រជាសូចនាករសេដ្ឋកិច្ចសំខាន់ ដែលជាជំនួយសម្រាប់វិនិយោគិន ក្នុងការរៀបចំនិងសម្រេចចិត្តវិនិយោគឱ្យបានត្រឹមត្រូវ ហើយទីផ្សារមូលបត្រក៏អាចជួយពង្រីកចំណេះដឹងរបស់ប្រជាជន អំពីស្ថានភាពសេដ្ឋកិច្ចរបស់ប្រទេសផងដែរ។ បន្ថែមពីនេះទីផ្សារមូលបត្រ ដើរតួនាទីយ៉ាងសំខាន់ក្នុងសេដ្ឋកិច្ចរបស់ប្រទេសមួយដោយវាអនុញ្ញាតឱ្យក្រុមហ៊ុនសាជីវកម្ម សហគ្រាសសាធារណៈ និងរាជរដ្ឋាភិបាល អាចប្រមូលទុនដោយផ្ទាល់ពីសាធារណជន មកប្រើប្រាស់ដើម្បីពង្រីកអាជីវកម្ម ឬអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជាដើម។ម៉្យាងវិញទៀត អ្នកដែលមានប្រាក់សល់ពីការចំណាយ មានជម្រើសក្នុងការធ្វើពិពិធកម្មសំណុំវិនិយោគរបស់ខ្លួន ឬធ្វើការសន្សំ (ជាមួយមូលបត្រដែលមានហានិភ័យទាប) នៅក្នុងទីផ្សារមូលបត្រ។ នៅពេលដែលសាច់ប្រាក់ហូរពីអ្នកមាន ឬអ្នកដែលមានសាច់ប្រាក់លើសតម្រូវការ ទៅអ្នកដែលត្រូវការ ប្រកបដោយប្រសិទ្ធភាព ពេលនោះសកម្មភាពសេដ្ឋកិច្ចដូចជា ផលិតកម្ម និងពាណិជ្ជកម្ម នឹងរីកលូតលាស់ទៅតាមនោះដែរ ព្រមទាំងបង្កើតឱ្យមានឱកាសការងារតាមរយៈការវិនិយោគបន្ថែម និងបង្កើនទ្រព្យសម្បត្តិសម្រាប់ប្រជាជនទូទៅ។ បន្ថែមពីនេះទៀត ការកើនឡើងនៃទីផ្សារមូលបត្រកម្ពុជា អាចធ្វើឱ្យមានការ ទាក់ទាញវិនិយោគិនមកប្រទេសកម្ពុជា ពីព្រោះថាក្រុមហ៊ុនបរទេសធំៗ ដែលមានបំណងមកវិនិយោគនៅកម្ពុជាអាចបោះផ្សាយលក់មូលបត្រនៅទីផ្សារមូលបត្រកម្ពុជា និងវិនិយោគនៅកម្ពុជាតែម្តង។ នៅពេលមានទីផ្សារនេះអាចជួយជំរុញឱ្យក្រុមហ៊ុនត្រូវប្រកាន់ភ្ជាប់នូវអភិបាលកិច្ចល្អ តម្លាភាពដោយផ្តល់នូវទំនុកចិត្តដល់សាធារណជន ដែលករណីនេះបង្កើតបានបរិយាកាសប្រកួតប្រជែង រវាងក្រុមហ៊ុនដែល មានអភិបាលកិច្ចល្អ មានតម្លាភាព និងក្រុមហ៊ុនដែលមិនមានអភិបាលកិច្ចល្អ និងគ្មានតម្លាភាព។ ដូច្នេះទីផ្សារមូលបត្រ មានសារៈសំខាន់សម្រាប់ជួយជំរុញឱ្យប្រភពមូលធនក្នុងស្រុកមានចលនារស់រវើក និងជាការពង្រីកនូវប្រភពហិរញ្ញវត្ថុសម្រាប់កំណើនសេដ្ឋកិច្ចដ៏រឹងមាំរបស់ប្រទេសកម្ពុជា។[3]

[3] Website: http://www.secc.gov.kh/khmer/m78.php?pn=8 (បានចូលទស្សនានៅថ្ងៃទី ០២ ខែឧសភា ឆ្នាំ២០២០)

## ១.៥. ប្រភេទផ្សេងៗនៃមូលបត្រ

### ១.៥.១. មូលបត្របំណុល

មូលបត្របំណុល ឬសញ្ញាបណ្ណ គឺជាមូលបត្រដែលបញ្ជាក់ពីបំណុលរយៈពេលវែងរបស់អ្នកបោះផ្សាយ ហើយអ្នកបោះផ្សាយសញ្ញាបានត្រូវមានមុខងារសងការប្រាក់សញ្ញាបណ្ណ និងតម្លៃសញ្ញាបានដល់ម្ចាស់កម្មសិទ្ធិសញ្ញាបណ្ណនៅពេលដល់កាលកំណត់របស់សញ្ញាបណ្ណនោះ។

សញ្ញាបានអាចបែងចែកជាច្រើនគេខុសគ្នាប៉ុន្តែប្រសិនបើផ្អែកទៅលើអ្នកបោះផ្សាយសញ្ញាបណ្ណរួមមានពីរប្រភេទគឺ សញ្ញាបណ្ណបណ្ណសាជីវកម្ម និងសញ្ញាបណ្ណរដ្ឋ។[4]

**សញ្ញាបណ្ណសាជីវកម្ម៖** គឺជាប្រភេទមូលបត្រដែលបោះផ្សាយដោយក្រុមហ៊ុនសាជីវកម្មក្នុងគោលដៅប្រមូលធន ដើម្បីបន្ថែមលើមូលធនបណ្តោះអាសន្នបម្រើឱ្យការវិនិយោគបន្ថែមទៀតសម្រាប់ក្រុមហ៊ុន។ សញ្ញាបណ្ណសាជីវកម្ម អាចបោះផ្សាយជាប្រភេទសញ្ញាបណ្ណដូចជា៖ Mortgage Bonds, Convertible Bond, Income Bond, Zero Coupon Bong,...។

**សញ្ញាបណ្ណរដ្ឋ៖** គឺជាប្រភេទមូលបត្រដែលបោះផ្សាយដោយរដ្ឋាភិបាលដើម្បីប្រមូលថវិកាចូលរដ្ឋក្នុងគោលបំណងកសាងហេដ្ឋារចនាសម្ព័ន្ធស្ថាបនាសាធារណៈដូចជា មន្ទីរពេទ្យ ស្ពាន ថ្នល់សាលារៀនជាដើម។ សញ្ញាបណ្ណប្រភេទនេះជាទូទៅមានសុវត្ថិភាពបំផុតពីព្រោះមូលធនត្រូវបានរដ្ឋាភិបាលជាអ្នកធានា ហើយអ្នកទិញវាភាគច្រើនត្រូវបានរួចពន្ធលើប្រាក់ចំណូល។ សញ្ញាបណ្ណរដ្ឋ អាចបោះផ្សាយតាមរយៈពេលនៃប្រភេទសញ្ញាបណ្ណដែលមានដូចជា៖ Treasury Bonds, Munipal Bond, State Bonds,.... ។

ជាទូទៅ ការ វិនិយោគលើសញ្ញាបណ្ណទទួលបានការចាប់អារម្មណ៍ខ្លាំង ដោយសារវាផ្តល់នូវអត្ថប្រយោជន៍ជាច្រើនដល់ទាំងក្រុមហ៊ុន វិនិយោគិន សាធារណៈ និងរដ្ឋ ដែលអត្ថប្រយោជន៍ទាំងនោះមានដូចជា៖

- **ចំពោះក្រុមហ៊ុន៖** ក្រុមហ៊ុនអាចធ្វើហិរញ្ញប្បទានរយៈពេលវែងបានតាមរយៈការបោះផ្សាយសញ្ញាបណ្ណ ដូចជាភាគហ៊ុនដែរ ប៉ុន្តែសញ្ញាបណ្ណមិនធ្វើអោយប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់ភាគហ៊ុននៅក្នុង ក្រុមហ៊ុននោះទេ ។ ម្យ៉ាងវិញទៀត ក្រុមហ៊ុនបង់ការប្រាក់លើសញ្ញាបណ្ណនេះមានកម្រិតទាបជាងការបង់ការប្រាក់ចំពោះកម្ចីធនាគារ ដែលវាផ្តល់នូវភាពងាយស្រួលដល់ក្រុមហ៊ុនក្នុងការពង្រីកអាជីវកម្ម ។

[4] ទីផ្សារ និងស្ថាប័នហិរញ្ញវត្ថុ១, សួនចំរើន, ២០១៧, ទំព័រទី៤០-៤៣

- **ចំពោះវិនិយោគសាធារណៈ៖** ការវិនិយោគលើសញ្ញបណ្ណមានកម្រិតហានិភ័យទាបជាងការវិនិយោគលើភាគហ៊ុន ឬប្រាក់កម្ចីផ្សេងៗ។ សម្រាប់សញ្ញបណ្ណ ជាទូទៅមានតម្លៃចារឹកទាប ដែលធ្វើឲ្យមានភាពងាយស្រួលក្នុងការវិនិយោគ ហើយអ្នកវិនិយោគនឹងទទួលបានចំណូលថេរពីសញ្ញបណ្ណទាំងនោះផងដែរ ។ ម្យ៉ាងវិញទៀត សញ្ញាបណ្ណផ្តល់ភាពងាយស្រួលក្នុងការលក់នៅពេលដែលអ្នកកាន់កាប់ត្រូវការសាច់ប្រាក់វិញ ។
- **ចំពោះរដ្ឋ៖** សញ្ញាបណ្ណរដ្ឋ បានផ្តល់ឲ្យរដ្ឋនូវហិរញ្ញប្បទានរយៈពេលវែងក្នុងការវិនិយោគគម្រោងធំៗ ដែលផ្តល់ផលប្រយោជន៍រយៈពេលវែងដល់សាធារណជនទូទៅ ។ ការបោះផ្សាយសញ្ញាបណ្ណលក់ជាជម្រើសល្អមួយដល់រដ្ឋាភិបាល ជាជាងការខ្ចីប្រាក់ពីបរទេស ឬកម្ចីនានា ។

### ១.៥.២. មូលបត្រកម្មសិទ្ធ

មូលបត្រសិទ្ធិ គឺជាមូលបត្រដែលបានបោះផ្សាយដោយក្រុមហ៊ុនសាធារណៈដើម្បីគៀងគរមូលនិធិពីសាធារណៈជន ហើយមានសិទ្ធិក្នុងការទទួលបានភាគលាភនៅក្នុងអង្គភាពមួយ។ ប្រភេទនៃមូលបត្រកម្មសិទ្ធិរួមមាន[5]៖

**ភាគហ៊ុនធម្មតា៖** គឺជាមូលបត្រទ្រព្យមិនមានរយៈពេលកំណត់ វាបិតថេរទៅតាមការបិតថេររបស់ក្រុមហ៊ុន ដែរ និងភាគលាភត្រូវសងនៅចុងឆ្នាំ។ ជាទូទៅម្ចាស់កាន់កាប់ភាគហ៊ុនធម្មតានេះមានសិទ្ធិក្នុងការចូលរួមបោះឆ្នោតនានានៅក្នុងក្រុមហ៊ុន ដូចជាការបោះឆ្នោតជ្រើសរើសគណៈគ្រប់គ្រងជាដើម ហើយទទួលបានភាគលាភមានការប្រែប្រួល និងទទួលបានបន្ទាប់ពីការបែងចែកទៅឱ្យភាគហ៊ុនបុរិមា។

**ភាគហ៊ុនបុរិមា៖** ឬភាគហ៊ុនអតិភាពមានលក្ខណៈដូចគ្នាទៅនឹងភាគហ៊ុនធម្មតាដែរតែអ្នកកាន់កាប់ភាគហ៊ុននេះនៅពេលបែងចែកភ្លាមគឺទទួលបានមុនគេ ហើយភាគលាភត្រូវបានកំណត់ជាក់លាក់ពីដំបូងលើទឹកប្រាក់កំណត់មួយ។ បន្ថែមលើនេះអ្នកកាន់កាប់ភាគហ៊ុនអាតិភាពពុំមានសិទ្ធិបោះឆ្នោតផ្សេងៗក្នុងក្រុមហ៊ុនទេ។

**សក្ខីបណ្ណទទួលប្រាក់បញ្ញើ៖** ជាប្រភេទមូលបត្រហិរញ្ញវត្ថុ ដែលត្រូវបានគេជួញដូរនៅលើទីផ្សារមូលបត្រក្នុងតំបន់ ដែលវាតំណាងឱ្យបានមូលបត្រ ដែលបានចុះបញ្ជីនៅទីផ្សារមូល- បត្របរទេស។[6]

---

[5] មូលដ្ឋានគ្រឹះនៃទីផ្សារមូលបត្រ, ប៉ៀន សាំង, ២០១១, ទំព័រ ៣៥-៣៦

[6] Michael Simmons, Securities OperationL A Guide to Trade and Position Management

### ១.៥.៣. ឧបករណ៍និស្សន្ទ

ឧបករណ៍និស្សន្ទ ឬឧបករណ៍ដេរីវេទីវ គឺជាឧបករណ៍ហិរញ្ញវត្ថុ និងកិច្ចសន្យារវាងភាគីពីរ ឬច្រើនដែលតម្លៃរបស់វាត្រូវបានកំណត់ដោយការប្រែប្រួលនៃទ្រព្យសកម្ម ។ ទ្រព្យសកម្មទាំងនោះជាទូទៅរួមមាន ភាគហ៊ុន សញ្ញាបណ្ណ វត្ថុធាតុ (មាស ប្រេង) រូបិយបណ្ណ អត្រាការប្រាក់និងសន្ទស្សន៍ទីផ្សារ ។

## ១.៦. ប្រភេទនៃទីផ្សារមូលបត្រ

ជាទូទៅទីផ្សារមូលបត្រត្រូវបានគេបែងចែកចេញជាច្រើនប្រភេទផ្សេងៗពីគ្នា ដោយហេតុថាមូលបត្រមានច្រើនប្រភេទ ប៉ុន្តែបើយើងគិតទៅតាមដំណាក់កាលនៃការដាក់លក់មូលបត្រវិញ គេបែងចែកទីផ្សារ មូលបត្រជា ពីរប្រភេទគឺ ទីផ្សារដំបូង និងទីផ្សារបន្ទាប់ ។

### ១.៦.១. ទីផ្សារដំបូង

ទីផ្សារដំបូង គឺជាកន្លែងដែលមូលបត្រត្រូវបានបោះផ្សាយចេញដោយក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ លក់ទៅឲ្យសាធារណជន ដើម្បីទទួលបាននូវហិរញ្ញប្បទាន ឬមូលធនយកទៅធ្វើការវិនិយោគ ។ នៅក្នុងន័យនេះ វិនិយោគិនដែលជាអ្នកទិញ នឹងត្រូវធ្វើការទិញមូលបត្រផ្ទាល់ពីក្រុមហ៊ុនបោះផ្សាយដែលដើរតួជាអ្នកលក់ ។ លំហូរសាច់ប្រាក់នៅក្នុងទីផ្សារដំបូងនេះ គឺត្រូវបានផ្តល់ដោយវិនិយោគិនដែលបានធ្វើការទិញមូលបត្រនេះ ទៅឲ្យក្រុមហ៊ុនបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ ហើយបន្ទាប់ពីមានការដោះដូររវាងសាច់ប្រាក់ និងមូលបត្រកម្មសិទ្ធិ នោះវិនិយោគិននឹងក្លាយខ្លួនទៅជាម្ចាស់ភាគហ៊ុនរបស់ក្រុមហ៊ុន ហើយក្រុមហ៊ុនបោះផ្សាយនោះ នឹងធ្វើការប្រើប្រាស់សាច់ប្រាក់ដែលប្រមូលបានពីវិនិយោគិន ទៅពង្រឹង ឬពង្រីកអាជីវកម្មរបស់ខ្លួន ។ ម្យ៉ាងវិញទៀត ដំណើរការដែលក្រុមហ៊ុនធ្វើការលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងនេះ ត្រូវបានគេហៅថា "ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង" ឬ "Initial Public Offering (IPO)" ។ នៅក្នុងទីផ្សារនេះ វិនិយោគិនអាចធ្វើការទិញមូលបត្រ ដោយផ្ទាល់ពីក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ។[7] ការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូងនៅក្នុងប្រទេសកម្ពុជាទាំងអស់ ត្រូវតែទទួលបានការអនុញ្ញាតជាមុនពីគណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក.) ដែលដើរតួជានិយ័តករតែមួយគត់ក្នុងវិស័យមូលបត្រ ។

[7] គណៈកម្មការមូលបត្រកម្ពុជា, មគ្គុទេសក៍ស្តីពីការស្វែងយល់ពីហិរញ្ញប្បទានតាមរយៈការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ (ភាគហ៊ុន) ជាសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា, ២០១៧, ទំព័រ៤

### ១.៦.២. ទីផ្សារបន្ទាប់

ទីផ្សារបន្ទាប់ គឺជាទីផ្សារសម្រាប់ ធ្វើការទិញលក់មូលបត្រដែលបានបោះផ្សាយលក់ជាសាធារណៈរួចហើយ មានន័យថា ជាទីផ្សារសម្រាប់ធ្វើការជួញដូរមូលបត្ររវាងវិនិយោគិន និងវិនិយោគិនក្នុងគោលបំណងមួយស្វែងរកប្រាក់ចំណេញដែលបានពីការទិញលក់នេះ ។ ប្រាក់ដែលបានមកពីសកម្មភាពជួញដូរនៅលើទីផ្សារបន្ទាប់ គឺបានទៅលើអ្នកកាន់កាប់មូលបត្រផ្ទាល់ មិនមែនបានទៅក្រុមហ៊ុនបោះផ្សាយមូលបត្រនោះទេ និយាយឲ្យងាយស្រួលគឺ ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រមិនទទួលបានផលប្រយោជន៍អ្វីពីការជួញដូរលើទីផ្សារបន្ទាប់នេះឡើយ ។ ការជួញដូរនៅទីផ្សារបន្ទាប់គឺធ្វើឡើងនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ផ.ម.ក.) ។ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា មានតួនាទីចម្បងនៅក្នុងការផ្តល់សេវាទីកន្លែង និងប្រព័ន្ធជួញដូរ សម្រាប់ឲ្យវិនិយោគិនមានភាពងាយស្រួលក្នុងការជួបគ្នា ដើម្បីធ្វើការជួញដូរមូលបត្រ ។ នាពេលបច្ចុប្បន្ន ទីផ្សារបន្ទាប់ត្រូវបានគេបែងចែកជាពីរគឺ ៖

- ទីផ្សារមូលបត្រ (Organized Exchange) ៖ សំដៅលើការជួញដូរមូលបត្រតាមរយៈទីផ្សារមូលបត្រ ដែលបមានទីកន្លែងជួញដូរជាក់លាក់មួយ មានវិធានទីផ្សារ និងមានប្រព័ន្ធជួញដូរដើម្បីគ្រប់គ្រងដំណើរការជួញដូរ ។
- ទីផ្សារមូលបត្រក្រៅប្រព័ន្ធ (Over-the-Counter – OTC) ៖ សំដៅលើការជួញដូរមូលបត្រក្រៅប្រព័ន្ធទីផ្សារមូលបត្រ ដែលពុំមានទីកន្លែងជួញដូរជាក់លាក់និងមិនផ្លូវការនោះទេ ។ វិនិយោគិនអាចជួញដូរមូលបត្រដោយការចរចារតាមរយៈទូរស័ព្ទ អ៊ីម៉ែល និងប្រព័ន្ធជួញដូររបស់ក្រុមហ៊ុនណាមួយ ។ ភាគច្រើននៃទីផ្សារនេះ ក្រុមហ៊ុនពាណិជ្ជករមូលបត្រជាអ្នកដាក់នូវការកំណត់ថ្លៃទិញ-លក់មូលបត្រជូនអតិថិជន និងក្រុមហ៊ុនពាណិជ្ជករមូលបត្រដ៏ទៃទៀត ។

## ១.៧. តួអង្គសំខាន់ៗក្នុងទីផ្សារមូលបត្រ

ជាទូទៅ នៅក្នុងដំណើរការទីផ្សារមូលបត្រគឺត្រូវមានអ្នកចូលរួមសំខាន់ៗមួយចំនួន ដែលក្នុងនោះរួមមាន៖

**ហេដ្ឋារចនាសម្ព័ន្ធ** (Infrastructure) ៖ សំដៅដល់បទគតិយុត្តផ្សេងៗដូចជាច្បាប់ បទប្បញ្ញត្តិ ដែលបានបង្កើតឡើងដោយនិយ័តករមូលបត្រ ដើម្បីគ្រប់គ្រងទីផ្សារមូលបត្រឲ្យមានប្រសិទ្ធិភាព សមធម៌ តម្លាភាព និងទូទាត់មូលបត្រផងដែរ ។ នៅកម្ពុជា និយ័តករមូលបត្រដែលបង្កើតបទដ្ឋានគតិយុត្តទីផ្សារមូលបត្រនោះគឺ គណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក.) ហើយ

ចំណែកឯប្រព័ន្ធជួញដូរ រក្សាទុក និងផាត់ទាត់ និងទូទាត់មូលបត្រត្រូវបានផ្តល់ដោយ **ក្រុមហ៊ុនផ្សារមូលបត្រ** (ផ.ម.ក.) ។

**អន្តរការីមូលបត្រ** (Intermediary) ៖ សំដៅដល់អង្គភាព ឬបុគ្គលដែលជាជំនួយការនៅក្នុងដំណើរការទាំងអស់ដែលទាក់ទងនឹងមូលបត្រ ។ អន្តរការីមានតួនាទីជាអ្នកផ្តល់ប្រឹក្សាយោបល់ ណែនាំ និងជាជំនួយនៅក្នុងការបោះផ្សាយ និងទិញលក់មូលបត្រ ដល់ទាំងក្រុមហ៊ុនបោះផ្សាយ និងវិនិយោគិនសាធារណៈ។ នៅក្នុងទីផ្សារមូលបត្រអន្តរការីមានដូចជា ពាណិជ្ជករមូលបត្រ អ្នកធានាទិញមូលបត្រ ឈ្មួញជើងសារ និងភ្នាក់ងារពាក់ព័ន្ធផ្សេងៗទៀត ។ ប្រសិនបើគ្មានវត្តមានអន្តរការីនោះទេ នោះពុំមានការតភ្ជាប់ក្រុមហ៊ុនបោះផ្សាយ ទៅកាន់ និយ័តករ និងផ្សារមូលបត្រនោះឡើយ ហើយក៏គ្មានអ្នកទាក់ទងវិនិយោគិនទិញឡើយ ហើយក៏គ្មានអ្នកទាក់ទាញវិនិយោគិនមូលបត្រជូនទៅឲ្យក្រុមហ៊ុនបោះផ្សាយលក់មូលបត្រដែរ ។

**ក្រុមហ៊ុនបោះផ្សាយ** (Issuer) ៖ គឺជាអង្គភាពដែលបោះផ្សាយមូលបត្រនៃក្រុមហ៊ុនរបស់ខ្លួនដាក់លក់ឲ្យវិនិយោគិនសាធារណៈ ដើម្បីស្វែងរកដើមទុនបន្ថែមដល់ក្រុមហ៊ុន និងពង្រីកអាជីវកម្មរបស់ខ្លួន ដែលវាគឺជាតួអង្គដ៏សំខាន់មួយនៅក្នុងទីផ្សារមូលបត្រ ពីព្រោះបើគ្មានវត្តមានរបស់ក្រុមហ៊ុនបោះផ្សាយនោះទេ ក៏គ្មានមូលបត្រសម្រាប់លក់ និងជួញដូរនៅទីផ្សារដែរ ។ ជាទូទៅក្រុមហ៊ុនដែលអាចបោះផ្សាយលក់មូលបត្រជាសាធារណៈបាន លុះត្រាតែបំពេញទៅតាមលក្ខខណ្ឌតម្រូវផ្សេងៗ ស្របទៅតាមច្បាប់ និងបទប្បញ្ញត្តិនានា ដែលបានរៀបចំ និងអនុម័តដោយអាជ្ញាធរមូលបត្រនៃប្រទេសនីមួយៗ ។

**វិនិយោគិន** (Investor) ៖ សំដៅទៅដល់អ្នកទិញ និងអ្នកលក់ ឬក៏អ្នកជួញដូរមូលបត្រក្នុងគោលបំណងដើម្បីស្វែងរកប្រាក់ចំណេញពីការវិនិយោគលើមូលបត្រនោះ ។ វិនិយោគិនអាចជាសាធារណជនទូទៅ ឬក៏ជា ស្ថាប័ន ដែលវិនិយោគិនទាំងនេះដើរតួយ៉ាងសំខាន់ផងដែរ ព្រោះបើពុំមានវិនិយោគិននោះទេ ការបោះផ្សាយលក់និងការជួញដូរមូលបត្រក៏ពុំអាចទទួលបានភាពជោគជ័យនោះដែរ ។

# ជំពូកទី២

# ស្ថានភាពទូទៅរបស់
# គណៈកម្មការមូលបត្រ
# កម្ពុជា

# ជំពូកទី២

# ស្ថានភាពទូទៅរបស់គណៈកម្មការមូលបត្រកម្ពុជា

## ២.១. ប្រវត្តិសង្ខេបរបស់គណៈកម្មការមូលបត្រកម្ពុជា

គណៈកម្មការមូលបត្រកម្ពុជា (**គ.ម.ក.**) ត្រូវបានបង្កើតឡើងក្រោមបញ្ញាតិនៃច្បាប់ស្តីពី "ការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន" ដែលត្រូវបានសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការកាលពី ថ្ងៃទី២៩ ខែមេសា ឆ្នាំ ២០០៩ ។ ការរៀបចំ និងការប្រព្រឹត្តទៅនៃ គ.ម.ក. ត្រូវបានធ្វើឡើងដោយអនុលោមតាមអនុក្រឹត្យស្តីពី "ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា" ដែលត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨។

## ២.២. ចក្ខុវិស័យ និងបេសកកម្ម

ក្នុងគោលបំណងគ្រប់គ្រងវិស័យមូលបត្រក្នុងប្រទេសកម្ពុជាប្រកបដោយស្ថេរភាព មានតម្លាភាព មានយុត្តិធម៌ និងមានសណ្តាប់ធ្នាប់ គណៈកម្មការមូលបត្រមូលបត្រកម្ពុជា ដែលគេច្រើនហៅកាត់ថា **គ.ម.ក.** មានចក្ខុវិស័យ និងបេសកកម្មដូចខាងក្រោម៖

### ២.២.១. ចក្ខុវិស័យ

គណៈកម្មការមូលបត្រកម្ពុជាហៅកាត់ថា **គ.ម.ក.** ត្រូវបានបង្កើតឡើងក្រោយពីច្បាប់មូលបត្ររដ្ឋ និងច្បាប់ស្តីពីការបោះផ្សាយ និងជួញដូរមូលបត្រមហាជនបានអនុម័តរួច។ **គ.ម.ក.** មានគោលដៅគ្រប់គ្រងវិស័យមូលបត្រក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងចូលរួមចំណែកដល់ការអភិវឌ្ឍន៍ សេដ្ឋកិច្ចជាតិ និងសង្គមតាមរយៈការកៀរគរមូលធនពីសាធារណៈជន ឬអ្នកវិនិយោគមូលបត្រ ដើម្បីឆ្លើយតបទៅនឹងតម្រូវការហិរញ្ញវត្ថុសម្រាប់ការវិនិយោគនៅកម្ពុជា។

### ២.២.២. បេសកកម្ម

- បង្កើត និងរក្សាឱ្យមានទំនុកចិត្តពីអ្នកវិនិយោគនៅក្នុងព្រះរាជាណាចក្រកម្ពុជាតាមរយៈការការពារសិទ្ធិស្របច្បាប់របស់អ្នកវិនិយោគ និងធានាឱ្យមានការបោះផ្សាយ និងការជួញដូរមូលបត្រប្រកបដោយសណ្តាប់ធ្នាប់ និងត្រឹមត្រូវ។
- លើកកម្ពស់ការគ្រប់គ្រងទីផ្សារមូលបត្រឱ្យមានប្រសិទ្ធភាព និងជំរុញការអភិវឌ្ឍទីផ្សារនេះឱ្យមានសណ្តាប់ធ្នាប់ និងរបៀបរៀបរយ។
- ជំរុញឱ្យមានភាពសម្បូរបែបនៃឧបករណ៍សញ្ញ័យ តាមរយៈការទិញមូលបត្រ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត។

- ជំរុញឱ្យមានការធ្វើវិនិយោគទុនពីបរទេស និងការចូលរួមក្នុងទីផ្សារមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- ជួយសម្រួលដល់ការធ្វើឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ នៅក្នុងព្រះរាជណាចក្រកម្ពុជា។

## ២.៣. ទីតាំងរបស់គណៈកម្មការមូលបត្រកម្ពុជា

គណៈកម្មការមូលបត្រកម្ពុជាមានទីតាំងនៅ ផ្ទះលេខ៩៩ ផ្លូវលេខ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

- ទូរស័ព្ទលេខ: ១១ ៥៦ ៨៨ ២៣ (៨៥៥)
- ទូរសារ: ២២ ៥៦ ៨៨ ២៣ (៨៥៥)
- អីម៉ែល: INFO@SECC.GOV.KH
- គេហទំព័រ: www.secc.gov.kh



*រូបភាព 1.- ទីតាំងរបស់គណៈកម្មការមូលបត្រកម្ពុជា*

## ២.៤. រូបសញ្ញា និងអត្ថន័យនៃរូបសញ្ញា

គណៈកម្មការមូលបត្រកម្ពុជា មានរូបសញ្ញាដូចជាស្ថាប័នរដ្ឋដទៃទៀត ដែលមានកំណត់សម្គាល់ដូចខាងក្រោម៖

### ២.៤.១. រូបសញ្ញា

- រូបហង្សពណ៌មាស

- រូបភាពស្លឹកឈើផ្នែកខាងឆ្វេង មានការលិចស្រមោលពណ៌មាស ហើយខាងស្តាំរំលេចស្រមោលពណ៌ប្រផេះ
- រូបរង្វង់ថាសដែលពាក់ កណ្តាលមានពណ៌មាស និងពាក់កណ្តាលទៀតមានពណ៌ប្រផេះ
- មានអក្សរពណ៌ទឹកប៊ិច ព័ទ្ធជុំវិញជារង្វង់នៅផ្នែកខាងលើមានអក្សរខ្មែរថា "គណៈកម្មការមូលបត្រកម្ពុជា" និងពាក់កណ្តាលនៃរង្វង់ នៅផ្នែកខាងក្រោមជាអក្សរអង់គ្លេសថា "SECURITIES AND EXCHANGE COMMISSION OF CAMBODIA"




*រូបភាព 2.- រូបសញ្ញាគណៈកម្មការមូលបត្រកម្ពុជា*

## ២.៤.២. អត្ថន័យនៃរូបសញ្ញា

- **រូបហង្សមានពណ៌មាស** តំណាងឱ្យអាជ្ញាធរហិរញ្ញវត្ថុ ដែលជាអ្នកត្រួតពិនិត្យ និងគ្រប់គ្រងប្រត្តិបត្តិការមូលបត្រ និងធានាឱ្យដំណើរការនៃទីផ្សារប្រកបដោយប្រសិទ្ធភាព មានសណ្តាប់ធ្នាប់ និងតម្លាភាព។
- **រូបរង្វង់ថាសដែលពាក់កណ្តាលមានពណ៌មាស និងពាក់កណ្តាលទៀតមានពណ៌ប្រផេះ** គឺតំណាងឱ្យភាពចំណេញខាតនៃដំណើរការទីផ្សារ។
- **រូបហង្សពណ៌មាសឈរលើរង្វងថាស ដែលមានជើងម្ខាង ជាន់លើផ្ទៃពណ៌មាស និងជើងម្ខាងទៀតជាន់លើផ្ទៃពណ៌ប្រផេះ** ចង់បង្ហាញពីភាពចំណេញខាត ឬភាពឡើងចុះនៃកិច្ចដំណើរការទីផ្សារដោយស្ថិតនៅក្រោមការត្រួតពិនិត្យ និងគ្រប់គ្រងរបស់អាជ្ញាធរ ជាគណៈកម្មការមូលបត្រកម្ពុជាប្រកបដោយប្រសិទ្ធភាព សណ្តាប់ធ្នាប់ និងតម្លាភាពគ្នាជានិច្ច។

- **រូបស្លឹកឈើ** តំណាងឱ្យលទ្ធផលជាផ្លែផ្កានៃការចូលរួមចំណែក របស់វិស័យមូលបត្រក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។

➢ **មូលហេតុនៃជម្រើសយករូបហង្សពណ៌មាសជានិមិត្តសញ្ញា**

- រូបហង្សពណ៌មាសជាប់ពាក់ព័ន្ធទៅនឹងដំណើរការអភិវឌ្ឍន៍នៃរូបិយវត្ថុរបស់ខ្មែរ ដោយរូបនេះត្រូវបានប្រើប្រាស់ ជាលើកដំបូងនៅលើប្រាក់ប្រាសាទ ក្នុងរាជ្យកាលព្រះបាទអង្គឌួង ដើម្បីរំលឹកដល់លោក **សំអាង ហង្ស** ដែលព្រះបាទអង្គឌួងបញ្ជូនអោយទៅសិក្សាវិជ្ជាបោះផ្សាយប្រាក់នៅបរទេស ហើយលោកបានចូលរួមចំណែកយ៉ាងខ្លាំងក្នុងការធ្វើឱ្យរូបិយវត្ថុមានអត្តសញ្ញាណច្បាស់លាស់ និងដាក់ចេញឱ្យប្រើប្រាស់ក្នុងសេដ្ឋកិច្ច។
- រូបហង្សពណ៌មាសនេះ ជារូបសញ្ញាតំណាងឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនាសម័យសង្គមរាស្ត្រនិយម ក្នុងសម័យព្រះរាជាណាចក្រកម្ពុជាទី២ និងសម័យសាធារណរដ្ឋ ក្រោមការដឹកនាំដោយការឆ្លាតវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលនាពេលនោះត្រូវគ្នានឹងគណៈកម្មការមូលបត្រកម្ពុជា ដែលជាអាជ្ញាធរហិរញ្ញវត្ថុ ហើយមានប្រធានជា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគឺឯកឧត្តមឧបនាយករដ្ឋមន្ត្រី **គាត ឈន់**។

### ២.៤.៣. ត្រារបស់គណៈកម្មការមូលបត្រកម្ពុជា

ត្រារបស់គណៈកម្មការមូលបត្រកម្ពុជា មានលក្ខណៈប្រហាក់ប្រហែលនឹងត្រាមូលរបស់អាជ្ញាធរ ឬស្ថាប័នរដ្ឋដទៃទៀតដែរ ដោយនៅកន្លែងរង្វង់មូលផ្នែកខាងលើមានអក្សរសរសេរថា "**ព្រះរាជាណាចក្រកម្ពុជា**" ផ្នែកកណ្តាលមានសញ្ញា ប្រាសាទអង្គរវត្ត និងផ្នែកខាងក្រោមមានអក្សរសរសេរថា "**គណៈកម្មការមូលបត្រកម្ពុជា**" ។




*រូបភាព 3.- ត្រារបស់គណៈកម្មការមូលបត្រកម្ពុជា*

## ២.៥. មុខងាររបស់គណៈកម្មការមូលបត្រកម្ពុជា

គណៈកម្មការមូលបត្រកម្ពុជា គឺជាស្ថាប័នដែលមានមុខងារគ្រប់គ្រង ត្រួតពិនិត្យទីផ្សារមូលបត្រ គ្រប់គ្រងរាល់បណ្តាលប្រតិបត្តិការ ក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនបោះផ្សាយមូលបត្រ និងការពារវិនិយោគិនមូលបត្រ ព្រមទាំងធានាឱ្យការជួញដូរមូលបត្រ ប្រកបដោយសណ្តាប់ធ្នាប់ និងត្រឹមត្រូវក្នុងវិស័យមូលបត្រនៃព្រះរាជាណាចក្រកម្ពុជា។ ការគ្រប់គ្រងនេះមានគោលបំណងចូលរួមចំណែកដល់ការអភិវឌ្ឍនៃសេដ្ឋកិច្ចជាតិ និងសង្គម តាមរយៈការប្រមូលមូលធនពីអ្នកវិនិយោគ ដើម្បីឆ្លើយតបទៅនឹងតម្រូវការហិរញ្ញវត្ថុសម្រាប់ធ្វើការ វិនិយោគនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

គណៈកម្មការមូលបត្រកម្ពុជា មានតួនាទីដូចខាងក្រោម[8] ៖

- គ្រប់គ្រង និងត្រួតពិនិត្យទីផ្សារមូលបត្រ នៅក្នុងព្រះរាជាណាចក្រកម្ពុជារួមទាំងទីផ្សារមូលបត្ររដ្ឋ។
- ដាក់ឱ្យអនុវត្តនូវគោលនយោបាយ ដែលពាក់ព័ន្ធនឹងទីផ្សារមូលបត្រ។
- កំណត់លក្ខខណ្ឌ ដើម្បីផ្តល់ការអនុញ្ញាត ជូនប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ។
- កំណត់លក្ខខណ្ឌដើម្បីផ្តល់អាជ្ញាប័ណ្ណជូនក្រុមហ៊ុនមូលបត្រ និងភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រ។
- លើកកម្ពស់ និងជម្រុញដល់ការគោរពតាមលក្ខខណ្ឌនៃច្បាប់នេះ។
- ដើរតួជាស្ថាប័នពិនិត្យ និងដោះស្រាយលើការតវ៉ាចំពោះសេចក្តីសម្រេចរបស់នីតិបុគ្គលមានអាជ្ញាប័ណ្ណ ដែលប៉ះពាល់ផលប្រយោជន៍របស់សមាជិកអ្នកចូលរួម ឬអ្នកវិនិយោគ។
- ពិគ្រោះយោបល់ជាមួយបុគ្គល ដែលមានលក្ខណៈសម្បត្តិសមស្រប ដើម្បីបង្កើតគោលនយោបាយសម្រាប់ការអភិវឌ្ឍទីផ្សារមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

[8] ច្បាប់ស្តីពី ការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន, ភ្នំពេញ ២០០៧

## ២.៦. សមាសភាពរបស់គណៈកម្មការមូលបត្រកម្ពុជា

គណៈកម្មការមូលបត្រកម្ពុជាត្រូវបានបង្កើតឡើងក្រោមច្បាប់ស្តីពី ការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ដែលមានប្រធាន ១ រូប ជារដ្ឋមន្ត្រីនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងមានសមាជិក ៨ រូប ដែលមានដូចជា៖

- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ១ រូប
- តំណាងក្រសួងពាណិជ្ជកម្ម ១ រូប
- តំណាងធានាគារជាតិនៃកម្ពុជា ១ រូប
- តំណាងក្រសួងយុត្តិធម៌ ១ រូប
- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ១ រូប
- អគ្គនាយកនៃ គ.ម.ក. ១ រូប
- អ្នកជំនាញដែលមានបទពិសោធន៍ក្នុងវិស័យមូលបត្រ ២ រូប

**សមាជិក គ.ម.ក អាណត្តិទី២ (២០១៣ - ២០១៨)**

គណៈកម្មការមូលបត្រកម្ពុជាដែលមានឯកឧត្តមបណ្ឌិត អូន ព័ន្ធមុនីរ័ត្ន ទេសរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាប្រធាន មានសមាជិកចំនួន ០៨ រូបដែលមានអាណត្តិរយៈពេល ០៥ ឆ្នាំ ។ សមាជិកទាំងនោះរួមមាន៖

- ឯកឧត្តមបណ្ឌិត អូន ព័ន្ធមុនីរ័ត្ន ជាទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាន គ.ម.ក.
- លោកជំទាវ **ងួន សុខា** ជារដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាសមាជិកនៃ គ.ម.ក.
- លោកជំទាវ **នាវ ច័ន្ទថាណា** ជាអគ្គទេសាភិបាលរងនៃធនាគារជាតិកម្ពុជា និងជាសមាជិកនៃ គ.ម.ក.
- លោកជំទាវ **តឹករ៉េត កំរង** ជារដ្ឋលេខាធិការនៃក្រសួងពាណិជ្ជកម្ម ជាសមាជិក គ.ម.ក.
- ឯកឧត្តម **កើត រិទ្ធ** ជារដ្ឋលេខាធិការក្រសួងយុត្តិធម៌ និងជាសមាជិក គ.ម.ក.
- ឯកឧត្តម **គឹម រ័ត្នវិសិដ្ឋ** ជាទីប្រឹក្សា និងជានាយកខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាសមាជិក គ.ម.ក.
- ឯកឧត្តម **ស៊ូ សុជាតិ** ជាអគ្គនាយកនៃ គ.ម.ក. និងជាសមាជិក គ.ម.ក.

- លោកសាស្ត្រាចារ្យបណ្ឌិត **សំ យឌ្នី** ជាអ្នកជំនាញមកពីវិស័យឯកជនដែលមានបទពិសោធន៍វិស័យមូលបត្រ និងជាសមាជិក គ.ម.ក.
- លោកសាស្ត្រាចារ្យបណ្ឌិត **សំ សុខុម** ជាអ្នកជំនាញមកពីវិស័យឯកជនដែលមានបទពិសោធន៍វិស័យមូលបត្រ និងជាសមាជិក គ.ម.ក.។

## ២.៧. រចនាសម្ព័ន្ធអង្គភាពចាត់តាំងរបស់គណៈកម្មការមូលបត្រកម្ពុជា

គ.ម.ក. មានរចនាសម្ព័ន្ធចាត់តាំងដូចខាងក្រោម ៖




*រូបភាព 4.- រចនាសម្ព័ន្ធចាត់តាំងរបស់គណៈកម្មការមូលបត្រកម្ពុជា*

### ➢ នាយកដ្ឋានរបស់ គ.ម.ក.

គ.ម.ក. មាននាយកដ្ឋានចំណុះចំនួន ០៦ (ប្រាំមួយ) ដែលត្រូវគ្រប់គ្រងដោយអគ្គនាយកនៃ គ.ម. ក មានដូចជា៖

- នាយកដ្ឋាន ត្រួតពិនិត្យអង្គការីមូលបត្រ
- នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិ
- នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ
- នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ
- នាយកដ្ឋានកិច្ចការគតិយុត្ត
- អគ្គភាពសវនកម្មផ្ទៃក្នុង

# ជំពូកទី៣
# ស្ថានភាពទូទៅរបស់
# ក្រុមហ៊ុនផ្សារមូលបត្រ
# កម្ពុជា

# ជំពូកទី៣

# ស្ថានភាពទូទៅរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

## ៣.១. ប្រវត្តិនៃការបង្កើតទីផ្សារមូលបត្រកម្ពុជា

ដើម្បីសម្រេចបាននូវការអភិវឌ្ឍប្រទេសកម្ពុជា ដោយឈរលើគោលដៅក្នុងការជំរុញកំណើនសេដ្ឋកិច្ចតាមរយៈលំហូរមូលធន ការវិនិយោគ និងការវិភាគជាថ្មីនូវមូលធនតាមយន្តការទីផ្សារមូលធន នៅខែ វិច្ឆិកា ឆ្នាំ ២០០៦ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េបានចុះ ហត្ថលេខាលើអនុស្សរណៈយោគយល់ ស្តីអំពី "ការអភិវឌ្ឍផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា"។ ដោយផ្អែកលើអនុស្សរណៈយោគយល់នេះ **សម្តេចអគ្គសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានប្រកាស បើកឲ្យដំណើរការគម្រោងបង្កើតទីផ្សារមូលបត្រនៅប្រទេសកម្ពុជា នៅខែកញ្ញា ឆ្នាំ២០០៧។ នៅឆ្នាំ២០០៨ អនុស្សរណៈយោគយល់មួយទៀតស្តីអំពី "ការបង្កើតផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា" ត្រូវបានចុះហត្ថលេខាដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា ជាមួយនឹងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។ នៅខែ មីនា ឆ្នាំ ២០០៩ រាជរដ្ឋាភិបាលកម្ពុជា ដែលតំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ បានចុះកិច្ចព្រមព្រៀង ក្រុម-ហ៊ុនចំរុះ (Joint Venture) ដើម្បីបង្កើតផ្សារមូលបត្រ "ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា" ស្របតាមច្បាប់ស្តីអំពីសហគ្រាសសាធារណៈ។ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាបានចុះក្នុងបញ្ជីពាណិជ្ជកម្មនៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១០។ ស្របតាមកិច្ចព្រមព្រៀងក្រុមហ៊ុនចំរុះ (Joint Venture) ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កាន់កាប់ភាគហ៊ុនចំនួន៥៥%នៃភាគហ៊ុនសរុបរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ហើយ ក្រុមហ៊ុនផ្សារមូលបត្រកូរ៉េកាន់កាប់ភាគហ៊ុនចំនួន ៤៥% នៃភាគហ៊ុនសរុបរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាបានទទួលអាជ្ញាបណ្ណជាប្រតិបត្តិករទីផ្សារមូល-បត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ ព្រមទាំងប្រតិបត្តិកររក្សាទុកមូលបត្រពី គណៈកម្មការមូលបត្រកម្ពុជា (**គ.ម.ក.**) ស្របតាមច្បាប់ស្តីអំពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

ក្រោមដំណើរការជាច្រើនដំណាក់កាលកន្លងមក នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១ គឺជាថ្ងៃប្រវត្តិសាស្ត្រដ៏សំខាន់មួយ នៃវិស័យហិរញ្ញវត្ថុ និងជាមោទនភាពជាតិមួយសម្រាប់កម្ពុជា ដែលនៅទីបំផុត ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (Cambodia Securities Exchange) បានឈានដល់ដំណាក់កាលចុងក្រោយ ដែលនឹងត្រូវបានសម្ពោធដាក់ឱ្យមានដំណើរការ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់

របស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **គាត ឈន់** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា។ ទន្ទឹមនឹងនោះ ការខិតខំប្រឹងប្រែងនៅតែ បន្តរហូតដល់ថ្ងៃទី១២ ខែមករា ឆ្នាំ២០១២ **ឯកឧត្តម ហ៊ាន សាហ៊ីប** ប្រធានក្រុមប្រឹក្សាភិបាល នៃផ្សារមូលបត្រកម្ពុជា បានប្រកាសបញ្ជាក់ពីស្នាដៃ និងលទ្ធផលសម្រេចបានកន្លងមក ក៏ដូចជាបង្ហាញពីភាពត្រៀមខ្លួនរួចជាស្រេចសម្រាប់ដំណើរការផ្សារមូលបត្រមួយនេះនៅប្រទេសកម្ពុជា។ ជាក់ស្តែង ការរៀបចំហេដ្ឋារចនាសម្ព័ន្ធទីផ្សារ ទាំងផ្នែករឹង ទាំងផ្នែកទន់ ត្រូវបាន សម្រេចដោយជោគជ័យទាំងស្រុង ពិសេសនោះគឺ "**ទីផ្សារ**" (ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា) និង "**អន្តរការីទីផ្សារ**" (ក្រុមហ៊ុនមូលបត្រ)។ ប៉ុន្តែនៅមានភាពយឺតយ៉ាវមួយចំនួន ពោលគឺ "**ផលិតផល**" (ក្រុមហ៊ុនចុះបញ្ជី) កំពុងស្ថិតក្នុងដំណាក់កាលចុងក្រោយនៃការរៀបចំ ការបោះផ្សាយមូលបត្រលើកដំបូង (IPO) របស់ខ្លួន។ ជាលទ្ធផលចុងក្រោយបង្អស់នៃការងារ ខិតខំប្រឹងប្រែងកន្លងមក នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២ នៅវេលាម៉ោង ០៩:០៩នាទី ព្រឹក ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា បានអនុវត្តការជួញដូរមូលបត្រកម្មសិទ្ធិជាលើកដំបូងដែលត្រូវបាន ប្រកាសបើកជាផ្លូវការ តាមរយៈសារវីដេអូដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** និងមានវត្តមានតំណាងដោយ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **គាត ឈន់**។[9]

## ៣.២. ចក្ខុវិស័យ និងបេសកកម្ម

### ៣.២.១. ចក្ខុវិស័យ

ដើម្បីធ្វើឲ្យក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា មានដំណើរការល្អនិងការរីកចម្រើន នៅលើមាគ៌ាមួយដ៏ត្រឹមត្រូវ ក្រុមហ៊ុនបានកំណត់គោលការណ៍យ៉ាងច្បាស់លាស់ ទៅលើចក្ខុវិស័យរបស់ខ្លួនគឺដើម្បីកសាងនូវ "មហាវិថី" ហិរញ្ញវត្ថុសម្រាប់កម្ពុជា ក្នុងគោលបំណងផ្តល់ភាពងាយស្រួលដល់អតិថិជនក្នុងការជួញដូរមូលបត្រ។[10]

### ៣.២.២. បេសកកម្ម

ដើម្បីសម្រេចបាននូវចក្ខុវិស័យខាងលើ ក្រុមហ៊ុនផ្សារមូលបត្រ បានដាក់ចេញនូវបេសកកម្មមួយចំនួនដូចជា៖

- ជួញសម្រួលក្នុងការកៀរគរមូលធនរបស់ក្រុមហ៊ុននៅកម្ពុជា

---

[9] Cambodia Securities Exchange (2019) ទិដ្ឋភាពទូទៅរបស់ ផ.ម.ក. Retrieved July 01, 2019 from website: http://csx.com.kh/kh/about/profile.jsp?MNCD=10301v

[10] Cambodia Securities Exchange (2019) ចក្ខុវិស័យ&បេសកកម្ម Retrieved July 01, 2019 from website: http://csx.com.kh/kh/about/mission.jsp?MNCD=1020

- បង្កើត និងបង្កើននូវបរិយាកាសជួញដូរមូលបត្រដែលអំណោយផលដល់វិនិយោគិនទាំងក្នុង និងក្រៅប្រទេស
- បង្កើតនូវផលិតផល និងសេវាកម្មដ៏ទំនើបជាច្រើនប្រភេទសម្រាប់អ្នកចូលរួម ទីផ្សារទាំងអស់
- ជួយដាក់ឲ្យដំណើរការនូវ សហគ្រាសសាធារណៈមួយដែលមាន ស្វ័យចីរភាពក្រោមមគ្គុទេសដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា។[11]

## ៣.៣. នាមករណ៍ និងផ្លាកសញ្ញារបស់ផ្សារមូលបត្រកម្ពុជា

### ក. នាមករណ៍

នាមករណ៍របស់ក្រុមហ៊ុនមាននាមជាភាសាខ្មែរថា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដែលហៅកាត់ថា (**ផ.ម.ក.**) និងជាភាសាអង់គ្លេសថា Cambodia Securities Exchange ដែលហៅកាត់ថា (CSX)។

### ខ. ផ្លាកសញ្ញា

*រូបភាព 5.- ស្លាកសញ្ញាក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា*

ផ្លាកសញ្ញារបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាមានអត្តសញ្ញាណដូចខាងក្រោម៖ ផ្នែកខាងលើ មានសរសេរអក្សរពណ៌ខៀវថា ផ្សារមូលបត្រកម្ពុជា ដែលជាឈ្មោះតំណាងរបស់ក្រុមហ៊ុន។ រីឯនៅផ្នែកខាងស្តាំ មានរូបហង្សពណ៌មាសមួយ ដែលឈរបែរមុខទៅខាងស្តាំ។ ចំនែកនៅពីក្រោមអក្សរផ្នែកខាងឆ្វេង មានឈ្មោះរបស់ក្រុមហ៊ុនផ្សារមូលបត្រជាអក្សរកាត់ភាសាអង់គ្លេសដែលមានពណ៌ខៀវដូចនឹងឈ្មោះខាងលើដែរ។

[11] Cambodia Securities Exchange (2019) ចក្ខុវិស័យ&បេសកកម្ម Retrieved July 01, 2019 from website: http://csx.com.kh/kh/about/mission.jsp?MNCD=1020

## ៣.៤. ព័ត៌មានទំនាក់ទំនងរបស់ក្រុមហ៊ុនមូលបត្រកម្ពុជា

**អាសយដ្ឋាន** : អាគារ ផ.ម.ក. វិថីព្រះមហាក្សត្រីយានី កុសុមៈ (ផ្លូវ ១០៦) សង្កាត់ វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

**ទូរស័ព្ទ** : (៨៥៥) ២៣ ៩៥ ៨៨៨៨/ ២៣ ៩៥ ៨៨៨៥

**ទូរសារ** : (៨៥៥) ២៣ ៩៩ ៥៥ ៥៨

**គេហទំព័រ** : www.csx.com.kh

**ហ្វេសបុក** : https://www.facebook.com/cambodia.csx/

**ក្រសួងនិងស្ថាប័នពាក់ព័ន្ធ** : info@csx.com.kh[12]

## ៣.៥. រចនាសម្ព័ន្ធនៃការគ្រប់គ្រង




*រូបភាព 6.- រចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា*

## ៣.៦. ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលនៃ **ផ.ម.ក.** រួមមានសមាជិកចំនួន **៧រូប** ដោយរាប់បញ្ចូលទាំងប្រធានក្រុមប្រឹក្សាភិបាល អនុប្រធានក្រុមប្រឹក្សាភិបាល (ដែលជាអគ្គនាយករងផងដែរ) និងអគ្គនាយក។ ប្រធានក្រុមប្រឹក្សាភិបាល និងអគ្គនាយកជាតំណាងរបស់រាជរដ្ឋាភិបាលកម្ពុជា។ ចំណែកឯអនុប្រធាន ក្រុមប្រឹក្សាភិបាល គឺជាតំណាងរបស់ក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។

[12] Cambodia Securities Exchange (2019) ព័ត៌មានសម្រាប់ទំនាក់ទំនង Retrieved July 01, 2019 from website: http://csx.com.kh/kh/about/contact.jsp?MNCD=10703

សមាជិកចំនួន **៤រូប** ផ្សេងទៀត គឺជាអភិបាលមិនអចិន្ត្រៃយ៍ដោយក្នុងនោះ ២ រូបត្រូវបានតែងតាំងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង **២រូប** ទៀតត្រូវបានតែងតាំងដោយក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។ នៅក្នុងក្រុមប្រឹក្សាភិបាលនៃ **ផ.ម.ក.** រួមមានសមាជិកចំនួន **៧រូប** ដោយរាប់បញ្ចូលទាំងប្រធានក្រុមប្រឹក្សាភិបាល អនុប្រធានក្រុមប្រឹក្សាភិបាល (ដែលជាអគ្គនាយករងផងដែរ) និងអគ្គនាយកនោះមានដូចខាងក្រោម៖

- ឯ.ឧ. បណ្ឌិត **ហ៊ាន សាហ៊ីប** ប្រធានក្រុមប្រឹក្សាភិបាលអគ្គលេខាធិការរងនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- Mr. **Lee Ihnsoo** អនុប្រធានក្រុមប្រឹក្សាភិបាល អគ្គនាយករងនៃក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។
- លោក **ហុង សុហួរ** សមាជិកអគ្គនាយកនៃក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។
- លោក **វ័ន្ត សារុធ** សមាជិកអគ្គនាយករងនៃធនាគារជាតិនៃកម្ពុជា។
- លោក **ហ៊ឹម ហ៊ាន** សមាជិកប្រធាននាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម។
- Mr. **KI-JOON YOON** សមាជិកអគ្គនាយករងជាន់ខ្ពស់នៃនាយកដ្ឋាន Global Business Management នៃក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។
- Mr. **HWI-SHIG CHO** សមាជិកប្រធាននាយកដ្ឋានប្រតិបត្តិការទីផ្សារនៃក្រុមហ៊ុនផ្សារមូល-បត្រកម្ពុជា។[13]

13 Cambodia Securities Exchange (2019) ក្រុមប្រឹក្សាភិបាល Retrieved July 01, 2019 from website: http://csx.com.kh/kh/about/director.jsp?MNCD=10303

# ជំពូកទី៤
# ដំណើរការទីផ្សារមូលបត្រ
# នៅកម្ពុជា

# ជំពូកទី៤

# ដំណើរការទីផ្សារមូលបត្រនៅកម្ពុជា

## ៤.១. ក្របខ័ណ្ឌនិងបទប្បញ្ញត្តិពាក់ព័ន្ធនឹងមូលបត្រនៅកម្ពុជា

ដើម្បីអនុវត្តន៍នូវគោលនយោបាយអភិវឌ្ឍន៍វិស័យមូលបត្រ នៅក្នុងប្រទេសកម្ពុជាឲ្យមានប្រសិទ្ធិភាពនោះ រាជរដ្ឋាភិបាលកម្ពុជាបានតាក់តែងរៀបចំ និងអនុម័តច្បាប់ និងអនុក្រឹតនានាមួយចំនួន។ នៅក្នុងនោះ ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ព្រមទាំងច្បាប់ស្តីពីមូលបត្ររដ្ឋ ត្រូវបានអនុម័ត និងប្រកាសឲ្យប្រើដោយរាជក្រម នៅក្នុងឆ្នាំ ២០០៧។ ច្បាប់ស្តីពីមូល-បត្រមហាជន ត្រូវបានគេបង្កើតឲ្យមានឡើងក្នុងគោលបំណងមួយដើម្បីគ្រប់គ្រងទីផ្សារមូលបត្រ ប្រតិបត្តិករមូលបត្រ ក្រុមហ៊ុនបោះផ្សាយ និងបុគ្គលពាក់ព័ន្ធដទៃទៀតដែលបានធ្វើសកម្មភាពនានានៅក្នុងវិស័យមូលបត្រនៅកម្ពុជា។ ដោយផ្អែកទៅតាមច្បាប់នេះ គណៈកម្មការមូលបត្រកម្ពុជា ត្រូវបានបង្កើតឡើង ហើយការរៀបចំនិងការប្រព្រឹត្តទៅត្រូវបានកំណត់ដោយអនុ-ក្រឹតចុះថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ២០០៨។ គណៈកម្មការមូលបត្រកម្ពុជា បានរៀបចំនូវបទប្បញ្ញត្តិផ្សេងៗ ដើម្បីកំណត់លក្ខខ័ណ្ឌដែលពាក់ព័ន្ធនឹងមូលបត្រ រួមមាន អនុក្រឹតស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងជួញដូរមូលបត្រមហាជន អនុក្រឹតស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ និងប្រកាសជាច្រើនទៀតដែលបង្កើតឡើងដោយគណៈកម្មការមូលបត្រកម្ពុជា ស្តីពីការផ្តល់អាជ្ញាបណ្ណ ការបោះផ្សាយលក់មូលបត្រ ការទទួលស្គាល់ ការកំណត់កម្រៃសាវា ការដាក់ឲ្យអនុវត្តន៍វិធានផ្សេងៗ និងការបង្ហាញពត៌មានសាជីវកម្មជាដើម។ លទ្ធផលដែលបានមកពីការអនុវត្តច្បាប់ និងបទប្បញ្ញត្តិទាំងនេះគឺ តួអង្គសំខាន់ៗនៅក្នុងវិស័យមូលបត្រកម្ពុជា ដូចជាក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារផ្សេងទៀតដែលពាក់ព័ន្ធនឹងមូលបត្រ ត្រូវបានផ្តល់អាជ្ញាបណ្ណទទួលស្គាល់ពីគ.ម.ក. ជាបន្តបន្ទាប់ ហើយនៅក្នុងនោះដែរ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាក៏ទទួលបានអាជ្ញាបណ្ណពីគ.ម.ក.កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១១ ដើម្បីផ្តល់សេវាកម្មទីផ្សារមូលបត្រ សាវាផាត់ទាត់និងទូទាត់ និងសាវារក្សាទុកមូលបត្រ។ បទប្បញ្ញត្តិទាំងអស់នេះ គឺជាហេដ្ឋារចនាសម្ព័ន្ធចាំបាច់មួយសម្រាប់ការអភិវឌ្ឍវិស័យមូលបត្រនៅកម្ពុជា ឲ្យមានដំណើរការទៅដោយរលូន។

## ៤.២. តួអង្គសំខាន់ៗក្នុងទីផ្សារមូលបត្រកម្ពុជា

ទីផ្សារមូលបត្រកម្ពុជា គឺជាទីផ្សារដ៏ថ្មីស្រឡាងមួយសម្រាប់សាធារណៈជនក្នុងប្រទេសកម្ពុជា។ ទីផ្សារនេះអាចដំណើរការទៅបាន អាស្រ័យលើតួអង្គសំខាន់ៗដែលមានដូចជា និយ័តករមូលបត្រសំដៅដល់គណៈកម្មការមូលបត្រកម្ពុជា ប្រតិបត្តិករមូលបត្រសំដៅដល់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាក្រុមហ៊ុន បោះផ្សាយមូលបត្រ ក្រុមហ៊ុនមូលបត្រ និងវិនិយោគិនមូលបត្រ។

### ៤.២.១. គណៈកម្មការមូលបត្រកម្ពុជា

គណៈកម្មការមូលបត្រកម្ពុជា (ហៅកាត់ថា **គ.ម.ក.**) ឬជាភាសាអង់គ្លេស Securities and Exchange Commission of Cambodia (ហៅកាត់ថា **SECC**) ត្រូវបានបង្កើតឡើងក្រោមបញ្ញាតិនៃច្បាប់ស្តីពី "ការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន" ដែលត្រូវបានសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការកាលពី ថ្ងៃទី២៩ ខែមេសា ឆ្នាំ ២០០៩ ។ គណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក.) ជាស្ថាប័នដែលមានមុខងារគ្រប់គ្រង ត្រួតពិនិត្យទីផ្សារមូលបត្រ គ្រប់គ្រងបណ្តាប្រតិបត្តិករមូលបត្រ ក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនបោះផ្សាយមូលបត្រ និងសំដៅការការពារអ្នកវិនិយោគមូលបត្រ ព្រមទាំងធានាឱ្យមានការជួញដូរមូលបត្រប្រកបដោយសណ្តាប់ធ្នាប់ និងត្រឹមត្រូវនៅក្នុងវិស័យមូលបត្រនៃព្រះរាជាណាចក្រកម្ពុជា[14]។

និយាយជារួម គ.ម.ក. មានតួនាទីជាអាជ្ញាធរអាណាព្យាបាលក្នុងវិស័យមូលបត្រដែលជាអ្នកផ្តល់ការអនុញ្ញាត និងអាជ្ញាបណ្ណចំពោះបុគ្គលទាំងឡាយណាដែលមានបំណងចង់ធ្វើសកម្មភាពអាជីវកម្មពាក់ព័ន្ធនឹងមូលបត្រ ហើយ គ.ម.ក. ក៏ជាអ្នកគ្រប់គ្រង និងត្រួតពិនិត្យទៅលើសកម្មភាពក្នុងវិស័យមូលបត្រទាំងនោះផងដែរ។ បន្ថែមលើសពីនេះទៅទៀតនោះ គ.ម.ក. មានមុខងារជានិយ័តករក្នុងវិស័យមូលបត្រ ដែលសំដៅដល់អ្នករៀបចំបង្កើត និងដាក់ឲ្យអនុវត្តន៍គោលនយោបាយនានា ក៏ដូចជាកំណត់លក្ខខ័ណ្ឌលម្អិត ដើម្បីធានានូវដំណើរការអភិវឌ្ឍទីផ្សារមូលបត្រនៅកម្ពុជា។

### ៤.២.២. ប្រតិបត្តិករមូលបត្រ

ប្រតិបត្តិករមូលបត្រ គឺសំដៅទៅដល់ទីផ្សារមូលបត្រកម្ពុជា (ផ.ម.ក) ដែលត្រូវបានបង្កើតឡើងដោយរាជរដ្ឋាភិបាលកម្ពុជាតំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយនឹងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។ បើយោងទៅតាមច្បាប់ស្តីពី "ការបោះផ្សាយ និងការជួញដូរមូលបត្រ

[14] គេហទំព័ររបស់គណៈកម្មការមូលបត្រកម្ពុជា (www.secc.gov.kh) (ចូលមើលថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២០)

មហាជន″ ផ.ម.ក បានទទួលនូវការអនុញ្ញាតពី គ.ម.ក. ឲ្យធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ និងប្រតតបត្តិកររក្សាទុកមូលបត្រ។

### ៤.២.២.១. ប្រតិបត្តិករទីផ្សារមូលបត្រ

ផ.ម.ក. ផ្តល់នូវប្រព័ន្ធជួញដូរ ជាទីផ្សារទិញលក់មូលបត្រដែលអ្នកទិញ ព្រមទាំងអ្នកលក់មូលបត្រអាចធ្វើការជួញដូរជាមួយគ្នានៅថ្លៃជាក់លាក់ណាមួយ។ ការជួញដូរនេះ អាចប្រព្រឹត្តទៅបានដោយមានជំនួយការពីក្រុមហ៊ុនជើងសារមូលបត្រ។

### ៤.២.២.២. ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ

បន្ទាប់ពីការជួញដូរត្រូវបានផ្ទួរផ្ទង់ដោយប្រព័ន្ធជួញដូររបស់ ផ.ម.ក. រួចហើយ ផ.ម.ក. ដើរតួនាទីជាអ្នកផាត់ទាត់ និងទូទាត់ ដើម្បីធានាបានថាអ្នកលក់នឹងទទួលបានការនូវការទូទាត់ ហើយអ្នកទិញនឹងទទួលបានភាពជាម្ចាស់លើមូលបត្រកម្មសិទ្ធិទៅតាមចំនួនមូលបត្រដែលបានជួញដូរ។

### ៤.២.២.៣. ប្រតិបត្តិកររក្សាទុកមូលបត្រ

ប្រតិបត្តិកររក្សាទុកមូលបត្រសំដៅទៅដល់កន្លែងសម្រាប់ដាក់ផ្ញើរមូលបត្រដែលបានជួញដូររួចរវាងវិនិយោគិន និងវិនិយោគិន។ រាល់មូលបត្រទាំងអស់ ដែលត្រូវបានគេរក្សាទុកនៅក្នុងប្រព័ន្ធអេឡិចត្រូនិចយ៉ាងមានសុវត្ថិភាព។ បន្ទាប់ពីបានធ្វើការផាត់ទាត់ និងទូទាត់រួច មូលបត្រទាំងនោះនឹងត្រូវបានផ្ទេរកែប្រែ និងលុបចោលតាមរយៈគណនី Book-Entry ដោយគ្មានការផ្ទេរមូលបត្រជារូបវន្តនោះទេ។

## ៤.២.៣. អន្តរការីមូលបត្រ

អន្តរការីមូលបត្រ មានសារៈសំខាន់យ៉ាងខ្លាំងណាស់ចំពោះផ្សារមូលបត្រ ពីព្រោះរាល់ការជួញដូរគឺប្រព្រឹត្តទៅបានតាមរយៈជំនួយពីអន្តរការីមូលបត្រនេះ។ អន្តរការីមូលបត្រ សំដៅទៅដល់ក្រុមហ៊ុនមូលបត្រ ហើយបើយោងទៅតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ក្រុមហ៊ុនមូលបត្រសំដៅដល់ក្រុមហ៊ុន ឬក៏ក្រុមហ៊ុនសហកម្មសិទ្ធិដែលទទួលបានអាជ្ញាបណ្ណដើម្បីធ្វើអាជីវកម្មមូលបត្រដែលមានដូចជាអាជីវកម្មធានាទិញ អាជីវកម្មជួញដូរមូលបត្រ និងអាជីវកម្មជើងសារមូលបត្រ។

### ៤.២.៣.១. ក្រុមហ៊ុនធានាទិញមូលបត្រ

ក្រុមហ៊ុនធានាទិញមូលបត្រ សំដៅលើក្រុមហ៊ុនដែលធ្វើអាជីវកម្មតែជាមួយក្រុមហ៊ុនបោះផ្សាយតែប៉ុណ្ណោះ។ ក្រុមហ៊ុនធានាទិញមូលបត្រដើរតួយ៉ាងសំខាន់ក្នុងការជួយសម្របសម្រួល

និងសហការជាមួយសមាជិកក្រុមការងារបោះផ្សាយលក់មូលបត្រផ្សេងទៀត ក្នុងការរៀបចំឯកសារពាក់ព័ន្ធ និងត្រួតពិនិត្យដំណើរការចុះបញ្ជីទាំងស្រុង រួមទាំងដំណាក់កាលនៃការបំពេញកាតព្វកិច្ចតាមផ្លូវច្បាប់ផងដែរ។ បើយោងទៅតាមប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណដល់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារមូលបត្រ សកម្មភាពរបស់ក្រុមហ៊ុនធានាទិញមូលបត្ររួមមាន៖

- ផ្តល់ប្រឹក្សាសំខាន់ទៅលើការបោះផ្សាយលក់មូលបត្រជាសាធារណៈ ដូចជាការដាក់តម្លៃមូលបត្រ ការកំណត់ទំហំទឹកប្រាក់និងចំនួនមូលបត្រនៃសំណើរបោះផ្សាយលក់មូលបត្រ និងការកំណត់ពេលវេលានៃការបោះផ្សាយលក់មូលបត្រជាសាធារណៈជាដើម។
- ទិញមូលបត្រទាំងអស់ ឬទិញមួយផ្នែកពីក្រុមហ៊ុនបោះផ្សាយមូលបត្រក្នុងគោលដៅចែកចាយ ឬក៏លក់បន្ត។
- ទិញមូលបត្រដែលលក់មិនអស់ ក្នុងដំណើរការបោះផ្សាយមូលបត្រជាសាធារណៈ នៅក្នុងគោលដៅធានានូវភាពជោគជ័យនៃការបោះផ្សាយ។
- រៀបចំនូវដំណើរការបោះផ្សាយលក់មូលបត្រជាសាធារណៈ ឲ្យក្រុមហ៊ុនបោះផ្សាយ ឬចូលរួមដោយផ្ទាល់ ឬមិនផ្ទាល់នៅក្នុងដំណើរការបោះផ្សាយលក់មូលបត្រជាសាធារណៈ។

ក្រុមហ៊ុនធានាទិញមូលបត្រ (Securities Underwriter) នៅផ្សារមូលបត្ររួមមាន៖

| ក្រុមហ៊ុនធានាទិញមូលបត្រ | |
|---|---|
| **១. យាន់តា ស៊ីឃ្យូរីធី (ខេមបូឌា) ភីអិលស៊ី**<br>Yuanta Securities (Cambodia) Plc. | អគារ Emerald ជាន់ទី៤ លេខ៦៤ (កែងផ្លូវ ១៧៨) មហាវិថីព្រះនរោត្តម សង្កាត់ជ័យជំនះ ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ<br>ទូរសព្ទ : ០២៣ ៨៦០ ៨០០<br>ទូរសព្ទដៃ : ០៩២ ៧៧៧ ៣០៩<br>ទូរសារ : ០២៣ ២២៤ ១២៦<br>អ៊ីម៉ែល : yuanta@yuantacambodia.com<br>គេហទំព័រ : www.yuantacambodia.com |
| **២. អ អេច ប៊ី ឥណ្ឌូឆៃណា ស៊ីឃ្យូរីធី ម.ក**<br>RHB Indochina Securities PLC. | អគារលេខ ១-៣ ជាន់ទី ២ និងទី ៣ ផ្លូវលេខ ២៧១ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ ភ្នំពេញ<br>ទូរសព្ទ : ០២៣ ៩៦៩ ១៦១<br>ទូរសារ : ០២៣ ៩៦៩ ១៧១ |

| | |
|---|---|
| ៣. កាណា ស៊ីឃ្យូរីធី អិលធីឌី<br>Cana Securities Ltd. | វិមានកាណាឌីយ៉ា ជាន់ទី ១៥ លេខ ៣១៥ ផ្លូវព្រះអង្គឌួង កែងមហាវិថីព្រះមុនីវង្ស សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>ទូរសព្ទ : ០២៣ ៩៩៩ ៨៨៧<br>០២៣ ៨៦៨ ២២២<br>ទូរសារ : ០២៣ ៩៩០ ៦៨៦<br>អ៊ីម៉ែល : info@canasecurities.com.kh<br>គេហទំព័រ : www.canasecurities.com.kh |
| ៤. កម្ពុ ស៊ីឃ្យូរីធី ភីអិលស៊ី<br>Campu Securities Plc. | អគារកម្ពុប៊ែង លេខ ២៣ ជាន់ទី ៦ ផ្លូវលេខ ១១៤ សង្កាត់ផ្សារថ្មីទី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>ទូរសព្ទ : ០២៣ ២២២ ៨៨០<br>០២៣ ២២២ ៨៨១<br>ទូរសារ : ០២៣ ២២២ ៨៨៧<br>អ៊ីម៉ែល : campusec@campusecurities.com.kh<br>gohklye@campusecurities.com.kh |
| ៥. អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីឃ្យូរីធី<br>SBI Royal Securities Plc. | អាគារភ្នំពេញថៅវ័រ លេខ ៤៤៥ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងព្រលឹត<br>ខណ្ឌ៧មករា រាជធានីភ្នំពេញ<br>ទូរសព្ទ : ០២៣ ៩៩៦ ៩៧០<br>០២៣ ៩៩៦ ៩៧១<br>អ៊ីម៉ែល : info@sbiroyal.com |
| ៦. ភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី<br>Phnom Penh Securities Plc. | អគារ GT Tower ជាន់ទី២ មហាវិថីសាធារណរដ្ឋឆែក (១៦៩) សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ<br>ទូរសព្ទ : ០២៣ ៩២៦ ៩៩៩<br>អ៊ីម៉ែល : info@pps.com.kh<br>គេហទំព័រ : www.pps.com.kh |

### ៤.២.៣.២. ក្រុមហ៊ុនពាណិជ្ជករមូលបត្រ

ក្រុមហ៊ុនពាណិជ្ជករមូលបត្រ អាចធ្វើការជួញដូរមូលបត្រ ក្នុងទីផ្សារមូលបត្រ។ ដូចនេះ តម្រូវឱ្យក្រុមហ៊ុនពាណិជ្ជករមូលបត្រមានគណនីផ្ទាល់ខ្លួនសម្រាប់ធ្វើការជួញដូរមូលបត្រ។ ក្នុងការជួញដូរនេះ ក្រុមហ៊ុនពាណិជ្ជករមូលបត្រអាចទទួលបានផលចំណេញពីមូលបត្រ ហើយក៏ត្រូវប្រឈមមុខនឹងហានិភ័យក្នុងការជួញដូរមូលបត្រផងដែរ[15]។ ក្នុងនាមជាក្រុមហ៊ុនពាណិជ្ជករមូលបត្រអាចមានសិទ្ធិធ្វើអាជីវកម្មដូរមូលបត្រ អាជីវកម្មឈ្មួញជើងសារមូលបត្រ និងអាជីវកម្មផ្តល់ប្រឹក្សាវិនិយោគ។ បច្ចុប្បន្នក្រុមហ៊ុនពាណិជ្ជករមូលបត្រមានតែក្រុមហ៊ុន ហ្គោលដេន ហ្វ័រឈូន (ខេមបូឌា) ភីអិលស៊ី តែប៉ុណ្ណោះ។

| ក្រុមហ៊ុនពាណិជ្ជករមូលបត្រ | |
|---|---|
| ១.ហ្គោលដេន ហ្វ័រឈូន (ខេមបូឌា) ស៊ីយូរីធី ភីអិលស៊ី<br>Golden Fortune (Cambodia) Securities Plc. | អគារលេខ ១៧៤ ABCD មហាវិថីម៉ៅសេងទុង សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ<br>ទូរសព្ទ : ០២៣ ២១៨ ២៨៨<br>០២៣ ២១៨ ៣៨៨<br>ទូរសារ : ០២៣ ២១០ ១១១ |

### ៤.២.៣.៣. ក្រុមហ៊ុនជើងសារមូលបត្រ

ក្រុមហ៊ុនមូលបត្រដែលជាក្រុមហ៊ុនឈ្មួញជើងសារមូលបត្រ មាននាទីជាអ្នកទទួលទិញ ឬលក់មូលបត្រ តាមបញ្ជារបស់អតិថិជនរបស់ខ្លួន[16]។ ក្នុងន័យនេះ សាធារណៈជនមិនអាចធ្វើការទិញ-លក់ មូលបត្រដោយផ្ទាល់នៅលើទីផ្សារមូលបត្របានទេ ប្រតិបត្តិការនេះទាមទារឱ្យឆ្លងកាត់អន្តរការីដែលជាក្រុមហ៊ុនឈ្មួញជើងសារមូលបត្រ។ ក្រុមហ៊ុនឈ្មួញជើងសារមូលបត្រទទួលបានកម្រៃជើងសារមូលបត្រ ទទួលបានកម្រៃជើងសារពីការ ទទួលបញ្ជាទិញ ឬលក់ពីអតិ-ថិជនរបស់ខ្លួន។ ក្នុងនាមជាក្រុមហ៊ុនឈ្មួញជើងសារមូលបត្រ គឺអាចមានសិទ្ធិធ្វើអាជីវកម្មឈ្មួញ

[15] ប្រកាសស្តីពីកាផ្តល់អាជ្ញាបណ្ណដល់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារមូលបត្រ,លេខ ០០៩ គ.ម.ក. ១៩ វិច្ឆិកា ២០០៩ , ប្រការ៦។

[16] ប្រកាសស្តីពីកាផ្តល់អាជ្ញាបណ្ណដល់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រ,លេខ ០០៩ គ.ម.ក. ១៩ វិច្ឆិកា ២០០៩ , ប្រការ៧។

ជើងសារមូលបត្រ និងអាជីវកម្មផ្តល់ប្រឹក្សាវិនិយោគ។ ក្រុមហ៊ុនទាំងនោះរួមមានដូចជា៖

| ក្រុមហ៊ុនឈ្មួញជើងសាមូលបត្រ | |
|---|---|
| ១. អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី<br>ACLEDA Securities Plc. | នៅជាន់ទី៥ អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ។<br>ទូរសព្ទ : ០២៣ ៧២៣ ៣៨៨<br>ទូរសារ : ០២៣ ៧២៣ ៣៧៧<br>អ៊ីម៉ែល : info@acledasecurities.com.kh<br>acs.admin@acledasecurities.com.kh<br>គេហទំព័រ : www.acledasecurities.com.kh |
| ២. ខេប ស៊ីឃ្យូរីធី លីមីធីត<br>CAB Securities Limited. | អគារលេខ ៩២ D ក្រុម ៦៧ វិថី ២៨៩ សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ។<br>ទូរសព្ទ : ០២៣ ២២០ ០០០<br>០២៣ ២២២ ០១៨<br>ទូរសារ : ០២៣ ៩២៦ ៦២៨ |
| ៣. ខេមបូឌាវៀតណាម ស៊ីឃ្យូរីធីឯ.ក<br>Cambodia-Vietnam Securities Co., Ltd. | អគារលេខ ៣៧០ ជាន់ទី៨ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងកេងកងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ<br>ទូរសព្ទ : ០២៣ ៧២៣ ៨៩៩<br>ទូរសារ : ០២៣ ៧២៣ ៨៩០<br>អ៊ីម៉ែល : info@cvs.com.kh<br>គេហទំព័រ : www.cvs.com.kh |

### ៤.២.៣.៤. ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុ

ក្រុមហ៊ុនទីប្រឹក្សាវិនិយោគ មានតួនាទីជាអ្នកផ្តល់ប្រឹក្សាអំពីការវិនិយោគលើមូលបត្រ និងបោះផ្សាយកាលវិភាគនៃការវិនិយោគលើមូលបត្រ សម្រាប់បវិនិយោគិនសាធារណៈ[17]។ ចំពោះក្រុមហ៊ុនទីប្រឹក្សាវិនិយោគមិនតម្រូវអោយមានអាជ្ញាបណ្ណពីគណៈកម្មការមូលបត្រកម្ពុជាទេ តែក្រុមហ៊ុននេះត្រូវតែមានភ្នាក់ងារទីប្រឹក្សាវិនិយោគ ឬភ្នាក់ងារក្រុមហ៊ុនមូលបត្រដែលទទួលអាជ្ញាបណ្ណពី គណៈកម្មការមូលបត្រកម្ពុជាយ៉ាងតិចមួយរូប។ ក្នុងនាមជាក្រុមហ៊ុនប្រឹក្សវិនិយោគអាចមានសិទ្ធតែធ្វើអាជីវកម្មផ្តល់ប្រឹក្សាវិនិយោគតែប៉ុណ្ណោះ។ ក្រុមហ៊ុនប្រឹក្សាវិនិយោគមានចំនួនពីរដែលមានដូចខាងក្រោម៖

| ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុ | |
|---|---|
| ១. អេ ភី អិម (ខេមបូឌា) ស៊ីឃ្យូរីធី ឯ.ក APM (CAMBODIA) SECURITIES CO., LTD. | ជាន់ទី៦ អាគារវីត្រាស់ ប្លុកអេ ផ្លូវ ១៦៧ សង្កាត់វាលវង់ ខណ្ឌ ៧មករា រាជធានីភ្នំពេញ |

### ៤.២.៤. ភ្នាក់ងារក្រុមហ៊ុនមូលបត្រ

ភ្នាក់ងារក្រុមហ៊ុនមូលបត្រ គឺសំដៅទៅដល់បុគ្គលដែលបំពេញនូវមុខងារ ឬក៏សកម្មភាពតាមការឯកសាររបស់ក្រុមហ៊ុនមូលបត្រដែលតម្រូវឲ្យមាន និងត្រូវមានអាជ្ញាបណ្ណដោយអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងជួញដូរមូលបត្រមហាជន[18]។ ភ្នាក់ងារសំខាន់ៗដែលចូលរួមក្នុងសកម្មភាពជួញដូរមូលបត្រ រួមមាន ភ្នាក់ងារទូទាត់សាច់ប្រាក់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ភ្នាក់ងារបញ្ជិកាមូលបត្រ ចុះបញ្ជីផ្ទេរមូលបត្រ និងទូទាត់មូលបត្រ។

### ៤.២.៤.១. ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ

ភ្នាក់ងារទូទាត់សាច់ប្រាក់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ គឺជាធានាគារពាណិជ្ជដែលធ្វើប្រតិបត្តិការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រជូនទៅដល់អតិថិជនរបស់ខ្លួន ដោយសំដៅដល់ការគ្រប់គ្រង និងការធានាឲ្យបានថាវិនិយោគិនដែលជាអ្នកលក់ នឹងទទួលបនាការទូទាត់ជា

---

[17] ប្រកាសស្តីពីកាផ្តល់អាជ្ញាបណ្ណដល់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រ,លេខ ០០៩ គ.ម.ក. ១៩ វិច្ឆិកា ២០០៩ , ប្រការ៨។

18 ឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយ និងជួញដូរមូលបត្រមហាជន

សាច់ប្រាក់ ជាថ្នូរនឹងការផ្ទេរនូវមូលបត្រកម្មសិទ្ធិដល់អ្នកទិញវិញ ដែលប្រកបទៅដោយភាពត្រឹមត្រូវ ភាពមានសុវត្ថិភាព និងប្រព្រឹត្តទៅតាមពេលកំណត់។ ភ្នាក់ងារទូទាត់សាច់ប្រាក់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រនៅក្នុងទីផ្សារមូលបត្ររួមមាន៖

- ធានាគារ អេស៊ីលីដា ភីអិលស៊ី
- ធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី
- ធនាគារកាណាឌីយ៉ា
- ធនាគារកម្ពុជាសាធារណៈ ភីអិលស៊ី

### ៤.២.៤.២. ភ្នាក់ងារបញ្ជិកាមូលបត្រ ចុះបញ្ជីផ្ទេរមូលបត្រ និងទូទាត់មូលបត្រ

ភ្នាក់ងារបញ្ជិកាមូលបត្រ ចុះបញ្ជីផ្ទេរមូលបត្រ និងទូទាត់មូលបត្រ សំដៅទៅដល់អ្នកដែលទទួលបាននូវការអនុញ្ញាតក្នុងការផ្តល់សេវាក្នុងនាមជាក្រុមហ៊ុនបោះផ្សាយ ដែលនៅក្នុងនោះ៖

- **ភ្នាក់ងារបញ្ជិកាមូលបត្រ៖** គ្រប់គ្រងនូវដំណើរការបរិវិសកម្ម បែងចែកមូលបត្រឲ្យបានត្រឹមត្រូវ កត់ត្រាបញ្ជីកម្មសិទ្ធិមូលបត្រ ធ្វើរបាយការណ៍ឲ្យក្រុមហ៊ុនបោះផ្សាយ និងគណៈកម្មការមូលបត្រកម្ពុជា ស្តីពីការបញ្ចប់ដំណើរការបរិវិសកម្ម និងជូបដំណឹងដល់កម្មសិទ្ធិករមូលបត្រជាដើម។
- **ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ៖** ក្រោយពេលដែលមូលបត្រកម្មសិទ្ធិ ត្រូវបានបែងចែកទៅឲ្យអ្នកធ្វើបរិវិសកម្មរួច ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ត្រូវរក្សា និងគ្រប់គ្រងបញ្ជីកម្មសិទ្ធិករមូលបត្រ ធ្វើរបាយការណ៍ទាក់ទងទៅនឹងការផ្លាស់ប្តូរកម្មសិទ្ធិ បញ្ជូនរបាយការណ៍ និងពត៌មានផ្សេងៗរួមមានការបែងចែកភាគលាភ ការបង់ប្រាក់ជាជូនដល់កម្មសិទ្ធិករមូលបត្រ និងសេវាពាក់ព័ន្ធផ្សេងៗ។
- **ភ្នាក់ងារទូទាត់មូលបត្រ៖** ដើរតួជាអ្នកគណនាភាគលាភ ការប្រាក់ ប្រាក់ដើមជាដើម ទៅតាមការណែនាំរបស់ក្រុមហ៊ុនបោះផ្សាយ រួចហើយធ្វើការទូទាត់ជូនកម្មសិទ្ធិករមូលបត្រ និងភាគីពាក់ព័ន្ធ រៀបចំរបាយការណ៍ និងបញ្ជូនពត៌មានចាំបាច់ទាក់ទងទៅនឹងការទូទាត់។

ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេមូលបត្រ និងភ្នាក់ងារទូទាត់ មានចំនួន បី ៖

- ធនាគារ អេស៊ីលីដា ភីអិលស៊ី
- ក្រុមហ៊ុន ត្រាយខ័រ ស៊ីយ្យូរីធី សិរីល ភីអិលស៊ី
- ក្រុមហ៊ុន ភ្នំពេញ ស៊ីយ្យូរីធី ភីអិលស៊ី

### ៤.២.៥. ក្រុមហ៊ុនបោះផ្សាយ

បើយោងតាមសន្ធានុក្រមនៅក្នុងគេហទំព័រគណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនបោះផ្សាយ គឺជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុតដែលទទួលបានការអនុញ្ញាតពីគណៈកម្មការមូលបត្រកម្ពុជា ដើម្បីបោះផ្សាយលក់មូលបត្រជាសាធារណៈ។ ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត សំដៅលើក្រុមហ៊ុនដែលបង្កើតឡើង និងចុះបញ្ជីតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មក្នុងគោលបំណងបោះផ្សាយមូលបត្រលក់ជាសាធារណៈ។ ក្រុមហ៊ុនបោះផ្សាយមូលបត្រជាតួអង្គយ៉ាងសំខាន់ក្នុងវិស័យមូលបត្រ ព្រោះបើគ្មានក្រុមហ៊ុនបោះផ្សាយមូលបត្រទេ នោះក៏មិនមានមូលបត្រដាក់លក់លើទីផ្សារឡើយ។ ក្រុមហ៊ុនបោះផ្សាយមូលបត្រក៏អាច ទទួលបានអត្ថប្រយោជន៍ពីលក់មូលបត្រដូចជា ការប្រមូលទុនវិនិយោគ ជាជាងការខ្ចីឥណទាន ពីធានាគារ និងដៃគូពាណិជ្ជកម្មផ្សេងៗ ព្រមទាំងកៀរគរមូលធន ឬដើមទុនពីវិនិយោគសាធារណៈសម្រាប់ពង្រីកការវិនិយោគរបស់ក្រុមហ៊ុនថែមទៀត។

បើគិតមកដល់ត្រឹមដើមឆ្នាំ២០២០ នេះ ក្រុមហ៊ុនបោះផ្សាយមូលបត្រនៅកម្ពុជាសរុបមានចំនួន ៨ក្រុមហ៊ុន រួមមាន៖

ក្រុមហ៊ុនបោះផ្សាយមូលបត្រកម្មសិទ្ធិចំនួនប្រាំ

- រដ្ឋាករទឹកស្វយ័ត្រក្រុងភ្នំពេញ (PWSA)
- ក្រុមហ៊ុនហ្គ្រេនធ្វីន អ៊ិនធើណេសិនណល(GTI)
- កំពង់ផែស្វយ័តភ្នំពេញ(PPAP)
- ក្រុមហ៊ុនភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី (PPSP)
- កំពង់ផែស្វយ័តក្រុងព្រះស៊ីហនុ (PAS)

ក្រុមហ៊ុនបោះផ្សាយមូលបត្របំណុលចំនួនបី

- ធនាគារហត្ថាកសិករលីមីតធីត
- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិល អូ អិល ស៊ី
- ធនាគារ វឌ្ឍនៈ អាស៊ីចំកាត់

### ៤.២.៥.១. ក្រុមហ៊ុនបោះផ្សាយមូលបត្រកម្មសិទ្ធិក្នុងទីផ្សារមូលបត្រកម្ពុជា

#### ៤.២.៥.១.១. រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (PWSA)

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ភ) ត្រូវបានបង្កើតឡើងជាគ្រឹះស្ថានសាធារណៈ ដែលមានលក្ខណៈសេដ្ឋកិច្ច ស្ថិតក្រោមច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ។ នាថ្ងៃទី១៨ ខែមេសា ឆ្នាំ ២០១២ (រ.ទ.ស.ភ) បានចុះបញ្ជីជាផ្លូវការនៅ ផ.ម.ក. ដោយបានបោះផ្សាយលក់មូលបត្រជាសាធារណៈចំនួន១៣.០៤៥.៩៧៥ ភាគហ៊ុន ដែលស្មើនឹង១៥% នៃចំនួនភាគហ៊ុនធម្មសរុប។[19]

*រូបភាព 7.- ស្លាកសញ្ញា PWSA*

| តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង | |
|---|---|
| ឈ្មោះក្រុមហ៊ុន | រដ្ឋាករទឹកស្វយ័ត ក្រុងភ្នំពេញ |
| ប្រភេទភាគហ៊ុន | ភាគហ៊ុនធម្មតា |
| ភាគហ៊ុនបោះផ្សាយ | ១៣.០៤៥.៩៧៥ |
| កាលបរិច្ឆេទធ្វើប៊ុកបៀលឌីង | ថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១២ ដល់ ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១២ |
| ចន្លោះថ្លៃក្នុងការធ្វើប៊ុកបៀលឌីង | ពី៤.០៥០រៀល ដល់៦.៣៥០រៀល |
| កាលបរិច្ឆេទធ្វើបរិវិសកម្ម | ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១២ ដល់ថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១២ |
| តម្លៃបោះផ្សាយលក់ជាសាធារណៈលើកដំបូង | ៦.៣០០រៀល |
| ក្រុមហ៊ុនធានាទិញមូលបត្រ | គុងយ៉ាង ស៊ីយូរីធី (ខេមបូឌា) ភីអិលស៊ី |

*តារាង 1.- តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង PWSA*

[19] នាយកដ្ឋានត្រួតពិនិត្យប្រតិបត្តិការមូលបត្រ, ២០១៨, *ព្រឹត្តិបត្រស្តីពីការជួញដូរមូលបត្រនៅទីផ្សារមូលបត្រកម្ពុជា ប្រចាំត្រីមាសទី១ ឆ្នាំ២០១៨ ចេញផ្សាយលេខ ០០១, ទំព័រទី២*

### ៤.២.៥.១.២. ក្រុមហ៊ុនហ្គ្រេនធ្វីន អ៊ិនធើណេសិនណាល (GTI)

ក្រុមហ៊ុន ហ្គ្រេនធ្វីនអ៊ីនធើណេសិនណល (ខាមបូឌា) ភីអិលស៊ី គឺជាក្រុមហ៊ុនផលិត សម្លៀកបំពាក់ ដែលបានបង្កើតឡើងក្នុងឆ្នាំ២០០៧។ នៅឆ្នាំ២០០៨ ក្រុមហ៊ុន ហ្គ្រេនធ្វីន បានទិញយកក្រុមហ៊ុន QMI Industrial Co., Ltd ដែលជារោងចក្រកាត់ដេរដ៏ធំមួយក្នុង ចំណោមរោងចក្រកាត់ដេរធំៗដំបូងបង្អស់ដែលបានធ្វើអាជីវកម្មនៅក្នុងប្រទេសកម្ពុជាក្នុងអំឡុងទសវត្សរ៍ឆ្នាំ ១៩៩០។ ក្រុមហ៊ុន ហ្គ្រេនធ្វីន គឺជារោងចក្រម៉ៅការបន្ត និងជារោងចក្រផលិតសម្លៀកបំពាក់ផ្ទាល់សម្រាប់នាំចេញ។ សព្វថ្ងៃផលិតផលរបស់ក្រុមហ៊ុនហ្គ្រេនធ្វីន រួមមានម៉ាកសម្លៀកបំពាក់កីឡាល្បីៗ ដូចជាម៉ាក Adidas, Reebok, Taylor Made, Salomon, New Balance (NB), Kohls, Nautica and North Face.[20]

*រូបភាព 8.- ស្លាកសញ្ញា GTI*

| តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង | |
|---|---|
| ឈ្មោះក្រុមហ៊ុន | ក្រុមហ៊ុន ហ្គ្រេនធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី |
| ប្រភេទភាគហ៊ុន | ភាគហ៊ុនធម្មតា |
| ភាគហ៊ុនបោះផ្សាយ | ៨.០០០.០០០ |
| កាលបរិច្ឆេទធ្វើប៊ុកបៀលឌីង | ថ្ងៃទី១៧ ដល់ ថ្ងៃទី២៨ ខែមិនា ឆ្នាំ២០១៤ |
| ចន្លោះថ្លៃក្នុងការធ្វើប៊ុកបៀលឌីង | ៧.៩០០ រៀល ដល់ ១៤.០០០ រៀល |
| កាលបរិច្ឆេទធ្វើបរិវិសកម្ម | ថ្ងៃទី២ ដល់ ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៤ |
| តម្លៃបោះផ្សាយលក់ជាសាធារណៈលើកដំបូង | ៩.៦៩០ រៀល |
| ក្រុមហ៊ុនធានាទិញមូលបត្រ | ភ្នំពេញ ស៊ីយូរីធី ភីអិលស៊ី |

*តារាង 2.- តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង GTI*

[20] នាយកដ្ឋានត្រួតពិនិត្យប្រតិបត្តិការមូលបត្រ, ២០១៨, *ព្រឹត្តិបត្រស្តីពីការជួញដូរមូលបត្រនៅទីផ្សារមូលបត្រកម្ពុជាប្រចាំត្រីមាសទី១ ឆ្នាំ២០១៨ ចេញផ្សាយលេខ ០០១, ទំព័រទី៣*

### ៤.២.៥.១.៣. កំពង់ផែស្វយ័តភ្នំពេញ (PPAP)

កំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ.) គឺជាប្រតិបត្តិករ មួយក្នុងចំណោមប្រតិបត្តិករកំពង់ផែកុងតឺន័រអន្តរជាតិ២នៅកម្ពុជា ហើយក៏ជាប្រតិបត្តិករកំពង់ផែទន្លេធំជាងគេបំផុត និងជាអាជ្ញាធរគ្រប់គ្រងផែនៅក្នុងមណ្ឌលអាជីវកម្មផែ។ មណ្ឌលអាជីវកម្មផែមានប្រវែង ១៦០ គីឡូម៉ែត្រ លាតសន្ធឹងពីខេត្តត្បូងឃ្មុំទៅដល់ព្រំប្រទល់ កម្ពុជា-វៀតណាម នៅឯក្អមសំណ។ នៅឆ្នាំ២០១៥ ក.ស.ភ. ទទួលបានសិទ្ធផ្តាច់មុខជាប្រតិបត្តិករកំពង់ផែ នៅក្នុងមណ្ឌលអាជីវកម្មផែ។ ក.ស.ភ. មានចំណតផែចម្បងៗចំនួន៤ គឺ៖ ទី១. ចំណតផែកុងតឺន័រ LM១៧, ទី២. ចំណតផែពហុបំណង TS៣, ទី៣. ចំណតផែអ្នកដំណើរ និងទេសចរណ៍ TS១, ទី៤. ចំណតផែទន្លេបិទ UM២។

*រូបភាព 9.- ស្លាកសញ្ញា PPAP*

| តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង | |
|---|---|
| ឈ្មោះក្រុមហ៊ុន | កំពង់ផែស្វយ័តភ្នំពេញ |
| ប្រភេទភាគហ៊ុន | ភាគហ៊ុនមានសិទ្ធិបោះឆ្នោត |
| ភាគហ៊ុនបោះផ្សាយ | ៤.១៣៦.៨៧៣ |
| កាលបរិច្ឆេទធ្វើប៊ុកបៀលឌីង | ថ្ងៃទី១៩ ដល់ ថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥ |
| ចន្លោះថ្លៃក្នុងការធ្វើប៊ុកបៀលឌីង | ៤.៨០៥ រៀល ដល់ ៦.៣២០ រៀល |
| កាលបរិច្ឆេទធ្វើបរិវិសកម្ម | ថ្ងៃទី១២ ដល់ ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៥ |
| តម្លៃបោះផ្សាយលក់ជាសាធារណៈលើកដំបូង | ៥.១២០ រៀល |
| ក្រុមហ៊ុនធានាទិញមូលបត្រ | យ៉ាន់តា ស៊ីយូរីធី (ខេមបូឌា) ភីអិលស៊ី |

*តារាង 3.- តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង PPAP*

### ៤.២.៥.១.៤. ក្រុមហ៊ុនភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី (PPSP)

រូបភាព 10.- ស្លាកសញ្ញា PPSP

ក្រុមហ៊ុនភ្នំពេញ អេសអ៊ីហ្សិតភីអិលស៊ី គឺជាអ្នកអភិវឌ្ឍ និងជាប្រតិបត្តិករនៃ តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ (“PPSEZ”) និង ប៉ោយប៉ែត ភីភី អេសអ៊ីហ្សិត (“Poipet PPSEZ”)។ នាថ្ងៃទី ១៩ ខែមេសា ឆ្នាំ២០០៦ ក្រុមហ៊ុនទទួលបានការអនុញ្ញាតពីរាជ-រដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា ដើម្បីក្លាយខ្លួនជាអ្នកអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស ដែលអាចធ្វើប្រតិបត្តិការអាជីវកម្មច្រើនប្រភេទ។ បច្ចុប្បន្ននេះ តំបន់សេដ្ឋកិច្ចពិសេស ដែលកំពុងធ្វើប្រតិបត្តិការ នៅជិតទីប្រជុំជននៃរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជាដែលមានអាជីវកម្មចម្បងក្នុងការអភិវឌ្ឍដីឧស្សាហកម្មសម្រាប់លក់ និង/ឬ ជួល។ ក្រុមហ៊ុនក៏មានផ្គត់ផ្គង់សេវាកម្មដែលពាក់ព័ន្ធនានា។ [21]

| តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង | |
|---|---|
| ឈ្មោះក្រុមហ៊ុន | ភ្នំពេញអេសអ៊ីហ្សិត ភីអិលស៊ី (ភីភីអេសភី) |
| ប្រភេទភាគហ៊ុន | ភាគហ៊ុនមានសិទ្ធិបោះឆ្នោត |
| ភាគហ៊ុនបោះផ្សាយ | ១១.៥៧៥.០០០ |
| កាលបរិច្ឆេទធ្វើប៊ុកបៀលឌីង | ថ្ងៃទី១៨ ដល់ ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៦ |
| ចន្លោះថ្លៃក្នុងការធ្វើប៊ុកបៀលឌីង | ២.៨០០រៀល ដល់ ៤.០០០រៀល |
| កាលបរិច្ឆេទធ្វើបរិវិសកម្ម | ថ្ងៃទី៩ ដល់ ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៦ |
| តម្លៃបោះផ្សាយលក់ជាសាធារណៈលើកដំបូង | ២.៨៦០ រៀល |
| ក្រុមហ៊ុនធានាទិញមូលបត្រ | អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីយ្យូរីធី កម្ពុ ស៊ីយ្យូរីធី និងកាណា ស៊ីយ្យូរីធី |

*តារាង 4.- តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង PPSP*

[21] នាយកដ្ឋានត្រួតពិនិត្យប្រតិបត្តិការមូលបត្រ,២០១៨, *ព្រឹត្តិបត្រស្តីពីការជួញដូរមូលបត្រនៅទីផ្សារមូលបត្រកម្ពុជាប្រចាំត្រីមាសទី១ ឆ្នាំ២០១៨ ចេញផ្សាយលេខ ០០១, ទំព័រទី៥*

#### ៤.២.៥.១.៥. កំពង់ផែស្វយ័តក្រុងព្រះសីហនុ (PAS)

កំពង់ផែស្វយ័តក្រុងព្រះសីហនុ (ក.ស.ស) ជាក្រុមហ៊ុនរដ្ឋ ដែលបានបង្កើតឡើង ដើម្បីធ្វើអាជីវកម្មសេវាកម្មមូលដ្ឋានលើការងារៈ កណ្ដាធារកិច្ច នាំនាវាចេញ-ចូល និងផ្ដល់ភស្ដុភារដល់នាវា, លើកដាក់ ផ្ទេរ ផ្ទុកទំនិញ, ស្ដុកទំនិញនៅឃ្លាំង និងទីលានព្រមទាំងដឹកជញ្ជូនទំនិញ។ បច្ចុប្បន្ន ក.ស.ស ក៏កំពុងផ្ដល់សេវាកម្មផ្សេងទៀតៈ សេវាក្នុងតំបន់សេដ្ឋកិច្ចពិសេស ដូចជាជួលឃ្លាំងនិងថែរក្សាទំនិញ លើកដាក់ និងដឹកជញ្ជូនទំនិញ រួមទាំងសេវាសន្តិសុខក្នុងកំពង់ផែ និងតំបន់សេដ្ឋកិច្ចពិសេស។ **ក.ស.ស** ជាកំពង់ផែអន្តរជាតិសមុទ្រទឹកជ្រៅតែមួយគត់នៅកម្ពុជា ដែលកំពុងធ្វើអាជីវកម្មលើផ្ទៃដីទំហំប្រមាណ ១២៥ហិចតា នៅខេត្តព្រះសីហនុ ហើយត្រូវបានតភ្ជាប់ដោយបណ្ដាញដឹកជញ្ជូនចំរុះ រួមមាន បណ្ដាញផ្លូវគោក បណ្ដាញផ្លូវរថភ្លើង និងបណ្ដាញផ្លូវអាកាស ។[22]

*រូបភាព 11.- ស្លាកសញ្ញា PAS*

| តារាងសង្ខេបលទ្ធនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង | |
|---|---|
| ឈ្មោះក្រុមហ៊ុន | កំពង់ផែស្វយ័តក្រុងព្រះសីហនុ |
| ប្រភេទភាគហ៊ុន | ភាគហ៊ុនមានសិទ្ធិបោះឆ្នោត |
| ភាគហ៊ុនបោះផ្សាយ | ២១.៤៤២.៩៩២ |
| កាលបរិច្ឆេទធ្វើប៊ុកបៀលឌីង | ថ្ងៃទី២៥ មេសា ដល់ ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៧ |
| ចន្លោះថ្លៃក្នុងការធ្វើប៊ុកបៀលឌីង | ៣.៥២០រៀល ដល់ ៥.១៨០រៀល |
| កាលបរិច្ឆេទធ្វើបរិវិសកម្ម | ថ្ងៃទី១៧ ដល់ ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៧ |
| តម្លៃបោះផ្សាយលក់ជាសាធារណៈលើកដំបូង | ៥.០៤០ រៀល |
| ក្រុមហ៊ុនធានាទិញមូលបត្រ | អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីយូរីធី |

*តារាង 5.- តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង PAS*

[22] នាយកដ្ឋានត្រួតពិនិត្យប្រតិបត្តិការមូលបត្រ,២០១៨, *ព្រឹត្តិបត្រស្តីពីការជួញដូរមូលបត្រនៅទីផ្សារមូលបត្រកម្ពុជា ប្រចាំត្រីមាសទី១ ឆ្នាំ២០១៨ ចេញផ្សាយលេខ ០០១, ទំព័រទី៦*

### ៤.២.៥.២. ក្រុមហ៊ុនបោះផ្សាយមូលបត្របំណុលក្នុងទីផ្សារមូលបត្រកម្ពុជា

#### ៤.២.៥.២.១. ធនាគារហត្ថាកសិករលីមីតធីត

ហត្ថាកសិករ គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើសន្សំពីសារណៈជនធំមួយដែលបានទទួលបានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា និងបានធ្វើប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជាជាង ២៥ឆ្នាំ មកហើយ។ ហត្ថាកសិករ បាននឹងកំពុងផ្តល់សេវាកម្មហិរញ្ញវត្ថុយ៉ាងសម្បូរបែបដល់អតិថិជនដូចជា៖ សេវាឥណទាន សេវាប្រាក់បញ្ញើសន្សំ សេវាផ្ទេរប្រាក់ក្នុងស្រុក សេវាATM សេវាធនាគារចល័ត សេវាបើកប្រាក់បៀវត្ស និងជាភ្នាក់លក់សេវាធានារ៉ាប់រងផងដែរ។ តាមរយៈសាខាចំនួន ១៧៧ និងម៉ាស៊ីនអេធីអឹមចំនួន ១២៩ គ្រឿងនៅទូទាំងប្រទេស។ គិតត្រឹមខែមិថុនា ឆ្នាំ ២០១៩ សមតុល្យប្រាក់បញ្ញើសន្សំរបស់ហត្ថាកសិករ មានចំនួនជាង ៥៦៣ លានដុល្លារអាមេរិក ជាមួយនឹងចំនួនអតិថិជន ប្រាក់បញ្ញើសន្សំជាង ២១៣,៩៥១ នាក់ ផលប័ត្រឥណទានសរុបមានចំនួនប្រមាណ ៨៨១ លានដុល្លារអាមេរិក និងមានអតិថិជនខ្ចីប្រាក់ចំនួន ១៩០,៨២០ នាក់។

បច្ចុប្បន្ន ហត្ថាកសិករ លីមីតធីត គឺជាបុត្រសម្ព័ន្ធរបស់ធនាគារក្រុងស្រី ដែលជាធនាគារពាណិជ្ជធំជាងគេលំដាប់ទី ៥ នៅព្រះរាជាណាចក្រថៃឡង់ន៍ និងជាសមាជិករបស់សម្ព័ន្ធហិរញ្ញវត្ថុអន្តរជាតិ Mitsubishi UFJ Financial Group (MUFG) ដែលជាសម្ព័ន្ធធនាគារធំជាងគេបំផុតនៅប្រទេសជប៉ុន ព្រមទាំង ជាសម្ព័ន្ធសេវាហិរញ្ញវត្ថុដ៏ធំមួយក្នុងចំណោមសម្ព័ន្ធហិរញ្ញវត្ថុធំជាងគេលើសកលលោក។

| និមិត្តសញ្ញាក្រុមហ៊ុនចុះបញ្ជី | ព័ត៌មានសង្ខេបរបស់ក្រុមហ៊ុនចុះបញ្ជី |
|---|---|
| HKL<br>ភាពវិនិច្ឆ័យ ភាពរីកចំរើន<br>ហត្ថាកសិករ លីមីតធីត<br>HATTHA KAKSEKAR LIMITED | ▪ អ្នកបោះផ្សាយ៖ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ លីមីតធីត (HKL21A)<br>▪ ចំណាត់ថ្នាក់លទ្ធភាពសង៖ BBB+<br>▪ ចំនួនបោះផ្សាយមូលបត្របំណុល (ឯកតា)៖ 1,200,000<br>▪ តម្លៃចារឹកនៃមូលបត្របំណុល៖ 100,000<br>▪ អត្រាគូប៉ុង (%)៖ 8.50% (ប្រចាំឆ្នាំ)<br>▪ ចំនួននៃការទូទាត់៖ ប្រចាំឆមាស<br>▪ កាលបរិច្ឆេទទូទាត់៖ 14/05, 14/11<br>▪ រយៈពេលឥណប្រតិទាន (ឆ្នាំ)៖ 3 ឆ្នាំ<br>▪ ឥណប្រតិទាន៖ 14/11/2021 |

*តារាង 6.- តារាងព័ត៌មានសង្ខេបរបស់ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្របំណុល HKL*

### ៤.២.៥.២.២. គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិល អូ អិល ស៊ី

អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ស្ថិតនៅលំដាប់ទី៤ (គិតលើចំនួនអតិថិជន និងផលប័ត្រឥណទាន) ក្នុងចំណោមគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលធំបំផុតនៅក្នុងប្រទេសកម្ពុជា។ អិលអូអិលស៊ីត្រូវបានបង្កើតឡើងដោយអង្គការ Catholic Relief Services ហៅកាត់ថា ("CRS") ក្នុងឆ្នាំ១៩៩៤ ដើម្បីជម្រុញលើកទឹកចិត្តឱ្យស្ត្រីនៅជនបទទទួលបាននូវសេវាហិរញ្ញវត្ថុដែលពួកគាត់អាចប្រើប្រាស់សម្រាប់សហគ្រាសខ្នាតតូចរបស់ពួកគាត់។ នៅឆ្នាំ១៩៩៩ អិលអូអិលស៊ី គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទីមួយនៅក្នុងប្រទេសកម្ពុជា ដែលទទួលបានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ដោយមានឈ្មោះថា "ធនាគារភូមិ (ខេមបូឌា) អិលធីឌី"។ នៅខែមករា ឆ្នាំ២០១០ Developing World Markets ("DWM") គឺជាក្រុមហ៊ុនគ្រប់គ្រងមូលនិធិទីផ្សារដែលមានសក្តានុពល ទទួលខុសត្រូវផ្នែកសង្គមមួយ ដែលមានទីតាំងនៅសហរដ្ឋអាមេរិកបានទិញយកភាគហ៊ុនដែលមាន សម្លេងលើសលប់នៅក្នុងធនាគាភូមិ ពីអង្គការ ("CRS")។ ជាមួយនឹងបទពិសោធន៍ជាង១៥ឆ្នាំ និងទ្រព្យសកម្មក្រោមការគ្រប់គ្រងសរុបចំនួនប្រមាណ ៧៦០លានដុល្លារអាមេរិក ព្រមទាំងការ យកចិត្តទុកដាក់ និងស្តង់ដាខ្ពស់របស់ DWM បានជម្រុញឱ្យធនាគារភូមិមានភាពប្រសើរនូវនិតិវិធី និងប្រតិបត្តិការរបស់ខ្លួន។ ដោយធនាគារភូមិមានការរីកចម្រើនយ៉ាងឆាប់រហ័ស ក្រុមហ៊ុន LOLC Micro Investment Ltd. ("LOMI") បានចាប់អារម្មណ៍បណ្តាក់ទុនវិនិយោគជាមួយធនាគារភូមិ និងបានកាន់កាប់ភាគហ៊ុនច្រើនលើសលុបនៅធនាគារភូមិ។ ក្នុងឆ្នាំ២០១៥ ធនាគារភូមិ (ខេមបូឌា) អិលធីឌី បានផ្លាស់ប្តូរឈ្មោះ ទៅជា អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី និងទទួលបានអាជ្ញាប័ណ្ណប្រកបអាជីវកម្មទទួលប្រាក់បញ្ញើពីធនាគារជាតិនៃកម្ពុជា នៅក្នុងឆ្នាំនោះដែរ។ ក្នុងឆ្នាំ២០១៨ ក្រុមហ៊ុន LOLC Private Limited ដែលជាក្រុមហ៊ុនចុះបញ្ជីក្នុងប្រទេសសិង្ហបុរីកាន់កាប់ភាគហ៊ុនច្រើនលើសលុបនៅអិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី ពី DWM និង LOMI ។ បច្ចុប្បន្ននេះ LOLC Private Limited កាន់កាប់ភាគហ៊ុនចំនួន ៩៦,៩៧% នៃចំនួនហ៊ុនសរុប ហើយភាគហ៊ុនដែលនៅសល់ ត្រូវបានកាន់កាប់ដោយក្រុមហ៊ុនបុគ្គលិកអិលអូអិលស៊ី ហៅកាត់ថា ធីភីស៊ី-អ៊ីសប Employee Stock Ownership Plan ("TPC-ESOP")។

| | |
|---|---|
| | ▪ ឈ្មោះមូលបត្របំណុល៖ សញ្ញាបណ្ណ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី មានការការពារហានិភ័យអត្រាប្តូរប្រាក់ ២០១៩-២០២២ (Fx-indexed Bond 2019-2022 No.1)<br>▪ អ្នកបោះផ្សាយ៖ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិល អូ អិល ស៊ី (LOLC22A)<br>▪ ចំណាត់ថ្នាក់លទ្ធភាពសង៖ N/A<br>▪ ចំនួនបោះផ្សាយមូលបត្របំណុល (ឯកតា)៖ 536,000<br>▪ តម្លៃចារឹកនៃមូលបត្របំណុល៖ 100,000 រៀល<br>▪ អត្រាគូប៉ុង (%)៖ 8.00% (ប្រចាំឆ្នាំ)<br>▪ រយៈពេលឥណប្រតិទាន (ឆ្នាំ)៖ 3 ឆ្នាំ<br>▪ ឥណប្រតិទាន៖ 26/04/2022 |
| | ▪ ឈ្មោះមូលបត្របំណុល៖ សញ្ញាបណ្ណ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី ២០១៩-២០២២ (Plain Bond 2019-2022 No.2)<br>▪ អ្នកបោះផ្សាយ៖ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិល អូ អិល ស៊ី (LOLC22B)<br>▪ ចំណាត់ថ្នាក់លទ្ធភាពសង៖ N/A<br>▪ ចំនួនបោះផ្សាយមូលបត្របំណុល (ឯកតា)៖ 264,000<br>▪ តម្លៃចារឹកនៃមូលបត្របំណុល៖ 100,000 រៀល<br>▪ អត្រាគូប៉ុង (%)៖ 9.00% (ប្រចាំឆ្នាំ)<br>▪ រយៈពេលឥណប្រតិទាន (ឆ្នាំ)៖ 3 ឆ្នាំ<br>▪ ឥណប្រតិទាន៖ 26/04/2022 |

*តារាង 7.- តារាងព័ត៌មានសង្ខេបរបស់ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្របំណុល LOLC*

### ៤.២.៥.២.៣. ធនាគារ វឌ្ឍនៈ អាស៊ីចំកាត់

ធនាគារ វឌ្ឍនៈ អាស៊ីចំកាត់ (អេ ប៊ី អេ) គឺជាគ្រឹះស្ថានហិរញ្ញវត្ថុឯកជនឈានមុខមួយរបស់កម្ពុជា (សហគ្រាសឯកជន) ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ1996 មានឈ្មោះថា ធនាគារវឌ្ឍនៈ អាស៊ី ចំកាត់។ ឆ្លងកាត់ការអភិវឌ្ឍនិងកំណើនជាង 20ឆ្នាំកន្លងមកនេះ ABA បានពង្រឹងជំហាររបស់ខ្លួនយ៉ាងរឹងមាំក្នុងទីផ្សារ និងក្លាយជាធនាគារមួយក្នុងចំណោមធនាគារពាណិជ្ជកំពូលទាំងបី នៅក្នុងប្រទេស។ សព្វថ្ងៃនេះ ABA មានបម្រើសេវាជូនដល់បណ្តាអតិថិជនជាច្រើនដូចជា សហគ្រាសធុនតូចនិងមធ្យម, អាជីវកម្មខ្នាតតូច, រូបវន្តបុគ្គល និងមានសាខាចំនួន 78, ម៉ាស៊ីនស្វ័យសេវាជាង 200, ម៉ាស៊ីន ATM ជាង 354 ទូទាំងប្រទេស, សេវាធនាគារអនឡាញ និងធនាគារតាមទូរស័ព្ទដ៏ទំនើប ធ្វើឲ្យធនាគារ ABA អាចបម្រើអតិថិជនបានកាន់តែច្រើនឡើងៗជាមួយសេវាហិរញ្ញវត្ថុដ៏ទំនើបសម្បូរបែបនេះ។

ធនាគារ ABA គឺជាបុត្រសម្ពន្ធរបស់ធនាគារជាតិកាណាដា (www.nbc.ca) ដែលជាគ្រឹះស្ថានហិរញ្ញវត្ថុមួយ មានទ្រព្យសកម្មជាង 218.9 ប៊ីលានដុល្លារអាមេរិក គិតត្រឹមថ្ងៃទី31 ខែមករា ឆ្នាំ 2020 និងមានបណ្តាញធនាគារសម្ពន្ធហិរញ្ញវត្ថុនៅទូទាំងពិភពលោក។

| | |
|---|---|
| ABA BANK<br>NATIONAL BANK OF CANADA GROUP | ▪ ឈ្មោះមូលបត្របំណុល៖ សញ្ញាបណ្ណសាជីវកម្ម អេ ប៊ី អេ (ABA Bond)<br>▪ អ្នកបោះផ្សាយ៖ ធនាគារ វឌ្ឍនៈ អាស៊ីចំកាត់<br>▪ ចំណាត់ថ្នាក់លទ្ធភាពសង៖ B (វាយតម្លៃដោយ S&P Global Ratings)<br>▪ ចំនួនបោះផ្សាយមូលបត្របំណុល (ឯកតា)៖ 848,210<br>▪ តម្លៃចារឹកនៃមូលបត្របំណុល៖ 100,000 រៀល<br>▪ អត្រាគូប៉ុង (%)៖ 7.75% (ប្រចាំឆ្នាំ)<br>▪ រយៈពេលឥណប្រតិទាន (ឆ្នាំ)៖ 3 ឆ្នាំ<br>▪ ឥណប្រតិទាន៖ 14/08/2022 |

*តារាង 8.- តារាងព័ត៌មានសង្ខេបរបស់ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្របំណុល ABA*

### ៤.២.៦. វិនិយោគិន

វិនិយោគិនធម្មតា គឺសំដៅលើសាធារណៈជននៅក្នុងប្រទេសកម្ពុជា រួមទាំងរូបវន្តបុគ្គល និង នីតិបុគ្គលដែលមានសិទ្ធទិញឬលក់មូលបត្រដែលបានបោះផ្សាយ និងធ្វើសំណើរលក់ជាសាធារណៈក្នុងប្រទេសកម្ពុជា ដោយក្រុមមូលបត្រមហាជនទទួលខុសត្រូវមានកម្រិត ឬក៏នីតិបុគ្គលប្រតិស្រុត ដែលមិនមែនជាសមាការី ឬក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬនីតិបុគ្គលពាក់ព័ន្ធរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុតនោះ[23]។ វត្តមាននៃទីផ្សារមូលបត្រនៅ កម្ពុជាបានអនុញ្ញាតវិនិយោគិន ដែលមានធនធាន (សាច់ប្រាក់) នៅទំនេរទៅវិនិយោគតាមរយៈការទិញមូលបត្របោះផ្សាយ ដោយក្រុមហ៊ុនបោះផ្សាយនៅលើទីផ្សារដើម្បីទទួលបាននូវផលចំណេញ ដូចជា ភាគលាភ ការប្រាក់ ឬការចំណេញជាមូលធន ជាជាងការទុកឱ្យនៅទំនេរចោល។

## ៤.៣. ការត្រៀមខ្លួនរបស់វិនិយោគិន

- **គោលបំណងវិនិយោគ** ៖ វិនិយោគិនអាចប្រឹក្សាជាមួយក្រុមហ៊ុនទីប្រឹក្សាវិនិយោគដែលមានបទពិសោធន៍ និងគុណវុឌ្ឍិ ដើម្បីជួយបង្កើតនូវគោលបំណងវិនិយោគ ឬ ធ្វើការសាកល្បងលើយោបល់របស់ក្រុមហ៊ុនទាំងនោះ។ ការប្រឹក្សានេះអាចជួយឲ្យវិនិយោគិនវាយតម្លៃលើគោលបំណងដែលអាចទុកចិត្តបាន និងកម្រិតហានិភ័យដែលនឹងអាចកើតមានក្នុងការវិនិយោគនេះ។ វិនិយោគិនគួរពិចារណាជាមុនលើកត្តាហានិភ័យ និងគម្រោងវិនិយោគមុនពេលសំរេចចិត្តក្នុងការវិនិយោគលើ អ្វីមួយដូចខាងក្រោម៖

ក. វិនិយោគិនគប្បីចោទសួរនូវសំណួរដូចជា៖

- តើអ្វីទៅជាគោលបំណងនៃការវិនិយោគរបស់អ្នក?
- តើថវិកាចំនួនប៉ុន្មានដែលអ្នកគួរតែធ្វើការវិនិយោគ?
- តើអ្នកគួរវិនិយោគនៅកន្លែងណា? ទីផ្សារមូលបត្រ ដាក់ប្រាក់បញ្ញើនៅធនាគារ ឬការវិនិយោគលើអចលនទ្រព្យជាដើម។

ខ. វិនិយោគិនគួរពិចារណាលើពាក្យស្លោក ដែលបានលើកឡើងថា ៖

- ការវិនិយោគដែលមានហានិភ័យខ្ពស់ នោះប្រាក់ចំណេញអាចទទួលបានក៏ខ្ពស់ដែរ (High risk, high return)

[23] ប្រកាសស្តីពីកាផ្តល់អាជ្ញាបណ្ណដល់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រ,លេខ ០០៩ គ.ម.ក. ១៩ វិច្ឆិកា ២០០៩ , ទំព័រ ៥។

- ○ គួរកុំប្រថុយវិនិយោគលើគម្រោងវិនិយោគតែមួយ (Don't put all your eggs in one basket)
- ○ សាច់ប្រាក់អាចបង្កើតសាច់ប្រាក់បាន (Money makes Money)

- **លេខអត្តសញ្ញាណវិនិយោគិន**៖វិនិយោគិនអាចស្នើសុំលេខអត្តសញ្ញាណវិនិយោគិនដោយផ្ទាល់នៅ **គ.ម.ក.** ឬតាមរយៈក្រុមហ៊ុនមូលបត្រ។ លេខអត្តសញ្ញាណវិនិយោគិនមាន សុពលភាពរយៈពេល១០ឆ្នាំ ហើយវិនិយោគិនអាចស្នើសុំបន្តលេខអត្តសញ្ញាណវិនិយោគិន មុនពេលអស់សុពលភាព៣ខែ។ ទម្រង់លេខអត្តសញ្ញាវិយោគិនមាន ១២ ខ្ទង់ ផ្តើមដោយអក្សរ D សម្រាប់វិនិយោគិនជនជាតិខ្មែរ និង F សម្រាប់វិនិយោគិនជនជាតិបរទេស។ ឧទាហរណ៍ : D12345678901 ឬ F12345678901។ ដើម្បីទទួលបានអត្តសញ្ញាណវិនិយោគិន ដោយវិនិយោគិនម្នាក់ អាចមានលេខអត្តសញ្ញាណវិនិយោគបានតែមួយប៉ុណ្ណោះ ហើយវិនិយោគិនទាំងអស់ចាំបាច់ត្រូវតែមានលេខអត្តសញ្ញាណវិនិយោគិន ទើបអាចធ្វើការជួញដូរមូលបត្របាន។ កម្រៃនៃការដាក់ស្នើសុំលេខអត្តសញ្ញាណវិនិយោគិន ចំពោះរូបវន្តបុគ្គល ២,០០០ រៀល និងចំពោះនីតិបុគ្គល ៥០,០០០ រៀល។ រីឯការដាក់ពាក្យស្នើវិនិយោគិនចំពោះរូបវន្តបុគ្គលត្រូវភ្ជាប់មកជាមួយនូវ អត្តសញ្ញាណប័ណ្ណ លិខិត ឆ្លងដែន និងរូបថត៤x៦ មួយសន្លឹក។ ចំពោះនីតិបុគ្គលត្រូវថតចំលងវិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុន និងអាជ្ញាបណ្ណជាដើម។
- **ការជ្រើសរើសក្រុមហ៊ុនមូលបត្រ** ៖ វិនិយោគិនអាចជ្រើសរើសក្រុមហ៊ុនមូលបត្រដែលខ្លួនពេញចិត្ត និងការពិចារណាលើកត្តាមួយចំនួនដូចជា សេវាកម្ម ថ្លៃកម្រៃជើងសា និង សិទ្ធិព្រមទាំងកាតព្វកិច្ចរបស់អតិថិជនក្នុងកិច្ចព្រមព្រៀងរវាង វិនិយោគិន និងក្រុមហ៊ុនមូលបត្រ។ វិនិ-យោគិនត្រូវជ្រើសរើសក្រុមហ៊ុនមូលបត្រ ដែលជាសមាជិករបស់ **ផ.ម.ក.** ដើម្បីជាអ្នកតំណាងរបស់ខ្លួនក្នុងការជួញដូរមូលបត្រមានដូចជា៖

១. ក្រុមហ៊ុនធានាទិញមូលបត្រ (Securities Underwriter/6SF) មាន៖

- ភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី / Phnom Penh Securities Plc.
- អ អេច ប៊ី ឥណ្ឌូឆៃណា ស៊ីឃ្យូរីធី ម.ក / RHB Securities (Cambodia) PLC.
- កាណា ស៊ីឃ្យូរីធី អិលធីឌី / Cana Securities Ltd.
- កម្ពុ ស៊ីឃ្យូរីធី ភីអិលស៊ី / Campu Securities Plc.
- យាន់តា ស៊ីឃ្យូរីធី (ខេមបូឌា) ភីអិលស៊ី / Yuanta Securities (Cambodia) Plc.
- អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីឃ្យូរីធី។ SBI Royal Securities Plc.

២. ក្រុមហ៊ុនពាណិជ្ជករមូលបត្រ (Securities Dealer/1SF) មាន៖

- ហ្គោលដេន ហ្វ័រឈូន (ខេមបូឌា) ស៊ីឃ្យូរីធី ភីអិលស៊ី / Golden Fortune (Cambodia)

៣. ក្រុមហ៊ុនឈ្មួញជើងសាមូលបត្រ (Securities Broker/3SF)

- ខេមបូឌា - វៀតណាម ស៊ីឃ្យូរីធី ភីអិលស៊ី / Cambodia-Vietnam Securities Co., Ltd.
- អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី / ACLEDA Securities Plc.
- ខេប ស៊ីឃ្យូរីធី លីមីធីត / CAB Securities Limited

៤. ក្រុមហ៊ុនផ្តល់ប្រឹក្សាវិនិយោគ (Investment Advisor/2SF)

- អេភី អិម (ខេមបូឌា) ស៊ីឃ្យូរីធី ឯ.ក APM (CAMBODIA) SECURITIES CO., LTD.

• **ការបើកគណនីសាច់ប្រាក់ និងគណនីមូលបត្រ** : វិនិយោគិនអាចបើកគណនីជួញដូរបានតែមួយប៉ុណ្ណោះចំពោះក្រុមហ៊ុនមូលបត្រមួយ។ ក្រុមហ៊ុនមូលបត្រដែលកំពុងដំណើរការបច្ចុប្បន្នដែលជាសមាជិករបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាចំនួន១១ក្រុមហ៊ុន។ ដូច្នេះវិនិយោគិនអាចបើកគណនីជួញដូរអតិបរមាចំនួនដប់មួយ ប៉ុន្តែវិនិយោគិនមិនគួរបើកគណនីច្រើនពេកនោះទេ វិនិ-យោគិនគួរជ្រើសរើសក្រុមហ៊ុនមូលបត្រពីរ ឬ បីទៅតាមតម្រូវការផ្ទាល់ខ្លួន ដោយផ្អែកលើគុណភាពសេវាកម្ម ចំនួនសេវាកម្ម និងកម្រៃសេវាជាដើម។ នៅពេលដែលជ្រើសរើសក្រុមហ៊ុនមូលបត្រដែលជាភ្នាក់ងារបម្រើសេវាកម្មមូលបត្ររួចហើយ វិនិយោគិនត្រូវអញ្ជើញទៅក្រុមហ៊ុនមូលបត្រនោះដោយយកទៅជាមួយនូវ ៖ អត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែន សម្រាប់ជនបរទេស និង រូបថត៤x៦ និង ចំពោះនិតិបុគ្គល ត្រូវថតចំលងវិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុន និងអាជ្ញា បណ្ណជាដើម។ ការបើកគណនីជួញដូរគឺសំដៅលើការបើកគណនីមូលបត្រ និងគណនីសាច់ប្រាក់នៅក្រុមហ៊ុនមូលបត្រដែលយើងជ្រើសរើស។ វិនិយោគិនមានគណនីមូលបត្រ ដោយមូលបត្រទាំងនេះត្រូវបានបម្លែងជាតួលេខ កត់ត្រាក្នុងប្រព័ន្ធកុំព្យូទ័រ ដូចការបម្លែងក្រដាសប្រាក់ទៅជាតួលេខកត់ត្រា ក្នុងប្រព័ន្ធកុំព្យូទ័រតាមធនាគារផងដែរ។ ចំណែកឯគណនីសាច់ប្រាក់វិញ វិនិយោគិនអាចយកសាច់ប្រាក់ទៅបញ្ចូលក្នុងគណនីនោះ ឬអាចផ្ទេរពីគណនីសាច់ប្រាក់ផ្ទាល់ខ្លួនទៅកាន់គណនីសាច់ប្រាក់សម្រាប់ការជួញដូរមូលបត្រនេះបាន។ ពេលដែលគណនីជួញដូរមានដំណើរការហើយ វិនិយោគិនអាចទិញ-លក់ភាគហ៊ុននៃក្រុមហ៊ុនដែលបានចុះបញ្ជីនៅ **ផ.ម.ក.** តាមរយៈក្រុមហ៊ុនមូលបត្រដែលខ្លួនបានបើកគណនីជួញដូរ។ វិនិយោគិនអាចបង្គាប់ទៅក្រុមហ៊ុន

មូលបត្រដើម្បីទិញ ឬលក់មូលបត្រណាមួយ តាមរយៈការអញ្ជើញទៅក្រុមហ៊ុនមូលបត្រនោះដោយផ្ទាល់ ឯកសារជាលាយលក្ខណ៍អក្សរ តាមរយៈទូរស័ព្ទ ពាក្យសំដី សារអេឡិចត្រូនិច ឬមធ្យោបាយផ្សេងទៀតដែលផ្តល់ដោយក្រុមហ៊ុនមូលបត្រ នូវពត៌មានចំនួន៤គឺ

១. ឈ្មោះមូលបត្រ

២. បរិមាណ

៣. ថ្លៃ

៤. ប្រភេទនៃបញ្ជាទិញ ឬបញ្ជាលក់។

## ៤.៤. ដំណើរការជួញដូរមូលបត្រនៅទីផ្សារមូលបត្រ

ដំណើរការជួញដូរមូលបត្រ នៅផ្សារមូលបត្រកម្ពុជាត្រូវបានប្រព្រឹត្តទៅជា ពីរដំណាក់កាលគឺ ការជួញដូរក្នុងទីផ្សារដំបូង និងនៅក្នុងទីផ្សារបន្ទាប់។

### ៤.៤.១. ដំណើរការជួញដូរនៅទីផ្សារដំបូង

ការជួញដូរនៅក្នុងទីផ្សារដំបូង កើតមានឡើងម្តងម្កាលតែប៉ុណ្ណោះ គឺនៅពេលដែលមានក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង។ សម្រាប់វិនិយោគិនណាដែលមានបំណងចង់វិនិយោគ ឬទិញមូលបត្រ ត្រូវតែធ្វើការទិញដោយផ្ទាល់ពីក្រុមហ៊ុនបោះផ្សាយតាមរយៈឈ្មួញជើងសារ។ ការជួញដូរនៅលើផ្សារដំបូងនេះត្រូវបានគេបែងចែកជា ២ ដំណាក់កាលទៀតគឺ ការធ្វើប៊ុក បៀលឌីង (Book Building) និងការធ្វើបរិវិសកម្ម (Subscription) ។

#### ៤.៤.១.១. ការធ្វើ ប៊ុក បៀលឌីង

ប៊ុក បៀលឌីង (Book Building) គឺជាដំណើរការស្ទាបស្ទង់ថ្លៃ ដើម្បីកំណត់ថ្លៃធ្វើសំណើលក់លើកដំបូង (Initial Public Offering)។ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ដែលបានធ្វើការកំណត់ចន្លោះថ្លៃមួយ ដើម្បីដាក់ស្នើឲ្យវិនិយោគិនសាធារណៈដាក់ថ្លៃទិញមូលបត្រនៅក្នុងចន្លោះថ្លៃនោះ។ វិនិយោគិនទាំងឡាយណាដែលមានបំណងចង់ចូលរួមក្នុងវគ្គ ប៊ុកបៀលឌីង នេះត្រូវទៅក្រុមហ៊ុនធានាទិញ ឬក្រុមហ៊ុនមូលបត្រដែលពាក់ព័ន្ធ ហើយបំពេញពាក្យស្នើសុំចូលរួមធ្វើ ប៊ុក បៀលឌីង ដោយត្រូវបញ្ជាក់ពីថ្លៃមូលបត្រ និងបរិមាណមូលបត្រដែលខ្លួនចង់ទិញ និងត្រូវតម្កល់ប្រាក់ ១០% នៃតម្លៃភាគហ៊ុនដែលខ្លួនចង់ទិញ។ នៅក្នុងនេះដែរ វិនិយោគិនមានសិទ្ធិអាចដាក់ថ្លៃភាគហ៊ុននៅក្នុងចន្លោះថ្លៃដែលបានកំណត់តែប៉ុណ្ណោះ ។ នៅក្នុងដំណាក់កាលនៃការធ្វើប៊ុក បៀលឌីងនេះ ដើម្បីជំរុញឲ្យមានវិនិយោគិនចូលរួមយ៉ាងសកម្មនោះ ចំនួនមូលបត្រដែលដាក់លក់មានដល់ទៅ ៧០% នៃមូលបត្រសរុបដែលនៅសល់បន្ទាប់ពី

ការលៃបម្រុងទុកសម្រាប់លក់ជូនឲ្យទៅបុគ្គលិកនិយោជិត និងវិនិយោគិនសក្តានុពលទៅតាមគោលការណ៍របស់ក្រុមហ៊ុនបោះផ្សាយនីមួយៗ។ សម្រាប់ចំណែកដែលនៅសល់ ៣០% ទៀតនោះ គឺត្រូវបានលៃបម្រុងទុកសម្រាប់ការលក់ជូនវិនិយោគិនដែលមិនបានចូលរួមក្នុងវគ្គប៊ុក បៀលឌីង ឬក៏មិនទទួលបានជោគជ័យនៅក្នុងវគ្គប៊ុក បៀលឌីង។ ចំនួនមូលបត្រអប្បបរមាដែលវិនិយោគិនត្រូវធ្វើការស្នើទិញគឺ ១,០០០ ហ៊ុន។ ក្រោយពេលបញ្ចប់ដំណាក់កាលប៊ុក បៀលឌីងនេះក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញត្រូវធ្វើការកំណត់ថ្លៃ IPO តាមវិធីរកមធ្យមភាគលើមូលដ្ឋានថ្លៃ និងចំនួនមូលបត្រ។ រយៈពេលប្រហែលពីរសប្តាហ៍ក្រោយ ក្រុមហ៊ុនបោះផ្សាយនឹងប្រកាសលទ្ធផល ប៊ុក បៀលឌីងជាសាធារណៈ ដែលនៅក្នុងនោះមានការបង្ហាញពីថ្លៃ IPO។ ក្រុមហ៊ុននឹងធ្វើការជូនដំណឹងដោយបញ្ជាក់ថាតើ វិនិយោគិនណា ដែលទទួលបានជោគជ័យនៅក្នុងវគ្គប៊ុក បៀលឌីងនេះ។ វិនិយោគិនដែលទទួលបានជោគជ័យ សំដៅទៅដល់អ្នកដែលដាក់ថ្លៃខ្ពស់ជាង ឬស្មើថ្លៃមូលបត្រដែលត្រូវបានកំណត់សម្រាប់ធ្វើសំណើលក់ ឬថ្លៃ IPO ចំណែកឯអ្នកវិនិយោគដែលមិនទទួលបានជោគជ័យ ហើយមិនចង់បន្តទៅវគ្គបន្ទាប់ទៀតដែលជាវគ្គនៃការធ្វើបរិវិសកម្ម អាចមានសិទ្ធិដកប្រាក់របស់ខ្លួន ១០% មកវិញបាន។

### ៤.៤.១.២. ការធ្វើបរិវិសកម្ម

បន្ទាប់ពីការធ្វើ ប៊ុក បៀលឌីងត្រូវបានបញ្ចប់ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញ ត្រូវរៀបចំវគ្គបរិវិសកម្មបន្តទៀត ដែលការធ្វើបរិវិសកម្មនេះ ជាដំណាក់កាលចុះឈ្មោះទិញមូលបត្រនៅថ្លៃដែលបានកំណត់រួច។ វិនិយោគិនដែលបានទទួលជោគជ័យនៅក្នុងការធ្វើ ប៊ុក បៀលឌីង ត្រូវដាក់ពាក្យស្នើសុំធ្វើបរិវិសកម្មបន្តទៀត ហើយត្រូវដាក់ប្រាក់តម្កល់បន្ថែមឲ្យគ្រប់ ១០០% នៃតំលៃភាគហ៊ុនដែលទទួលបានជោគជ័យក្នុងវគ្គ ប៊ុក បៀលឌីង ដើម្បីទទួលបានភាគហ៊ុនទាំងនោះ។ ចំពោះវិនិយោគិនដែលពុំបានទទួលជោគជ័យ ឬមិនបានចូលរួមនៅក្នុងការធ្វើប៊ុក បៀលឌីង ក៏អាចមានសិទ្ធិចុះឈ្មោះទិញបនាដែរ ដោយត្រូវបំពេញពាក្យស្នើសុំធ្វើបរិវិសកម្ម និងបញ្ជាក់ពីបរិមាណមូលបត្រដែលខ្លួនចង់ទិញ ដោយត្រូវដាក់ប្រាក់តម្កល់ចំនួន ១០០% នៃតម្លៃភាគហ៊ុនដែលខ្លួនចង់ទិញដូចគ្នា។ ក្នុងដំណាក់កាលនេះ វិនិយោគិនអាចស្នើសុំទិញចាប់ពី ១០០ភាគហ៊ុនឡើងទៅ។ សម្រាប់ការបែងចែកមូលបត្រវិញ បើសំណើទិញលើសចំនួនមូលបត្រដែលបោះផ្សាយលក់ គេនឹងធ្វើការបែងចែកតាមវិធានប្រ៉ូរ៉ាតា។

### ៤.៤.២. ប្រតិបត្តិការជួញដូរនៅទីផ្សារបន្ទាប់

ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា គឺជាទីផ្សារបន្ទាប់សម្រាប់វិនិយោគិនក្នុងការបញ្ជាទិញ ឬលក់មូលបត្រដែលបានចុះបញ្ជី និងបានបោះផ្សាយលក់ជាសាធារណៈរួចមកហើយ។ ការជួញដូរមូល បត្រនៅទីផ្សារបន្ទាប់ ត្រូវអនុលោមតាមវិធានប្រតិបត្តិការទីផ្សាររបស់ ផ.ម.ក. ដែលប្រកាសដាក់ឱ្យអនុវត្តដោយ **គ.ម.ក.**។




*រូបភាព 12.- ដំណើរការជួញដូរមូលបត្រ*

#### ៤.៤.២.១. ម៉ោងជួញដូរ

ថ្ងៃជួញដូរចាប់ផ្តើមពីថ្ងៃចន្ទ ដល់ ថ្ងៃសុក្រ លើកលែងតែថ្ងៃឈប់សម្រាកជាសាធារណៈ ដោយអនុលោមតាមច្បាប់ស្តីពីការងារ។ ចំពោះម៉ោងជួញដូរចាប់ផ្តើមពីម៉ោង ០៨:០០ នាទី ព្រឹក រហូតដល់ម៉ោង ៣:០០ រសៀល ដែលមានរយៈពេលនៃការជួញដូរចំនួន ៧ម៉ោង ក្នុងមួយថ្ងៃ ដែលបែងចែកជាបីវគ្គដោយឈរលើមូលដ្ឋាននៃវិធីសាស្ត្រនៃការដេញថ្លៃ ដូចខាងក្រោម៖

| វគ្គ | ម៉ោងទទួលបញ្ជា | ម៉ោងអនុវត្តការជួញដូរ | វិធីសាស្ត្រ |
|---|---|---|---|
| វគ្គបើក | ៨:០០ ព្រឹក - ៩:០០ ព្រឹក | ៩:០០ ព្រឹក | ដេញថ្លៃដោយយកថ្លៃតែមួយ |
| វគ្គនិរន្តរ៍ | ៩:០០ ព្រឹក - ២:៥០ រសៀល | | ដេញថ្លៃដោយយកថ្លៃច្រើន |
| វគ្គបិទ | ២:៥០ រសៀល - ៣:០០ រសៀល | ៣:០០ រសៀល | ដេញថ្លៃដោយយកថ្លៃតែមួយ |

ប្រសិនបើមិនមានការផ្គូផ្គងបញ្ជានៅម៉ោង ៩:០០ នាទី ព្រឹកទេ វគ្គបើកនឹងត្រូវពន្យារពេលរហូតដល់មានការផ្គូផ្គងនៅក្នុងថ្ងៃដដែរ។

*ចំពោះវិធីសាស្ត្រជួញដូរតាមការចរចា÷ ម៉ោងជួញដូរ គឺពីម៉ោង ៩:០០នាទី ព្រឹកដល់ម៉ោង ៣:០០ នាទី រសៀល។

### ៤.៤.២.២. ប្រភេទបញ្ជា

បច្ចុប្បន្ន **ផ.ម.ក.** អនុញ្ញាតឱ្យមានប្រភេទបញ្ជាដូចខាងក្រោម៖

**ក. បញ្ជាដែនកំណត់** ( Limit Order )

ជាបញ្ជាដែលមានថ្លៃជាក់លាក់មួយដើម្បីទិញ ឬលក់មូលបត្រនៅថ្លៃជាក់លាក់នោះ ឬនៅថ្លៃប្រសើរជាងថ្លៃជាក់លាក់នោះ។ ថ្លៃប្រសើរជាងថ្លៃជាក់លាក់ គឺជាថ្លៃទាបជាងថ្លៃជាក់លាក់នោះក្នុងករណីទិញ ឬជាថ្លៃខ្ពស់ជាងថ្លៃជាក់លាក់នោះក្នុងករណីលក់។

**ខ. បញ្ជាទីផ្សារ** ( Market Order )

ជាបញ្ជាដើម្បីទិញឬលក់មូលបត្រកម្មសិទ្ធិ នៅថ្លៃល្អបំផុតដែលមានក្នុងទីផ្សារ។ បញ្ជាទី-ផ្សារមិនត្រូវបានអនុញ្ញាតសម្រាប់ប្រតិបត្តិការផ្តល់សន្ទនីយភាពមូលបត្រ និងការជួញដូរលើកដំបូងនៃមូលបត្រចុះបញ្ជីលក់លើកដំបូង។ នៅក្នុងវគ្គនិរន្តរ៍ បញ្ជាទីផ្សារអាចភ្ជាប់លក្ខខណ្ឌណាមួយ ដូចខាងក្រោម៖

- លក្ខខណ្ឌជួញដូរទាំងស្រុង ឬលុបចោល (Fill or Kill)៖ ជាលក្ខខណ្ឌដែលកំណត់ថាបញ្ជានឹងត្រូវលុបចោលភ្លាម ប្រសិនបើបរិមាណនៃបញ្ជានោះមិនត្រូវបានផ្គូផ្គងទាំងស្រុងភ្លាមៗ បន្ទាប់ពីត្រូវបានដាក់បញ្ចូលក្នុងប្រព័ន្ធជួញដូរ។
- លក្ខខណ្ឌជួញដូរ ហើយលុបចោល (Fill and Kill)៖ ជាលក្ខខណ្ឌដែលកំណត់ថាបញ្ជានឹងត្រូវលុបចោលភ្លាម ប្រសិនបើបរិមាណនៃបញ្ជានោះមិនត្រូវបានផ្គូផ្គងទាំងស្រុងឬមួយផ្នែកភ្លាមៗ បន្ទាប់ពីត្រូវបានដាក់បញ្ចូលក្នុងប្រព័ន្ធជួញដូរ។ ក្នុងករណីដែលបរិមាណនៃបញ្ជានោះត្រូវបានផ្គូផ្គងមួយផ្នែក បញ្ជាដែលមានបរិមាណនៅសល់នោះ នឹងត្រូវលុបចោលភ្លាម។

**គ. បញ្ជាតាមការចរចា** ( Negotiated Order )

ជាបញ្ជាដើម្បីទិញឬលក់មូលបត្រ តាមវិធីសាស្ត្រជួញដូរតាមការចរចា (Negotiated Trading Method)។ រាល់បញ្ជានីមួយៗ ត្រូវមានសុពលភាពចាប់ពីពេលដែលទទួលបាននៅក្នុងប្រព័ន្ធជួញដូររបស់ **ផ.ម.ក.** រហូតដល់ពេលដែលបញ្ជានោះត្រូវបានអនុវត្តការជួញដូរនៅអំឡុងវគ្គ

ជួញដូរនៃថ្ងៃតែមួយ។ ហើយសុពលភាពនៃបញ្ជានៃមូលបត្រណាមួយត្រូវបានព្យួរក្នុងករណីដែលការជួញដូរមូលបត្រនោះត្រូវបានព្យួរក្នុងអំឡុងម៉ោងជួញដូរ។

### ៤.៤.២.៣. ការដាក់បញ្ជា

ក្នុងរយៈពេលយ៉ាងហោចណាស់មួយថ្ងៃ បន្ទាប់ពីបើកគណនីជួញដូររួច ទើបវិនិយោគិនអាចដាក់បញ្ជាទៅក្នុងប្រព័ន្ធជួញដូររបស់ ផ.ម.ក. ដើម្បីធ្វើការអាចជួញដូរបាន។ វិនិយោគិនអាចធ្វើការដាក់បញ្ជាទិញ ឬលក់មូលបត្រទៅកាន់ក្រុមហ៊ុនមូលបត្រដែលខ្លួនបានជ្រើសរើសតាមរយៈការអញ្ជើញ ទៅក្រុមហ៊ុនមូលបត្រនោះដោយផ្ទាល់ ឯកសារជាលាយលក្ខណ៍អក្សរ ការហៅទូរសព្ទ សារជាសំឡេង អ៊ីម៉ែល ឬវិសាស្ត្រអេឡិចត្រូនិចផ្សេងៗទៀត ហើយជាពិសេសវិនិយោគិនអាចប្រើប្រាស់នូវប្រព័ន្ធជួញដូរចល័ត (MTS Moblie Trading Syetem) របស់ ផ.ម.ក.បានផងដែរ។ ដើម្បីធ្វើការដាក់បញ្ជាបានសម្រេច វិនិយោគិនត្រូវភ្ជាប់ជាមួយនូវព័ត៌មានលម្អិតនៃការដាក់បញ្ជា និងត្រូវមានសាច់ប្រាក់យ៉ាងហោចណាស់ ១០០% សម្រាប់បញ្ជាទិញ ឬមានមូលបត្រយ៉ាងហោចណាស់ ១០០% សម្រាប់ការដាក់បញ្ជាលក់។

### ៤.៤.២.៤. ព័ត៌មានលម្អិតនៃបញ្ជា

បញ្ជាដែលដាក់ចូលទៅក្នុងប្រព័ន្ធជួញដូរត្រូវមានព័ត៌មានលម្អិតដូចជា៖

១-ឈ្មោះមូលបត្រ

២-បរិមាណ

៣-ថ្លៃ ករណីក្រៅពីបញ្ជាទីផ្សារ

៤-លេខកូដជួញដូរតាមការចរចា ចំពោះបញ្ជាតាមការចរចា

៥-ការបញ្ជាក់ពីបញ្ជា៖ បញ្ជាទិញ ឬបញ្ជាលក់

៦-ប្រភេទនៃប្រតិបត្តិការ៖ ប្រតិបត្តិការគណនីអតិថិជន ឬប្រតិបត្តិការគណនីសមាជិក

៧-លេខអត្តសញ្ញាណសមាជិក

៨-លេខអត្តសញ្ញាណវិនិយោគិន

៩-លេខបញ្ជា

១០-លេខគណនីជួញដូរ

១១-ក្នុងករណីលុប ឬកែប្រែបញ្ជាត្រូវបញ្ជាក់ថាជាការលុ ឬកែប្រែ និងបញ្ជាក់លេខបញ្ជាដើម

១២-លេខកូដវិនិយោគិន៖ រូបវន្តបុគ្គល ឬនីតិបុគ្គល

១៣-លេខកូដប្រទេសរបស់វិនិយោគិន។

#### ៤.៤.២.៥. ឯកតាគម្លាតតម្លៃ

ឯកតាគម្លាតតម្លៃ សម្រាប់ថ្លៃនៃមូលបត្រកម្មសិទ្ធិនីមួយៗត្រូវបានកំណត់ដូចខាងក្រោម៖

| ថ្លៃ | ឯកតាគម្លាតតម្លៃ | ឧទាហរណ៍ថ្លៃបញ្ជាខុស | ឧទាហរណ៍ថ្លៃបញ្ជាត្រូវ |
|---|---|---|---|
| ]0-4,000[ | 10 | 2,555; 3,012 | 2,550; 3,010 |
| [4,000-20,000[ | 20 | 4,210; 19,525 | 4,200; 19,520 |
| [20,00-40,000[ | 50 | 20,110; 35,530 | 20,100; 35,550 |
| [40,000-100,000[ | 100 | 50,720; 90,450 | 50,720; 90,400 |
| [100,000-200,000[ | 200 | 150,500; 125,300 | 150,400; 125,400 |
| [200,000-400,000[ | 500 | 300,100; 350,200 | 300,000; 350,500 |
| [400,000[ | 1000 | 620,500; 851,100 | 621,000; 852,000 |

*តារាង 9.- តារាងឯកតាគម្លាតថ្លៃ*

#### ៤.៤.២.៦. ថ្លៃមូលដ្ឋាន

ថ្លៃមូលដ្ឋានសម្រាប់ការជួញដូរមូលបត្រកម្មសិទ្ធិចុះបញ្ជីលក់លើកដំបូង សំដៅដល់ថ្លៃជួញដូរដំបូងដែលត្រូវបានកំណត់នៅចន្លោះពី ៩០% (កៅសិបភាគរយ) និង ១៥០% (មួយរយហាសិបភាគរយ) នៃថ្លៃបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង។ រីឯ ថ្លៃមូលដ្ឋាននៃមូលបត្រកម្មសិទ្ធិសម្រាប់ថ្ងៃជួញដូរនិមួយៗ គឺជាថ្លៃបិទនៃថ្ងៃជួញដូរចុងក្រោយ។

#### ៤.៤.២.៧. ថ្លៃពិសេស

ថ្លៃពិសេសសំដៅដល់ថ្លៃដូចខាងក្រោម ក្នុងករណីមូលបត្រកម្មសិទ្ធិមិនត្រូវបានអនុវត្តការជួញដូររហូតដល់ម៉ោងបិទផ្សារ៖

- ថ្លៃល្អបំផុតនៃសំណើលក់ល្អបំផុត ដែលថ្លៃនៃសំណើលក់នេះទាបជាងថ្លៃមូលដ្ឋាន ឬថ្លៃបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង សម្រាប់ថ្ងៃជួញដូរលើកដំបូង។
- ថ្លៃល្អបំផុតនៃសំណើទិញ ដែលថ្លៃនៃសំណើទិញនេះខ្ពស់ជាងថ្លៃមូលដ្ឋានឬថ្លៃបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង សម្រាប់ថ្ងៃជួញដូរលើកដំបូង។

**ឧទាហរណ៍១៖**

| បញ្ជាលក់ (Ask Order) | ថ្លៃ (Price) | បញ្ជាទិញ (Bid Order) |
|---|---|---|
| ① 300 | 10,420 | |
| | 10,400 (ថ្លៃមូលដ្ឋាន) | |
| ② 200 | 10,380 | |
| | 10,360 | |
| | 10,340 | ③ 100 |

- គ្មានការជួញដូរកើតមានឡើងរហូតដល់ផ្សារបិទ
- ⇒ ថ្លៃពិសេសគឺ៖ 10,380 រ

**ឧទាហរណ៍២៖**

| បញ្ជាលក់ (Ask Order) | ថ្លៃ (Price) | បញ្ជាទិញ (Bid Order) |
|---|---|---|
| ③ 700 | 10,420 | |
| | 10,400 | |
| | 10,380 | ① 300 |
| | 10,360 (ថ្លៃមូលដ្ឋាន) | |
| | 10,340 | ② 100 |

- គ្មានការជួញដូរកើតមានឡើងរហូតដល់ផ្សារបិទ
- ⇒ ថ្លៃពិសេសគឺ៖ 10,380 រ

### ៤.៤.២.៨. វិធីសាស្ត្រជួញដូរមូលបត្រកម្មសិទ្ធិ និងមូលបត្របំណុល

វិធីសាស្ត្រជួញដូរ ត្រូវបានធ្វើឡើងតាមវិធីសាស្ត្រចំនួនពីរគឺ វិធីសាស្ត្រដេញថ្លៃ (Auction Trading Method) និងវិធីសាស្ត្រជួញដូរតាមការចរចា (Negotiated Trading Method)។

#### ក. វិធីសាស្ត្រដេញថ្លៃ

វិធីសាស្ត្រដេញថ្លៃ គឺជាវិធីសាស្ត្រផ្គូផ្គងបញ្ជាទិញ និងបញ្ជាលក់ដោយស្វ័យប្រវត្តិ តាមវិធីសាស្ត្រដេញថ្លៃដោយយកថ្លៃតែមួយ (Single Price Auction)ឬ វិធីសាស្ត្រដេញថ្លៃដោយយកថ្លៃច្រើន (Multiple Price Auction)។

➢ **វិធីសាស្ត្រដេញថ្លៃដោយយកថ្លៃតែមួយ**

ការជួញដូរតាមវិធីសាស្ត្រដេញថ្លៃដោយយកថ្លៃតែមួយ បញ្ជាទិញ និងបញ្ជាលក់ទាំងអស់ត្រូវបានផ្គូផ្គងព្រមគ្នានិងជួញដូរនៅថ្លៃតែមួយ។

➢ **វិធីសាស្ត្រដេញថ្លៃដោយយកថ្លៃច្រើន**

ការជួញដូរតាមវិធីសាស្ត្រដេញថ្លៃដោយយកថ្លៃច្រើន បញ្ជាទិញ ឬបញ្ជាលក់មួយអាចផ្គូផ្គង និងអាចជួញដូរនៅថ្លៃច្រើនផ្សេងៗពីគ្នា ហើយថ្លៃថ្លៃជួញដូរគឺជាថ្លៃនៃបញ្ជាដែលទទួលបានមុន។

អាទិភាពនៃបញ្ជាតាមវិធីសាស្ត្រដេញថ្លៃដោយយកថ្លៃតែមួយ និង វិធីសាស្ត្រដេញថ្លៃដោយយកថ្លៃច្រើន ត្រូវកំណត់ទៅតាមគោលការណ៍ដូចខាងក្រោម៖

**ក. អាទិភាពថ្លៃ**

បញ្ជាលក់ដែលមានថ្លៃទាបជាង (បញ្ជាទិញដែលមានថ្លៃខ្ពស់ជាង) មានអាទិភាពលើបញ្ជាលក់ដែលមានថ្លៃខ្ពស់ជាង (បញ្ជាទិញដែលមានថ្លៃទាបជាង)។

**ខ. អាទិភាពពេលវេលា**

ក្នុងករណីបញ្ជាមានថ្លៃដូចគ្នា នោះអាទិភាពបញ្ជាដែលទទួលបានមុនគឺមានអាទិភាពលើបញ្ជាដែលទទួលបានក្រោយ។

***លក្ខណៈសំខាន់ៗនៃវិធីសាស្ត្រដេញថ្លៃចំពោះមូលបត្រកម្មសិទ្ធិ៖**

- បញ្ជាអប្បបរមា៖ 1 ភាគហ៊ុន
- អតិបរិមា៖ មិនកំណត់
- ឯកតាគម្លាតថ្លៃ៖ 10, 20, 50, 100, 200, 500, 1000 (KHR)
- ដែនកំណត់ថ្លៃប្រចាំថ្ងៃ៖ ±10 %នៃថ្លៃមូលដ្ឋាន

***លក្ខណៈសំខាន់ៗនៃវិធីសាស្ត្រដេញថ្លៃចំពោះមូលបត្របំណុល៖**

- បញ្ជាអប្បបរមា៖ 1 ភាគហ៊ុន
- អតិបរិមា៖ ឯកតា 10, 000
- ឯកតាគម្លាតថ្លៃ៖ 1 (KHR)
- ដែនកំណត់ថ្លៃប្រចាំថ្ងៃ៖ មិនអនុវត្ត

**ខ. វិធីសាស្ត្រជួញដូរតាមការចរចា** (Negotiated Trading Method)

គឺជាវិធីសាស្ត្រផ្គូផ្គងបញ្ជាតាមការចរចាទិញ និងលក់មួយគូ បន្ទាប់ពីភាគីទាំងពីរបានចរចា និងព្រមព្រៀងលើលក្ខខណ្ឌទាំងឡាយនៃការជួញដូរ។ បញ្ជាជួញដូរតាមការចរចាទាំងសង្ខាង ត្រូវមានព័ត៌មានលម្អិតដូចគ្នាទាំងស្រុងគឺ ឈ្មោះមូលបត្រ បរិមាណ ថ្លៃ និងលេខកូតជួញដូរតាមការចរចា។

***លក្ខណៈសំខាន់ៗនៃវិធីសាស្ត្រជួញដូរតាមការចរចារចំពោះមូលបត្រកម្មសិទ្ធិ៖**

- បញ្ជាអប្បបរមា៖ បញ្ជាតាមការចរចាត្រូវមានបរិមាណយ៉ាងហោច 50,000 ភាគហ៊ុន ឬ តម្លៃជួញដូរ 200,000,000 រៀល ។(យកមួយណាដែលតូចជាង)
- ឯកតាគម្លាតថ្លៃ៖ 1 រៀល។
- ដែនកំណត់ថ្លៃប្រចាំថ្ងៃ៖ ±10 %នៃថ្លៃមូលដ្ឋាន។

***លក្ខណៈសំខាន់ៗនៃវិធីសាស្ត្រជួញដូរតាមការចរចារចំពោះមូលបត្រកម្មបំណុល៖**

- បញ្ជាអប្បបរមា៖ បញ្ជាតាមការចរចាត្រូវមានបរិមាណយ៉ាងហោច ឯកតា1
- ឯកតាគម្លាតថ្លៃ៖ 1 រៀល។
- ដែនកំណត់ថ្លៃប្រចាំថ្ងៃ៖ មិនត្រូវបានអនុវត្តចំពោះការជួញដូរតាមវិធីសាស្ត្រជួញដូរតាមការចរចា។

### ៤.៤.២.៩. យន្តការផាត់ទាត់

#### ៤.៤.២.៩.១. ប្រព័ន្ធផាត់ទាត់ និងទូទាត់

ប្រព័ន្ធផាត់ទាត់ និងទូទាត់ សំដៅដល់ប្រព័ន្ធដែលផ្តល់លទ្ធភាពដល់ភាគីធ្វើប្រតិបត្តិការជួញដូរមូលបត្រ បំពេញកាតព្វកិច្ចរបស់ខ្លួនទៅវិញ ទៅមកបាន ដោយធ្វើការផ្ទៀងផ្ទាត់ប្រតិបត្តិការបានយ៉ាងច្បាស់លាស់ និងធានាឱ្យមានការទូទាត់ថ្លៃទិញជូនអ្នកលក់ដែលជាថ្នូរនឹងការផ្ទេរកម្មសិទ្ធិមូលបត្រឱ្យអ្នកទិញ។ ប្រព័ន្ធផាត់ទាត់ និងទូទាត់រួមមាន៖ ប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ និងប្រព័ន្ធផាត់ទាត់ និងទូទាត់សាច់ប្រាក់។

- **ប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ៖** សំដៅទៅដល់ប្រព័ន្ធផាត់ទាត់ និងទូទាត់ ដើម្បីធ្វើការផ្លាស់ប្តូរកម្មសិទ្ធិលើមូលបត្ររវាងភាគីប្រតិបត្តិការជួញដូរមូលបត្រ។
- **ប្រព័ន្ធផាត់ទាត់ និងទូទាត់សាច់ប្រាក់៖** សំដៅដល់ប្រព័ន្ធផាត់ទាត់ និងទូទាត់ដើម្បីធ្វើការផ្ទេរ ឬបង្វែរសាច់ប្រាក់រវាងភាគីធ្វើប្រតិបត្តិការជួញដូរមូលបត្រ។ ក្រុមហ៊ុនមូលបត្រ

នីមួយៗត្រូវបើកគណនីដោយឡែកចំនួនចំនួន បី គឺ៖ គណនីសាច់ប្រាក់អតិថិជន គណនីសាច់ប្រាក់ផ្ទាល់ខ្លួន និងគណនីទូទាត់សាច់ប្រាក់។

**+ តួអង្គសំខាន់ៗនៅក្នុងយន្តការនៃការផាត់ទាត់និងទូទាត់៖**

ការផាត់ទាត់ និងទូទាត់មូលបត្រមានការចូលរួមពីភាគីពាក់ព័ន្ធមួយចំនួនដូចជា៖

- CSX: ប្រតិបត្តិករទីផ្សារមូលបត្រ
- CSO: ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ
- CSD: ប្រតិបត្តិកររក្សាទុកមូលបត្រ
- SFs: ក្រុមហ៊ុនមូលបត្រដែលទទួលបានអាជ្ញាបណ្ណពី គ.ម.ក.
- CSAs: ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ
- NBC: ធនាគារជាតិនៃកម្ពុជា ។

### ៤.៤.២.៩.២. នីតិវិធីនៃការផាត់ទាត់ និងទូទាត់

នៅកាលបរិច្ឆេទក្នុងថ្ងៃ T+0: ប្រព័ន្ធរបស់ CSO នឹងទទួលទិន្នន័យជួញដូរដែលផ្គូផ្គងជោគជ័យដោយស្វ័យប្រវត្តិ ពីប្រព័ន្ធជួញដូររបស់ប្រតិបត្តិករទីផ្សារមូលបត្រក្រោយពេលផ្សារបិទសម្រាប់រក្សាទុកដើម្បីធ្វើការផាត់ទាត់បរិមាណមូលបត្រនិងបរិមាណសាច់ប្រាក់សរុបរបស់ក្រុមហ៊ុនមូលបត្រនីមួយៗនៅកាលបរិច្ឆេទថ្ងៃបន្ទាប់ (T+១)។

• នៅកាលបរិច្ឆេទក្នុងថ្ងៃ T+១: ប្រព័ន្ធរបស់ CSO ចាប់ផ្តើមធ្វើប្រតិបត្តិការផាត់ទាត់សាច់ប្រាក់និងមូលបត្រ តាមរយៈការបន្សុទ្ធ ឬការកាត់កង (Netting) រវាងភាគីដែលបានធ្វើប្រតិបត្តិការជួញដូរពីកាលបរិច្ឆេទ T+0។ បន្ទាប់មកប្រហែលម៉ោង ២ រសៀល CSO នឹងធ្វើការទាញយកឯកសារបង្គាប់ទូទាត់ (Settlement Instrution SI) និងធ្វើការផ្ទៀងផ្ទាត់ដោយគណនានូវកម្រៃសាវា របស់ **គ.ម.ក.** និង **ផ.ម.ក.** រួចរក្សាទុក SI ជាexcel file និងបោះពុម្ព ១ ច្បាប់។ បន្ទាប់មក រដ្ឋបាលយ៉ាងយូរត្រឹមម៉ោង ៥:០០ រសៀល ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រត្រូវមកយកច្បាប់ដើមឯកសារបង្គាប់ទូទាត់ពី CSO។

• នៅកាលបរិច្ឆេទក្នុងថ្ងៃ T+២: នៅមុនម៉ោង ០៨:៣០នាទីព្រឹក CSO នឹងធ្វើការពិនិត្យមើលគណនីទូទាត់ (Settlement Account) របស់ **ផ.ម.ក.** ដើម្បីពិនិត្យ និងផ្ទៀងផ្ទាត់មើលនូវព័ត៌មាននៃការទូទាត់សាច់ប្រាក់ជាមួយនឹង SI ដែល CSO បានបញ្ជាទូទាត់ (Cash Receipt Deposit)។

• នៅកាលបរិច្ឆេទក្នុងថ្ងៃ T+២: ប្រតិបត្តិការបន្ទាប់នៅម៉ោង ១០:៣០ នាទី ព្រឹក CSO នឹងធ្វើការបញ្ជាក់ការទូទាត់សាច់ប្រាក់ចេញពីគណនីទូទាត់ (CS) របស់ខ្លួនទៅឱ្យគណនីទូទាត់របស់ក្រុមហ៊ុនមូលបត្រ (SF) ដែលជាអ្នកលក់មូលបត្រ។ នៅថ្ងៃ T+២ បន្ទាប់ពី CSO ចុចទូទាត់ (Confirmation Setlement) រួចហើយ ប្រព័ន្ធទូទាត់របស់ CSO នឹងធ្វើការទូទាត់មូលបត្រដោយស្វ័យប្រវត្តិពីគណនីមូលបត្ររបស់អ្នកលក់ទៅគណនីមូលបត្ររបស់អ្នកទិញ។




*រូបភាព 13.- ដំណើរការនៃប្រព័ន្ធផាត់ទាត់ និងទូទាត់*

(១). ប្រតិបត្តិករទីផ្សារមូលបត្រ ត្រូវបញ្ជូនព័ត៌មានពីការជួញដូរដែលបានបន្សុីរួចរាល់ (Confirmed Trade)ទៅ CSO

- CSO ត្រូវធ្វើការបន្សុទ្ធ (Netting)សាច់ប្រាក់ និងមូលបត្រ

+បន្សុទ្ធសាច់ប្រាក់ = ផាត់ទាត់តម្លៃទិញសរុប និងតម្លៃលក់សម្រាប់សមាជិកនីមួយៗ

+បន្សុទ្ធមូលបត្រ = ផាត់ទាត់បរិមាណលក់សរុប និងបរិមាណទិញសរុបនៃមូលបត្រនីមួយៗ

(២). CSO បញ្ជូនព័ត៌មាននៃកាលបរិច្ឆេទផាត់ទាត់និងទូទាត់ ទឹកប្រាក់ និងបរិមាណនៃមូលបត្រនីមួយៗដែលត្រូវធ្វើការ

ទូទាត់ដោយសមាជិកផ្ទាល់ ឬក្នុងនាមអតិថិជន ទៅ SF(s)

(៣). SF(s) ត្រូវដាក់ការបញ្ជាទូទាត់សាច់ប្រាក់ទៅ CSA ដែលពាក់ព័ន្ធ

(៤). SF(s) ត្រូវដាក់ការបញ្ជាទូទាត់មូលបត្រទៅ CSD

### ៤.៤.២.៩.២.១. ដំណើរការនៃប្រព័ន្ធផាត់ទាត់ និងទូទាត់សាច់ប្រាក់

#### ក. ការទូទាត់សាច់ប្រាក់នៅក្នុងធនាគារតែមួយ




*រូបភាព 14.- ការទូទាត់សាច់ប្រាក់នៅក្នុងធនាគារតែមួយ*

(១)- SF(អ្នកទិញ) ត្រូវផ្ទេរសាច់ប្រាក់ពីគណនីសាច់ប្រាក់របស់ខ្លួន ទៅគណនីទូទាត់សាច់ប្រាក់របស់ CSO

(២)- បន្ទាប់មក CSO ត្រូវធ្វើការផ្ទេរសាច់ប្រាក់បន្តពីគណនីទូទាត់សាច់ប្រាក់របស់ខ្លួន ទៅគណនីសាច់ប្រាក់របស់ SF(អ្នកលក់)

#### ខ. ការទូទាត់សាច់ប្រាក់អន្តរធនាគារ




*រូបភាព 15.- ការទូទាត់សាច់ប្រាក់អន្តរធនាគារ*

(១). SF(អ្នកទិញ)ត្រូវផ្ទេរសាច់ប្រាក់ពីគណនីសាច់ប្រាក់របស់ខ្លួន ទៅគណនីទូទាត់សាច់ប្រាក់របស់ CSO

(២). បន្ទាប់មក CSO ត្រូវធ្វើការផ្ទេរសាច់ប្រាក់បន្តពីគណនីទូទាត់សាច់ប្រាក់របស់ខ្លួន ទៅគណនីសាច់ប្រាក់របស់ SF(អ្នកលក់) ដែលបើកនៅក្នុង CSA2 តាមរយៈសភាផាត់ទាត់នៃ NBC

### ៤.៤.២.៩.២.២. ដំណើរការនៃប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ




*រូបភាព 16.- ដំណើរការនៃប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ*

(១). SF(អ្នកលក់) ត្រូវផ្ទេរមូលបត្រ (Book-entry Transfer) ពីគណនីមូលបត្ររបស់ខ្លួន ទៅគណនីទូទាត់មូលបត្ររបស់ CSO។

(២). CSO ត្រូវផ្ទេរមូលបត្រ (Book-entry Transfer) ពីគណនីមូលបត្ររបស់ខ្លួន ទៅគណនីមូលបត្ររបស់ SF(អ្នកទិញ)។

### ៤.៤.២.១០ យន្តការនៃការរក្សាទុកមូលបត្រ

ប្រតិបត្តិកររក្សាទុកមូលបត្រសំដៅដល់កន្លែងសម្រាប់ដាក់ផ្ញើមូលបត្រ។ ហើយការដាក់ផ្ញើមូលបត្រ គឺជាដំណើរការនៃការផ្ទេរកម្មសិទ្ធិករមូលបត្រ តាមរយៈការផ្ទេររវាងគណនី (Book Entry) (ការកត់ត្រាឥណទាន/ឥណពន្ធ ក្នុងសៀវភៅគណនីរបស់សមាជិក និងអ្នកចូលរួម) ដោយគ្មានចរន្តនៃការផ្ទេរមូលបត្ររូបវន្ត។ ប្រតិបត្តិការរក្សាទុកមូលបត្រ គឺត្រូវចាប់ដំណើរកាផ្ទេរមូលបត្រ (Book Entry Transfer) នៅថ្ងៃទីពីរនៃការជួញដូរ (T+២) បន្ទាប់ពីប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រត្រូវបានអនុវត្តចប់រវាងក្រុមហ៊ុនមូលបត្រ និងអតិថិជនដោយការផ្ទេរមូលបត្រត្រូវបានផ្ទេរតាមប្រព័ន្ធ Ledger System។ ប្រព័ន្ធបច្ចេកវិទ្យានៃប្រតិបត្តិកររក្សាទុកមូលបត្រចាប់ផ្តើមដំណើរការពីម៉ោង ២:០០ ព្រឹក ដោយស្វ័យប្រវត្តិ និងប្រព័ន្ធ Ledger system ចាប់ផ្តើមដំណើរការនៅម៉ោង ៨:០០ ព្រឹក ហើយប្រព័ន្ធបច្ចេកវិទ្យានឹងបិទដំណើរការក្នុងអំឡុងពេលម៉ោង ១៦:៣០ ដល់ម៉ោង ១៧:០០ ល្ងាច បន្ទាប់ពីប្រព័ន្ធដទៃទៀតត្រូវបានបិទរួចរាល់។

សមាជិក អ្នកចូលរួម និងអតិថិជនដែលបានដាក់ផ្ញើរមូលបត្រនៅ **ផ.ម.ក.** មិនចាំបាច់ដកមូលបត្រទៅវិញ នៅពេលដែលត្រូវអនុវត្តន៍សិទ្ធិកម្មសិទ្ធិករឡើយ។ បុគ្គលដែលអាចបើកគណនីមូលបត្រនៅប្រតិបត្តិកររក្សាទុកមូលបត្ររួមមាន ក្រុមហ៊ុនមូលបត្រ និងក្រុមហ៊ុនចេះបញ្ជីលក់

មូលបត្រ។ បុគ្គលដែលមានបំណងបើកគណនីមូលបត្រត្រូវបំពេញសំណុំបែបបទបើកគណនីមូលបត្រនៅប្រតិបត្តិកររក្សាទុកមូលបត្រ។ គ្រប់គណនីមូលបត្រទាំងអស់ រួមមានគណនីមូលត្ររបស់សមាជិក ឬក៏របស់អតិថិជនត្រូវបានបង្កើតឡើងក្នុងប្រព័ន្ធ Ledger (ledger system) របស់ **ផ.ម.ក.** ដែលផ្ទុកផងដែលនូវទិន្នន័យលម្អិតនៃប្រតិបត្តិការរបស់សមាជិក និងអតិថិជន ព្រមទាំងទិន្នន័យលម្អិតនៃបញ្ជីភាគហ៊ុនិក។ ដើម្បីដាក់ផ្ញើមូលបត្រនៅប្រតិបត្តិកររក្សាទុកមូលបត្រ បុគ្គលដែលដាក់ផ្ញើរត្រូវតែផ្តល់ព័ត៌មានដូចខាងក្រោម ដល់ប្រតិបត្តិកររក្សាទុកមូលបត្រ៖

- ប្រភេទមូលបត្រ
- ចំនួននៃការបោះផ្សាយ
- ឈ្មោះមូលបត្រ
- អក្សរកូដ
- ចំនួនមូលបត្រសរុប
- កាលបរិច្ឆេទបេះបញ្ជី
- ព័ត៌មានផ្សេងទៀតពាក់ព័ន្ធនឹងកម្មសិទ្ធិភាពមូលបត្រ។

### ៤.៤.៣. ទិដ្ឋភាពទូទៅនៃការជួញដូរមូលបត្រនៅទីផ្សារមូលបត្រកម្ពុជា

#### ៤.៤.៣.១. ការជួញដូរមូលបត្រកម្មសិទ្ធិសម្រាប់ឆ្នាំ២០១៩

##### ៤.៤.៣.១.១. ទិដ្ឋភាពទូទៅនៃការជួញដូរមូលបត្រកម្មសិទ្ធិសម្រាប់ឆ្នាំ២០១៩

ទំហំមូលធនូបនីយកម្មទីផ្សារសរុប (Market Capitalization) នៅចុងឆ្នាំ២០១៩ មានតម្លៃ ២.៨០៥.៨០៧ លានរៀល (ប្រហែល ៧០១,៤៥ លានដុល្លារសហរដ្ឋអាមេរិក) ប្រហែលស្មើនឹង ២,៥៨% នៃ GDP សរុប[24]។ ក្នុងឆ្នាំ២០១៩ ទំហំជួញដូរភាគហ៊ុនសរុបមានចំនួន ១៥.៤៨៩.៩០៥ ភាគហ៊ុន បានកើនឡើងប្រមាណ ៣០៩,៦៥% ប្រៀបធៀបនឹងឆ្នាំ២០១៨ ដែលមានបរិមាណជួញដូរសរុបចំនួន ៣.៧៨១.២៣១ភាគហ៊ុន។ តម្លៃជួញដូរមូលបត្រសរុបមានតម្លៃប្រហែល ១៤៨.៨៧៨,៦៤ លានរៀល (ប្រហែល ៣៧,២២លានដុល្លារសហរដ្ឋអាមេរិក) បានកើនឡើងប្រមាណ ៤៩៧,៨៥% ប្រៀបធៀបជាមួយនឹងឆ្នាំ២០១៨។ ចំពោះទំហំជួញដូរជាមធ្យមប្រចាំថ្ងៃមានចំនួន ៦៥.៣៥៨ ភាគហ៊ុន ដែលមានតម្លៃប្រមាណ ៦២៨,១៨ លានរៀល (ប្រហែលនឹង ១៥៧,០៥ ពាន់ដុល្លារសហរដ្ឋអាមេរិក)។

[24] Website: https://www.mef.gov.kh/ (បានចូលទស្សនានៅថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០២០)

*តារាង 10.- ទិដ្ឋភាពទូទៅនៃការជួញដូរមូលបត្រ*

| ទិដ្ឋភាពទូទៅ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | បម្រែបម្រួល |
|---|---|---|---|
| មូលធនូបនីយកម្មទីផ្សារ (លានរៀល) | 1,771,678 | 2,805,807 | 58.37% |
| មូលធនូបនីយកម្មទីផ្សារ (លានដុល្លារ) | 442.92 | 701.45 | |
| ទំហំជួញដូរ (ភាគហ៊ុន) | 3,781,231 | 15,489,905 | 309.65% |
| ទំហំជួញដូរជាមធ្យមប្រចាំថ្ងៃ (ភាគហ៊ុន) | 16,228 | 65,358.25 | |
| តម្លៃជួញដូរ (លានរៀល) | 24,902.32 | 148,878.64 | 497.85% |
| តម្លៃជួញដូរ (ដុល្លារ) | 6,225,580 | 37,219,659 | |
| តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃ (លានរៀល) | 106.88 | 628.18 | 487.76% |
| តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃ (ដុល្លារ) | 26,719.23 | 157,044.98 | |
| សន្ទស្សន៍ **ផ.ម.ក.** (សន្ទស្សន៍បិទ) | 480.98 | 761.73 | 58.37% |
| ចំនួនវិនិយោគិន | 669 | 1,311 | 95.96% |

ទំហំជួញដូរភាគហ៊ុនរបស់ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រត្រូវបានបែងចែកតាមក្រុមហ៊ុន រួមមាន PWSA ស្មើនឹង ៧%, GTI ស្មើនឹង ១%, PPAP ស្មើនឹង ៣%, PPSP ស្មើនឹង ២៤% និង PAS ស្មើនឹង ៦៥% នៃភាគហ៊ុនដែលបានជួញដូរសរុបប្រចាំឆ្នាំ២០១៩។




*ក្រាហ្វិច 1.- ទំហំជួញដូររបស់ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ (គិតជាភាគរយ)*

### ៤.៤.៣.១.២. សន្ទស្សន៍ ផ.ម.ក

ក្នុងឆ្នាំ២០១៩ សន្ទស្សន៍ **ផ.ម.ក.** បានកើនឡើងប្រមាណ ៥៨,៣៧% ដែលប្រែប្រួល ពី ៤៨០,៩៨ នៅចុងឆ្នាំ២០១៨ ដល់ ៧៦១,៧៣ នៅចុងឆ្នាំ២០១៩។




*ក្រាហ្វិច 2.- សន្ទស្សន៍ ផ.ម.ក. និងទំហំជួញដូរសរុប*

ចំនួនបញ្ជាទិញ-លក់សរុបប្រចាំឆ្នាំ២០១៩ មានចំនួនសរុបប្រមាណ ៥១,២០ លាន ភាគហ៊ុន ដែលក្នុងនោះបរិមាណបញ្ជាលក់មានប្រមាណ ២៩,៦០ លានភាគហ៊ុន និងចំនួនបញ្ជាទិញមានប្រមាណ ២១,៦០ លានភាគហ៊ុន។ នៅក្នុងនោះ បរិមាណបញ្ជាទិញសរុបបានកើនឡើងប្រមាណ ៣០,៩% ធៀបនឹងឆ្នាំ២០១៨ និងបរិមាណបញ្ជាលក់បានកើនឡើងប្រមាណ ១៦,៦៩% បើប្រៀបធៀបនឹងឆ្នាំ២០១៨ ផងដែរ។ ក្នុងចំណោមភាគហ៊ុនចុះបញ្ជីលក់នៅ **ផ.ម.ក.** ភាគហ៊ុនរបស់ PAS ទទួលបានការដាក់បញ្ជាទិញច្រើនជាងគេ ដែលមានចំនួនសរុបដល់ប្រមាណ ១១.១២២.៦៧៣ ភាគហ៊ុន ចំណែកឯ ភាគហ៊ុនទទួលបានការដាក់បញ្ជាលក់ច្រើនជាងគេ គឺភាគហ៊ុនរបស់ក្រុមហ៊ុន PAS ដដែរ ទទួលបានការដាក់បញ្ជាលក់សរុបប្រមាណ ១១.៧៦៨.២៩៥ ភាគហ៊ុន។




*ក្រាហ្វិច 3.- ចំនួនបញ្ញាទិញ-លក់ភាគហ៊ុនចុះបញ្ជីទាំង៥*

## ៤.៤.៣.១.៤. ការចូលរួមជួញដូរមូលបត្ររបស់វិនិយោគិន

ក្នុងឆ្នាំ២០១៩ ចំនួនយោគិនចូលរួមសរុបមានចំនួន ១.៣១១ នាក់ ដែលក្នុងនោះវិនិយោគិនជនជាតិខ្មែរមានចំនួន ៨៩២ នាក់ ស្មើនឹង ៦៨% និងវិនិយោគិនបរទេសមានចំនួន ៩១៩ នាក់ ស្មើនឹង ៣២% ហើយបើយើងបែងចែកទៅតាមប្រភេទវិនិយោគិនវិញ នៅក្នុងឆ្នាំ២០១៩ មានវិនិយោគិន ជាវិនិយោគិននីតិបុគ្គលចំនួន ១២ នាក់ និងវិនិយោគិនរូបវន្តបុគ្គល ១.២៩៩ នាក់។ ដោយឡែកនៅក្នុងឆ្នាំ២០១៨ ចំនួនយោគិនចូលរួមសរុបមានចំនួន ៦៦៩ នាក់ ដែលក្នុងនោះមានវិនិយោគិន ជនជាតិខ្មែរមានចំនួន ៥០០ នាក់ ស្មើនឹង ៧៤,៧៣% និងវិនិយោគិនបរទេសមានចំនួន ១៦៩ នាក់ ស្មើនឹង ២៥,២៧% ហើយបើយើងបែងចែកទៅតាមប្រភេទវិនិយោគិនវិញ នៅក្នុងឆ្នាំ២០១៨ មានវិនិយោគិន ជាវិនិយោគិននីតិបុគ្គលចំនួន ៦ នាក់ និងវិនិយោគិនរូបវន្តបុគ្គល ៦៦៣ នាក់។ ជារួមនៅក្នុងឆ្នាំ២០១៩ វិនិយោគិនចូលរួមនៅក្នុងទីផ្សារមានការកើនឡើងរហូតដល់ ៩៥,៩៦% បើធៀបនឹងឆ្នាំ២០១៨។

ចំនួនវិនិយោគិនបែងចែកតាមសញ្ជាតិខ្មែរ និងបរទេស




*ក្រាហ្វិច 4.- ចំនួនវិនិយោគិនបែងចែកតាមសញ្ជាតិខ្មែរ និងបរទេស*

ចំនួនវិនិយោគិនបែងចែកតាមប្រភេទរូបវន្តបុគ្គល និងនីតិបុគ្គល




*ក្រាហ្វិច 5.- ចំនួនវិនិយោគិនបែងចែកតាមប្រភេទរូបវន្តបុគ្គល និងនីតិបុគ្គល*

#### ៤.៤.៣.២. សកម្មភាពជួញដូរភាគហ៊ុនរបស់ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ

##### ៤.៤.៣.២.១. ភាគហ៊ុនរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (PWSA)

| ទិដ្ឋភាពទូទៅ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | បម្រែបម្រួល |
|---|---|---|---|
| មូលធនូបនីយកម្មទីផ្សារ (លានរៀល) | 365,287 | 521,839 | 42.86% |
| មូលធនូបនីយកម្មទីផ្សារ (លានដុល្លារ) | 91.32 | 130.46 | |
| ទំហំជួញដូរ (ភាគហ៊ុន) | 612,321 | 1,023,467 | 67.15% |
| ទំហំជួញដូរជាមធ្យមប្រចាំថ្ងៃ (ភាគហ៊ុន) | 2,628 | 4,318.43 | |
| តម្លៃជួញដូរ (លានរៀល) | 2,081.32 | 5,812.57 | 179.27% |
| តម្លៃជួញដូរ (ដុល្លារ) | 520,331 | 1,453,143 | |
| តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃ (លានរៀល) | 8.93 | 24.53 | 174.56% |
| តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃ (ដុល្លារ) | 2,233.18 | 6,131.41 | |

*តារាង 11.- ទិដ្ឋភាពទូទៅនៃការជួញដូរភាគហ៊ុន PWSA*

នៅក្នុងឆ្នាំ២០១៩ ថ្លៃបិទរបស់ភាគហ៊ុន PWSA ប្រែប្រួលក្នុងចន្លោះពី ៤.២០០រៀល ដល់ ៦.០០០ រៀល។ ចំពោះសកម្មភាពជួញដូរមានការកើនឡើងបើធៀបជាមួយនឹងឆ្នាំ២០១៨ ដែលមានទំហំជួញដូរ កើនឡើងពី ៦១២.៣១២ ភាគហ៊ុន នៅក្នុងឆ្នាំ២០១៨ ដល់ ១.០២៣.៤៦៧ ភាគហ៊ុន នៅក្នុងឆ្នាំ២០១៩។ តម្លៃជួញដូរសរុបសម្រាប់ភាគហ៊ុន PWSA នៅក្នុងឆ្នាំ២០១៩ មានតម្លៃប្រហែល ៥.៨១២ លានរៀល (ប្រហែល ១,៤៥ លានដុល្លារសហរដ្ឋអាមេរិក)។




*ក្រាហ្វិច 6.- ថ្លៃភាគហ៊ុនធៀបនឹងទំហំជួញដូររបស់ភាគហ៊ុន PWSA*

ចំពោះបរិមាណបញ្ជាទិញ-លក់សរុបរបស់ភាគហ៊ុន PWSA មានចំនួន ៨.៩៥២.០៣៦ ភាគហ៊ុន ដែលក្នុងនោះអនុបាតបញ្ជាលក់ធៀបនឹងបញ្ជាទិញមានចំនួន ១,៦០ ដែលបង្ហាញថាវិនិយោគិនមាននិន្នាការលក់ច្រើនជាងទិញ (បរិមាណដាក់បញ្ជាលក់មានចំនួនប្រមាណ ៥.៣១៧.៦៧៩ ភាគហ៊ុន និងបរិមាណដាក់បញ្ជាទិញមានចំនួនប្រមាណ ៣.៣១៤.៣៥៧ ភាគហ៊ុន)។ ក្នុងនោះដែរ បរិមាណបញ្ជាទិញ-លក់ សរុបមានការថយចុះប្រមាណ ១,៧៦% ចំណែកឯបរិមាណបញ្ជាទិញសរុប បានថយចុះប្រមាណ ២១,៧៧% និងបរិមាណបញ្ជាលក់បានកើនឡើងប្រមាណ ១៥,៦៧% បើប្រៀបធៀបនឹងឆ្នាំ២០១៨ ផងដែរ។

**បរិមាណបញ្ជាទិញ-លក់**




*ក្រាហ្វិច 7.- បរិមាណបញ្ជាទិញ-លក់មូលបត្រ PWSA*

### ៣.៤.៣.២.២. ភាគហ៊ុនរបស់ក្រុមហ៊ុន គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី (GTI)

| ទិដ្ឋភាពទូទៅ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | បម្រែបម្រួល |
|---|---|---|---|
| មូលធនូបនីយកម្មទីផ្សារ (លានរៀល) | 172,800 | 176,000 | 1.85% |
| មូលធនូបនីយកម្មទីផ្សារ (លានដុល្លារ) | 43.20 | 44.00 | |
| ទំហំជួញដូរ (ភាគហ៊ុន) | 140,910 | 190,716 | 35.35% |
| ទំហំជួញដូរជាមធ្យមប្រចាំថ្ងៃ (ភាគហ៊ុន) | 605 | 804.71 | |
| តម្លៃជួញដូរ (លានរៀល) | 596.12 | 904.84 | 51.79% |
| តម្លៃជួញដូរ (ដុល្លារ) | 149,030 | 226,209 | |
| តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃ (លានរៀល) | 2.56 | 3.82 | 49.23% |
| តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃ (ដុល្លារ) | 639.61 | 954.47 | |

*តារាង 12.- ទិដ្ឋភាពទូទៅនៃការជួញដូរភាគហ៊ុន GTI*

ក្នុងឆ្នាំ២០១៩ ថ្លៃបិទរបស់ភាគហ៊ុន GTI ប្រែប្រួលក្នុងចន្លោះពី ៤.៣២០ រៀល ដល់ ៤.៨០០ រៀល។ ចំពោះសកម្មភាពជួញដូរមានការកើនឡើងបើធៀបជាមួយនឹងឆ្នាំ២០១៨ ដែលមានទំហំជួញដូរ កើនឡើងពី ១៤០.៩១០ ភាគហ៊ុន នៅក្នុងឆ្នាំ២០១៨ ដល់ ១៩០.៧១៦ ភាគហ៊ុន នៅក្នុងឆ្នាំ២០១៩។ តម្លៃជួញដូរសរុបសម្រាប់ភាគហ៊ុន GTI នៅក្នុងឆ្នាំ២០១៩ មានតម្លៃប្រហែល ៩០៤ លានរៀល (ប្រហែល ២២៦,២១ពាន់ដុល្លារសហរដ្ឋអាមេរិក)។




*ក្រាហ្វិច 8.- ថ្លៃភាគហ៊ុនធៀបនឹងទំហំជួញដូររបស់ភាគហ៊ុន GT*

ចំពោះបរិមាណបណ្ណទិញ-លក់សរុបរបស់ភាគហ៊ុន GTI មានចំនួន ១៨២១.៧៤០ ភាគហ៊ុន ដែលក្នុងនោះអនុបាតបណ្ណលក់ធៀបនឹងបណ្ណទិញមានចំនួន ១,០៩ ដែលបង្ហាញថាវិនិយោគិនមាននិន្នាការលក់ច្រើនជាងទិញ (បរិមាណដាក់បណ្ណលក់មានចំនួនប្រមាណ ៨៧១.៧៧១ ភាគហ៊ុន និងបរិមាណដាក់បណ្ណទិញមានចំនួនប្រមាណ ៩៤៩.៩៦៩ ភាគហ៊ុន)។ ក្នុងនោះដែរ បរិមាណបណ្ណទិញ-លក់ សរុបមានការថយចុះប្រមាណ ៧៨, ៨៣% ចំណែកឯបរិមាណបណ្ណទិញសរុបបានថយចុះប្រមាណ ៧៨,២៤% និងបរិមាណបណ្ណលក់បានថយចុះប្រមាណ ៧៩,៣៤% បើប្រៀបធៀបនឹងឆ្នាំ២០១៨ ផងដែរ។




*ក្រាហ្វិច 9.- បរិមាណបណ្ណទិញ-លក់មូលបត្រ GTI*

### ៤.៤.៣.២.៣. ភាគហ៊ុនរបស់កំពង់ផែស្វយ័តភ្នំពេញ ( PPAP )

| ទិដ្ឋភាពទូទៅ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | បម្រែបម្រួល |
|---|---|---|---|
| មូលធនូបនីយកម្មទីផ្សារ (លានរៀល) | 158,856 | 258,555 | 62.76% |
| មូលធនូបនីយកម្មទីផ្សារ (លានដុល្លារ) | 39.71 | 64.64 | |
| ទំហំជួញដូរ (ភាគហ៊ុន) | 445,180 | 441,819 | -0.75% |
| ទំហំជួញដូរជាមធ្យមប្រចាំថ្ងៃ (ភាគហ៊ុន) | 1,911 | 1,864.22 | |
| តម្លៃជួញដូរ (លានរៀល) | 2,482.20 | 4,539.87 | 82.90% |
| តម្លៃជួញដូរ (ដុល្លារ) | 620,550 | 1,134,967 | |
| តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃ (លានរៀល) | 10.65 | 19.16 | 79.81% |
| តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃ (ដុល្លារ) | 2,663.30 | 4,788.89 | |

*តារាង 13.- ទិដ្ឋភាពទូទៅនៃការជួញដូរភាគហ៊ុន PPAP*

នៅក្នុងឆ្នាំ២០១៩ ថ្លៃបិទរបស់ភាគហ៊ុន PPAP ប្រែប្រួលក្នុងចន្លោះពី ៧.៦៨០ រៀល ដល់ ១២.៥០០ រៀល។ ចំពោះសកម្មភាពជួញដូរមានការថយចុះបើធៀបជាមួយនឹងឆ្នាំ២០១៨ ដែលមានទំហំជួញដូរថយចុះពី ៤៤៥.១៨០ ភាគហ៊ុន នៅក្នុងឆ្នាំ២០១៨ ដល់ ៤៤១.៨១៩ ភាគហ៊ុន នៅក្នុងឆ្នាំ២០១៩។ តម្លៃជួញដូរសរុបសម្រាប់ភាគហ៊ុន PPAP នៅក្នុងឆ្នាំ២០១៩ មានតម្លៃប្រហែល ៤.៥៣៩ លានរៀល (ប្រហែល ៤,៧៩ ពាន់ដុល្លារសហរដ្ឋអាមេរិក)។




*ក្រាហ្វិច 10.- ថ្លៃភាគហ៊ុនធៀបនឹងទំហំជួញដូររបស់ភាគហ៊ុន PPAP*

ចំពោះបរិមាណបញ្ជាទិញ-លក់សរុបរបស់ភាគហ៊ុន GTI មានចំនួន ៣.៧២២.១០៧ ភាគហ៊ុន ដែលក្នុងនោះអនុបាតបញ្ជាលក់ធៀបនឹងបញ្ជាទិញមានចំនួន ០,៥០ ដែលបង្ហាញថាវិនិយោគិនមាននិន្នាការលក់ច្រើនជាងទិញ(បរិមាណដាក់បញ្ជាលក់មានចំនួនប្រមាណ ២.៤៧០.១៦៣ ភាគហ៊ុន និងបរិមាណដាក់បញ្ជាទិញមានចំនួនប្រមាណ ១.២៥១.៩៤៤ ភាគហ៊ុន) ។ ក្នុងនោះដែរ បរិមាណបញ្ជាទិញ-លក់ សរុបមានការថយចុះប្រមាណ ៤១,៩៣% ចំណែកឯបរិមាណបញ្ជាទិញសរុបបានថយចុះប្រមាណ ៧៣,២៦% និងបរិមាណបញ្ជាលក់បានកើនឡើងប្រមាណ ៤៣,០៧% បើប្រៀបធៀបនឹងឆ្នាំ២០១៨ ផងដែរ។




*ក្រាហ្វិច 11.- បរិមាណបញ្ជាទិញ-លក់មូលបត្រ PPAP*

### ៤.៤.៣.២.៤. ភាគហ៊ុនរបស់ភ្នំពេញអេសអ៊ីហ្សិត គីអិលស៊ី (PPSP)

| ទិដ្ឋភាពទូទៅ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | បម្រែបម្រួល |
|---|---|---|---|
| មូលធនូបនីយកម្មទីផ្សារ (លានរៀល) | 208,438 | 185,438 | -11.03% |
| មូលធនូបនីយកម្មទីផ្សារ (លានដុល្លារ) | 52.11 | 46.36 | |
| ទំហំជួញដូរ (ភាគហ៊ុន) | 177,431 | 3,725,036 | 1999.43% |
| ទំហំជួញដូរជាមធ្យមប្រចាំថ្ងៃ (ភាគហ៊ុន) | 762 | 15,717.45 | |
| តម្លៃជួញដូរ (លានរៀល) | 477.20 | 8,083.29 | 1593.89% |
| តម្លៃជួញដូរ (ដុល្លារ) | 119,301 | 2,020,822 | |
| តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃ (លានរៀល) | 2.05 | 34.11 | 1565.30% |
| តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃ (ដុល្លារ) | 512.02 | 8,526.68 | |

*តារាង 14.- ទិដ្ឋភាពទូទៅនៃការជួញដូរភាគហ៊ុន PPSP*

នៅក្នុងឆ្នាំ២០១៩ ថ្លៃបិទរបស់ភាគហ៊ុន PPSP ប្រែប្រួលក្នុងចន្លោះពី ២.៩០០ រៀល ដល់ ២.៥៨០ រៀល។ ចំពោះសកម្មភាពជួញដូរមានការកើនឡើងយ៉ាងគំហុកបើធៀបជាមួយនឹងឆ្នាំ ២០១៨ ដែលមានទំហំជួញដូរកើនឡើងពី ១៧៧.៤៣១ ភាគហ៊ុន នៅក្នុងឆ្នាំ២០១៨ ដល់ ៣.៧២៥.០៣៦ ភាគហ៊ុន នៅក្នុងឆ្នាំ២០១៩ ដោយហេតុថា មានការជួញដូរមូលបត្រតាមវិធីសាស្ត្រជួញដូរតាមការចរចា (Negotiation Trading Method - NTM) ចំនួន ៣ លានភាគហ៊ុន កាលពីថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៩ ដែលស្មើនឹងប្រមាណ ៨០,៥៣% នៃទំហំជួញដូរភាគហ៊ុនសរុបនៃឆ្នាំ២០១៩។ តម្លៃជួញដូរសរុបសម្រាប់ភាគហ៊ុន PPSP នៅក្នុងឆ្នាំ២០១៩ មានតម្លៃប្រហែល ៨.០៨៣ លានរៀល (ប្រហែល ២,០២ លាន ដុល្លារសហរដ្ឋអាមេរិក)។




ក្រាហ្វិច 12.- ថ្លៃភាគហ៊ុនធៀបនឹងទំហំជួញដូររបស់ភាគហ៊ុន PPSP

ចំពោះ បរិមាណបញ្ជាទិញ-លក់សរុបរបស់ភាគហ៊ុន PPSP មានចំនួន ១៤.៣១៨.១៥៥ ភាគហ៊ុន ដែលក្នុងនោះអនុបាតបញ្ជាលក់ធៀបនឹងបញ្ជាទិញមានចំនួន ០,៧៤ ដែលបង្ហាញថាវិនិយោគិនមាននិន្នាការលក់ច្រើនជាងទិញ (បរិមាណដាក់បញ្ជាលក់មានចំនួនប្រមាណ ៩.០៩៣.១៤៦ ភាគហ៊ុន និងបរិមាណដាក់បញ្ជាទិញមានចំនួនប្រមាណ ៥.២២៥.០០៩ ភាគហ៊ុន)។ ក្នុងនោះដែរ បរិមាណបញ្ជាទិញ-លក់ សរុបមានការថយចុះប្រមាណ ១៥,៥៤% ចំណែកឯបរិមាណបញ្ជាទិញសរុបបានកើនឡើងប្រមាណ ៨៤៧% និងបរិមាណបញ្ជាលក់បានថយចុះប្រមាណ ២៣,២០% បើប្រៀបធៀបនឹងឆ្នាំ២០១៨ ផងដែរ។




*ក្រាហ្វិច 13.- បរិមាណបញ្ជាទិញ-លក់មូលបត្រ PPSP*

### ៤.៤.៣.២.៥. ភាគហ៊ុនរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ (PAS)

| ទិដ្ឋភាពទូទៅ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | បម្រែបម្រួល |
|---|---|---|---|
| មូលធនូបនីយកម្មទីផ្សារ (លានរៀល) | 866,297 | 1,663,976 | 92.08% |
| មូលធនូបនីយកម្មទីផ្សារ (លានដុល្លារ) | 216.57 | 415.99 | |
| ទំហំជួញដូរ (ភាគហ៊ុន) | 2,405,389 | 10,108,867 | 320.26% |
| ទំហំជួញដូរជាមធ្យមប្រចាំថ្ងៃ (ភាគហ៊ុន) | 10,324 | 42,653.45 | |
| តម្លៃជួញដូរ (លានរៀល) | 19,265.48 | 129,538.07 | 572.38% |
| តម្លៃជួញដូរ (ដុល្លារ) | 4,816,370 | 32,384,517 | |
| តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃ (លានរៀល) | 82.68 | 546.57 | 561.04% |
| តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃ (ដុល្លារ) | 20,671.11 | 136,643.53 | |

*តារាង 15.- ទិដ្ឋភាពទូទៅនៃការជួញដូរភាគហ៊ុន PAS*

នៅក្នុងឆ្នាំ២០១៩ ថ្លៃបិទរបស់ភាគហ៊ុន PAS ប្រែប្រួលក្នុងចន្លោះពី ១០.១០០ រៀល ដល់ ១៩.៩០០ រៀល។ ចំពោះសកម្មភាពជួញដូរមានការថយចុះបើធៀបជាមួយនឹងឆ្នាំ២០១៨ ដែលមានទំហំជួញដូរមានការកើនឡើងពី ២.៤០៥.៣៨៩ ភាគហ៊ុន នៅក្នុងឆ្នាំ២០១៨ ដល់ ១០.១០៨.៨៦៧ ភាគហ៊ុន នៅក្នុងឆ្នាំ២០១៩ ដោយហេតុថា មានការជួញដូរមូលបត្រតាមវិធីសាស្ត្រជួញដូរតាមការចរចា (Negotiation Trading Method - NTM) ចំនួន ៣ លើក។ លើកទី១ កាលពីថ្ងៃទី ២១ ខែឧសភា ចំនួន ៩.៤៣៤.៩១៦ ភាគហ៊ុន ហើយលើកទី២ កាលពីថ្ងៃទី៥ ខែកក្កដា ចំនួន ២០០.០០០ ភាគហ៊ុន និងលើកទី៣ កាលពីថ្ងៃទី ១០ ខែតុលា ចំនួន ១១.៨០០ ភាគហ៊ុន ដែលសរុបទាំងបីលើកមានចំនួន ៩.៦៤៦.៧១៦ ភាគហ៊ុន ស្មើនឹងប្រមាណ ៩៥,៤៣%នៃការជួញដូរភាគហ៊ុនសរុបនៃឆ្នាំ២០១៩។ តម្លៃជួញដូរសរុបសម្រាប់ភាគហ៊ុន PAS នៅក្នុងឆ្នាំ២០១៩ មានតម្លៃប្រហែល ១២៩.៥៣៨ លានរៀល (ប្រហែល ៣២,៣៨ លានដុល្លារសហរដ្ឋអាមេរិក)។




*ក្រាហ្វិច 14.- ថ្លៃភាគហ៊ុនធៀបនឹងទំហំជួញដូររបស់ភាគហ៊ុន PAS*

ចំពោះបរិមាណបញ្ជាទិញ-លក់សរុបរបស់ភាគហ៊ុន PAS មានចំនួន ២២.៨៩០.៩៦៨ ភាគ-ហ៊ុន ដែលក្នុងនោះអនុបាតបញ្ជាលក់ធៀបនឹងបញ្ជាទិញមានចំនួន ១,០៥ ដែលបង្ហាញថាវិនិយោគិនមាននិន្នាការលក់ប្រហាក់ប្រហែលទិញដែរ (បរិមាណដាក់បញ្ជាលក់មានចំនួនប្រមាណ ១១.៧៦៨.២៩៥ ភាគហ៊ុន និងបរិមាណដាក់បញ្ជាទិញមានចំនួនប្រមាណ ១១.១២២.៦៧៣ ភាគហ៊ុន)។ ក្នុងនោះដែរ បរិមាណបញ្ជាទិញ-លក់ សរុបមានការកើនឡើងមាណ ៦៨,៩៣% ចំណែកឯបរិមាណបញ្ជាទិញសរុបបានកើនឡើងប្រមាណ ៦២,០៤% និងបរិមាណបញ្ជាលក់បានកើនឡើងប្រមាណ ៧៦% បើប្រៀបធៀបនឹងឆ្នាំ២០១៨ ផងដែរ។




*ក្រាហ្វិច 15.- បរិមាណបញ្ជាទិញ-លក់មូលបត្រ PAS*

### ៤.៤.៣.៣.សកម្មភាពជួញដូរសញ្ញាបណ្ណរបស់ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រចំណុល

#### ៤.៤.៣.៣.១. គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ លីមីតធីត (HKL21A)

នាថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៨ កន្លងទៅនេះ **ផ.ម.ក.** បានទទួលស្វាគមន៍នូវការចុះបញ្ជីដាក់ឱ្យជួញដូរនូវសញ្ញាបណ្ណដំបូងបំផុត ដែលមានឈ្មោះថា "សញ្ញាបណ្ណសាជីវកម្មដំបូងបំផុតនៅកម្ពុជាលេខ ១" (HKL21A) បោះផ្សាយជាប្រាក់រៀល ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ លីមីតធីត។ ការបោះផ្សាយ សញ្ញាបណ្ណ HKL21A ត្រូវបានធ្វើឡើងក្នុងបរិមាណ ១,២លានសញ្ញាបណ្ណ ដែលគិតជាទឹកប្រាក់សរុបចំនួន ១២០ ពាន់លានរៀល។ វិនិយោគិនសញ្ញាបណ្ណនេះនឹងទទួលបាននូវគូប៉ុង (ការប្រាក់) ដែលបង់ប្រចាំឆមាស ក្នុងអត្រា ៨,៥០% ក្នុងមួយឆ្នាំ។ យ៉ាងណាមិញ ក្រោយពីការចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅ **ផ.ម.ក.** រួច សញ្ញាបណ្ណសាជីវកម្ម (Corporate Bond) របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហត្ថាកសិករ (HKL) មានវិនិយោគិនរូបវន្តបុគ្គលបញ្ជាទិញសរុបចំនួន ២៨០ ឯកតា នៅថ្លៃជាមធ្យមចំនួន ១០២.៧៥៧ រៀល ដោយពុំទាន់មានវិនិយោគិនបញ្ជាលក់នោះទេ។ ដូចនេះ សញ្ញាបណ្ណសាជីវកម្ម (Corporate Bond) របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហត្ថាកសិករ (HKL) ពុំទាន់មានការជួញដូរនៅឡើយទេ។

#### ៤.៤.៣.៣.២. គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិល អូ អិល ស៊ី (LOLC)

បន្ទាប់ពីការចុះបញ្ជីលក់សញ្ញាបណ្ណសាជីវកម្ម របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ លីមីតធីត **ផ.ម.ក.** បានសម្រេចចុះបញ្ជីសញ្ញាបណ្ណសាជីវកម្ម របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអិលអូ- អិលស៊ី កាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៩។ សញ្ញាបណ្ណសាជីវកម្មដែលបានចុះបញ្ជីលក់នេះ មានឈ្មោះថា "សញ្ញាបណ្ណសាជីវកម្ម អិល អូ អិល ស៊ី មានការការពារហានិភ័យអត្រាប្តូរប្រាក់ - Fx-indexed Bond 2019-2022 No.1" ដែលមានអត្រាគូប៉ុង ៨% ក្នុងមួយឆ្នាំ និង "សញ្ញាបណ្ណសាជីវកម្ម អិល អូ អិល ស៊ី មិនមានការការពារហានិភ័យអត្រាប្តូរប្រាក់" ដែលមានអត្រាគូប៉ុង ៩% ក្នុងមួយឆ្នាំ។ សញ្ញាបណ្ណសាជីវកម្មនេះ មានឥណប្រតិទានរយៈពេល ៣ឆ្នាំ ដោយគិតចាប់ពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៩ ដល់ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២។ គួរបញ្ជាក់ផងដែរថា ចាប់តាំងពីការចុះបញ្ជីលក់នៅ **ផ.ម.ក.** រួចមក សញ្ញាបណ្ណនេះ ពុំទាន់មានការជួញដូរនៅឡើយទេ។

#### ៤.៤.៣.៣.៣. ធនាគារ វឌ្ឍនៈ អាស៊ីចំកាត់ (ABA)

នាថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ សញ្ញាបណ្ណសាជីវកម្មរបស់ធនាគារ វឌ្ឍនៈ អាស៊ីចំកាត់ (ABA) ត្រូវបានសម្រេចឱ្យចុះបញ្ជីជាផ្លូវការនៅ **ផ.ម.ក.**។ សញ្ញាបណ្ណសាជីវកម្មនេះ មានឈ្មោះថា

"សញ្ញាបណ្ណសាជីវកម្ម អេ ប៊ី អេ" ដែលមានអត្រាគូប៉ុងចំនួន ៧,៧៥% ក្នុងមួយឆ្នាំ ជាមួយនឹងឥណ-ប្រតិទានរយៈពេល ៣ឆ្នាំ ដោយគិតចាប់ពីថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ រហូតដល់ ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២២។ គួរបញ្ជាក់ផងដែរថា ធនាគារ វឌ្ឍនៈ អាស៊ីចំកាត់ គឺជាធនាគារពាណិជ្ជដំបូងបង្អស់ដែលបានបោះផ្សាយលក់សញ្ញាបណ្ណសម្រាប់វិនិយោគិនស្ថាប័ននិងវិនិយោគិនរូបវន្តបុគ្គល ជាមួយនឹងអត្រាគូប៉ុង ៧,៧៥% ដែលខ្ពស់ជាងអត្រាដាក់ប្រាក់បញ្ញើមានកាលកំណត់របស់ធនាគារពាណិជ្ជ។ បន្ថែមពីនេះ សញ្ញាបណ្ណនេះទទួលបានចំណាត់ថ្នាក់លទ្ធភាពសង "B" ចេញដោយភ្នាក់ងារវាយតម្លៃលទ្ធភាពសង S&P Global Ratings។ គិតត្រឹមចុងឆ្នាំ២០១៩ បន្ទាប់ពីបានចុះបញ្ជីនៅ **ផ.ម.ក.** សញ្ញាបណ្ណសាជីវកម្ម អេ ប៊ី អេ មានការជួញដូរចំនួន ១៨០ ឯកតា ស្មើនឹងទំហំទឹកប្រាក់ ១៨ លានរៀល។

### ៤.៤.៣.៤. ចំនួនវិនិយោគិន

បើយើងគិតត្រឹមចុងឆ្នាំ២០១៩ ផ្សារមូលបត្រកម្ពុជាមានវិនិយោគិនទាំងជនជាតិខ្មែរ និងជនជាតិបរទេសសរុបចំនួន ២២.៤៤៦ ដែលក្នុងនោះមានវិនិយោគិនរូបវន្តបុគ្គលសរុបចំនួន ២២.៣២៦ និងវិនិយោគិននីតិបុគ្គលមានសរុបចំនួន ១២០។

| | | **២០១៨** | **២០១៩** | **បម្រែបម្រួល** | **សរុបឆ្នាំ ២០១៩** |
|---|---|---|---|---|---|
| **រូបវន្តបុគ្គល** | សញ្ជាតិខ្មែរ | 17,339 | 18,537 | 6.91% | <u>22,326</u> |
| | សញ្ជាតិ បរទេស | 3,099 | 3,789 | 22.27% | |
| **នីតិបុគ្គល** | សញ្ជាតិខ្មែរ | 25 | 26 | 4.00% | <u>120</u> |
| | សញ្ជាតិ បរទេស | 86 | 94 | 9.30% | |
| **សរុប** | | <u>20,549</u> | <u>22,446</u> | 9.23% | <u>22,446</u> |

*តារាង 16.- ស្ថិតិបង្ហាញពីចំនួនវិនិយោគិននៅក្នុងឆ្នាំ២០១៨-២០១៩*

## ៤.៥. ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយនៃការជួញដូរមូលបត្រនៅកម្ពុជា

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវទាក់ទងនឹងការជួញដូរមូលបត្រ នៅផ្សារមូលបត្រកម្ពុជាមកនាងខ្ញុំបានមើលឃើញចំណុចល្អជាច្រើន និងចំណុចខ្វះខាតមួយចំនួន។ ខាងក្រោមនេះជាការយល់ឃើញ និងការវិភាគរបស់ខ្ញុំបាទផ្ទាល់ខ្លួនដោយផ្អែកតាមការរយៈទិន្នន័យទីផ្សារ ដូចដែលបានបង្ហាញ ខាងលើ។

### ៤.៥.១ ចំណុចខ្លាំង

- ទំហំជួញដូរមានការកើនឡើង បើធ្វើការប្រៀបធៀបពីចុងឆ្នាំ២០១៨ នឹងដើមឆ្នាំ២០១៩
- មានប្រព័ន្ធជួញដូរចល័ត (MTS) ដែលបង្កភាពងាយស្រួល ឆាប់រហ័ស និងសុវិត្ថភាពដល់វិនិយោគិនក្នុងដាក់បញ្ជាទិញ-លក់របស់ពួកគេ។
- ការដាក់បញ្ជាទិញ-លក់របស់វិនិយោគិនមានសកម្មភាពជារៀងរាល់ថ្ងៃសម្រាប់ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិទាំងប្រាំ
- មានការចូលរួមពីសំណាក់វិនិយោគិនទាំងក្នុងស្រុក និងក្រៅស្រុក
- ដោយសារតែក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាបានសហការជាមួយក្រុមហ៊ុនមូលបត្រកូរ៉េ ហេតុនេះហើយធ្វើអោយប្រតិបត្តិការនានាមានភាពច្បាស់លាស់ត្រឹមត្រូវ
- មានប្រព័ន្ធបច្ចេកវិទ្យាទំនើបក្នុងការដាក់អនុវត្តក្នុងប្រតិបត្តិការទីផ្សារ យន្តការផាត់ទាត់ និងទូទាត់ព្រមទាំងរក្សាទុកមូលបត្រ។
- ការដាក់ឱ្យអនុវត្តនូវច្បាប់ បទបញ្ញត្តិ វិធានការ និងប្រកាសដែលទាក់ទងនឹងប្រតិបត្តិទីផ្សារនិងដំណើការជួញដូរមានប្រសិទ្ធភាព។
- បុគ្គលិកមានសមត្ថភាព ចំណេះដឹង ការទទួលខុសត្រូវប្រកបដោយសីលធម៌វិជ្ជាជីវៈខ្ពស់ ព្រមទាំងមានរចនាសម្ព័ន្ធមុខងារច្បាស់លាស់
- ការដាក់បង្ហាញព័ត៌មានទាក់ទងនឹងមូលបត្រ អ្នកចូលរួមក្នុងទីផ្សារ និងទិន្នន័យទីផ្សារតាម រយៈគេហទំព័រគេហទំព័រក្បោះក្បាយ ដែលជាហេតុងាយស្រួលដល់មហាជនក្នុងការទទួលយកព័ត៌មានបន្ថែម។
- មានរៀបចំសិក្ខាសិលាអប់រំបន្ថែមជារៀងរាល់ខែ និងសិក្ខាសិលាបណ្តុះបណ្តាល តាមខេត្តមួយចំនួន

- ការបើកឱ្យមានកម្មវិធីប្រកួតប្រជែងដល់សិស្សនិស្សិត និងសាធារណៈជនក្នុងការអនុវត្តទិញលក់មូលបត្រនៅលើទីផ្សារ ក្នុងគោលបំណងបញ្ជ្រាបព័ត៌មានឱ្យកាន់តែមានភាពទូលំទូលាយ។

### ៤.៥.២. ចំណុចខ្សោយ

ជាការពិតណាស់ ទន្ទឹមនឹងភាពល្អប្រសើរច្រើនរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា រមែងតែងមាននូវចំណុចខ្វះខាតបន្តិចបន្តួច របស់ក្រុមហ៊ុនដូចគ្នាដែរ។ ខាងក្រោមនេះជាចន្លោះបន្តិចបន្តួចដែលក្រុមហ៊ុនមាន៖

- មិនមាន កម្មវិធី (Application) សម្រាប់ទូរសព្ទដៃ
- ចំនួនវិនិយោគិនមានច្រើន ប៉ុន្តែវិនិយោគិនដែលចូលរួមវិនិយោគនៅមានកម្រិតនូវឡើយ
- មានរយៈពេលនៃការជួញដូរតិចជាងប្រទេសនៅក្នុងតំបន់
- ជាវិស័យថ្មីសម្រាប់សាធារណៈជនទូទៅ ហើយការយល់ដឹងពីវិស័យមិនសូវទូលំទូលាយ
- ក្រុមហ៊ុនចុះបញ្ជីក្នុងក្រុមហ៊ុនផ្សារមូលបត្រមានចំនួនតិច ដែលជាហេតុធ្វើឱ្យមានជម្រើសតិចក្នុងការជ្រើសរើស
- កង្វះទំនុកចិត្តពីសាធារណជនចំពោះ ក្រុមហ៊ុនចុះបញ្ជី និងថ្លៃភាគហ៊ុននៅលើទីផ្សារ
- ចំនួននៃប្រតិបត្តិការជួញដូរមានកម្រិតទាបនៅឡើយ ដែលនាំឱ្យវិនិយោគិនខ្វះការទុក ចិត្តលើក្រុមហ៊ុនមូលបត្រ និងដំណើការទីផ្សារ។

# សេចក្ដីសន្និដ្ឋាន
# និង
# ការផ្ដល់អនុសាសន៍

# សេចក្តីសន្និដ្ឋាន និង ការផ្តល់អនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវអំពីដំណើរការទីផ្សារមូលបត្រនៅកម្ពុជា ដែលនៅក្នុងនោះមានការផ្តោតសំខាន់ទៅលើប្រតិបត្តិការជួញដូរមូលបត្រនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា រួចមក យើងសង្កេតឃើញថា គិតត្រឹមបច្ចុប្បន្ន **ផ.ម.ក.** មានអាយុកាលជិត ៩ឆ្នាំ មកហើយ ដែលមានក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិចំនួន ៥ និងក្រុមហ៊ុនចុះបញ្ជីលក់មូលបត្របំណុលចំនួន៣ ដែលក្រុមហ៊ុនទាំងនោះបានប្រមូលសាច់ប្រាក់ពីទីផ្សារសរុបចំនួន ប្រមាណ ១៥១ លានដុល្លារអាមេរិក។ យោងតាមទិន្នន័យទីផ្សារក្នុងឆ្នាំ ២០១៩ យើងសង្កេតឃើញថា ប្រតិបត្តិការនៅលើទីផ្សារមានចលនាល្អដែលមានការចូលរួមពីវិនិយោគិនជារៀងរាល់ថ្ងៃទាំងផ្នែកតម្រូវការ (បញ្ជាទិញ) និងការផ្គត់ផ្គង់ (បញ្ជាលក់)។ ចំពោះទំហំមូលធនូបនីយកម្មទីផ្សារសរុប (Market Capitalization) មានចំនួន ២.៨០៥.៨០៧ លានរៀល (ប្រហែល ៧០១,៤៥ លានដុល្លារសហរដ្ឋអាមេរិក) ប្រហែលស្មើនឹង ២,៥៨% នៃ GDP ប្រទេសកម្ពុជាសរុប បានកើនឡើង ៥៨,៣៧% និងសន្ទស្សន៍ **ផ.ម.ក.** ស្មើនឹង ៧៦១,៧៣ (Price Index/Current Index) ក៏បានកើនឡើង ៤០% ផងដែរ ធៀបនឹងឆ្នាំ២០១៨។ ចំពោះទំហំជួញដូរសរុបមានចំនួន ១៥.៤៨៩.៩០៥ ភាគហ៊ុន ដែលមានតម្លៃប្រហែល ១៩៨.៨៧៨,៦៤ លានរៀល (ប្រហែល ៣៧,២២ លានដុល្លារសហរដ្ឋអាមេរិក) ដោយទំហំជួញដូរបានកើនឡើងប្រមាណ ៣០៩,៦៥% និងតម្លៃជួញដូរបានកើនឡើងប្រមាណ ៤៩៧,៨៥% ប្រៀបធៀបជាមួយនឹងឆ្នាំ២០១៨។ ដោយឡែកចំពោះការជួញដូរមូលបត្របំណុល ហាក់បីដូចជាមិនមានសកម្មភាពសោះឡើយ ក្នុងចំណោមសញ្ញាបណ្ណសាជីវកម្មទាំង៣ មានតែសញ្ញាបណ្ណសាជីវកម្មរបស់ធនាគារ វឌ្ឍនៈ អាស៊ីចំកាត់ (ABA) មួយប៉ុណ្ណោះដែលមានការជួញដូរចំនួន ១៨០ ឯកតា ក្នុងឆ្នាំ២០១៩នេះ។

ម្យ៉ាងទៀត ដើម្បីធ្វើការជួញដូរនៅ **ផ.ម.ក.** បាន វិនិយោគិនតម្រូវឱ្យមានលេខអត្តសញ្ញាណវិនិយោគិន និងគណនីជួញដូរជាមុនសិន។ ហើយវិនិយោគិនគ្រាន់តែស្វែងយល់បន្ថែមអំពីវិធានទាំងបី ដែលរួមមាន វិធានប្រតិបត្តិការទីផ្សារមូលបត្រ, វិធានជាត់ទាត់និងទាត់មូលបត្រ និងវិធានរក្សារទុកមូលបត្រ របស់ **ផ.ម.ក.** ដោយផ្តោតលើសំខាន់លើ ពេលវេលាជួញដូរ វិធីសាស្រ្តជួញដូរ ប្រភេទបញ្ជា ព័ត៌មានលម្អិតពេលដាក់បញ្ជា ឯកត្តាគម្លាតថ្លៃជួញដូរ ដើម្បីធ្វើការជួញក្នុងប្រព័ន្ធរបស់ប្រតិបត្តិករទីផ្សារមូលបត្រ និងរង់ចាំការជាត់ទាត់និងទូទាត់ របស់ប្រតិបត្តិករជាត់ទាត់ និងទូទាត់មូលបត្រ ព្រមទាំងការរក្សាទុកមូលបត្រពីប្រតិបត្តិកររក្សាទុកមូលបត្រផងដែរ។

សរុបសេចក្ដីមក ប្រតិបត្តិការជួញដូររបស់ **ផ.ម.ក.** មានលក្ខណៈមិនសូវជាស្មុគស្មាញនោះទេសម្រាប់វិនិយោគិន ប៉ុន្តែសកម្មភាពជួញដូរនៅមានកម្រិតទាប ដោយសារតែជម្រើសផលិតផល របស់ក្រុមហ៊ុនចុះបញ្ជីមានចំនួនតិច និងវិនិយោគិនមិនទាន់ស្គាល់ពីទីផ្សារនេះច្បាស់លាស់នូវឡើយទេ ដែលជាហេតុធ្វើឱ្យទំហំមូលធនូបនីយកម្មទីផ្សារយើងតូចបើធៀបនឹងប្រទេសក្នុងតំបន់។

## ២. ការផ្ដល់អនុសាសន៍

យោងតាមលទ្ធផលនៃការសិក្សាស្រាវជ្រាវ អស់មួយរយៈពេលកន្លងមក យើងពិតជាឃើញថា ប្រតិបត្តិការជួញដូរមូលបត្រនៅផ្សារមូលបត្រកម្ពុជា ពិតមានភាពវិជ្ជមាន និងបានអភិវឌ្ឍខ្លួនយ៉ាងឆាប់រហ័ស ក៏ប៉ុន្តែទន្ទឹមនឹងគ្នាយើងក៏បានវិភាគរកឃើញនូវចំណុចអវិជ្ជមានមួយចំនួនតូចលេចឡើង ដែលក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា និងគណៈកម្មការមូលបត្រកម្ពុជា គប្បីតែធ្វើការគិតពិចារណាផងដែរ។ នាងខ្ញុំសូមការអនុញ្ញាតផ្ដល់ជាគំនិត និងមតិយោបល់ខ្លះៗ ទៅលើចំណុចមួយចំនួនដូចខាងក្រោម ដើម្បីជួយឲ្យការជួញដូរមូលបត្រកាន់តែមានសក្ដិសិទ្ធិភាព និងប្រសិទ្ធិភាពខ្ពស់បន្ថែមទៀត៖

- អភិវឌ្ឍកម្មវិធី (Application) នៅលើទូរសព្ទដើម្បីបង្កើនភាពកាន់តែងាយស្រួលដល់វិនិ-យោគិន
- ជំរុញការជួញដូរឧបករណ៍ហិរញ្ញវត្ថុនៅលើទីផ្សារ ឲ្យកាន់តែមានភាពប្រសើរឡើងបន្ថែមទៀត ហើយជាពិសេសនោះគឺការជួញដូរមូលបត្របំណុល
- ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាគួរតែបន្ថែមម៉ោងជួញដូរឱ្យបានយូរជាងពេលបច្ចុប្បន្នឱ្យស្របតាមប្រទេសនៅក្នុងតំបន់ (weekend)
- គណៈកម្មការមូលបត្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា បន្តជំរុញ និងមានយុទ្ធ-សាស្ត្រទាក់ទាញយ៉ាងណា ដើម្បីឲ្យមានការកើនឡើងនូវចំនួនក្រុមហ៊ុនចុះបញ្ជីដែលរួមបញ្ចូលទាំងគ្រឹះ ស្ថានសាធារណៈនិងក្រុមហ៊ុនឯកជន ព្រមទាំងការវិនិយោគនៅលើទីផ្សារបន្ថែមទៀត
- បន្តការផ្សព្វផ្សាយ និងបង្កើតជាវេទិកា កម្មវិធីសិក្ខាសាលា កម្មវិធីប្រកួតប្រជែងជួញដូរភាគហ៊ុន និងតាមរយៈកម្មវិធីផ្សេងទៀតដើម្បីឱ្យវិនិយោគិនមានចំណេះដឹងកាន់តែច្បាស់លាស់ មុននឹងឈានចូលប្រលូកក្នុងវិស័យមួយនេះ។

# ឯកសារយោង

# ឯកសារយោង

## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត


- ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន, លេខ នស/រកម/១០០៧/០២៨, ១៩ តុលា ២០០៧
- អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- ប្រកាសស្តីពីការដាក់ឲ្យអនុវត្តវិធានប្រតិបត្តិការទីផ្សារមូលបត្រលេខ០០២/២០ គ.ម.ក./ប្រ.ក.,ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០
- ប្រកាសស្តីពីការដាក់ឲ្យអនុវត្តវិធានប្រតិបត្តិការរក្សាទុកមូលបត្រ, លេខ០០៤/២០គ.ម.ក ប្រ.ក.,១០ កុម្ភៈ ២០២០,ជំពូក១,២និង៣
- ប្រកាសស្តីពីការដាក់ឲ្យអនុវត្តវិធានប្រតិបត្តិការជាត់ទាត់ និងទូទាត់មូលបត្រ, លេខ០១៨/១៧គ.ម.កប្រ.ក.,២៦ ធ្នូ ២០១៧,ជំពូក២និង៣
- ប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណដល់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារមូលបត្រ, លេខ ០០៩ គ.ម.ក. ប្រ.ក.,ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៩
- វិធាននិងបទប្បញ្ញត្តិរបស់ **ផ.ម.ក**


## សៀវភៅ


- គណៈកម្មការមូលបត្រកម្ពុជា. ២០១៧. មគ្គុទេសក៍ស្តីពីការស្វែងយល់ពីហិរញ្ញប្បទានតាមរយៈការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ (ភាគហ៊ុន) ជាសាធារណៈនៅប្រទេសកម្ពុជា
- នាយកដ្ឋានត្រួតពិនិត្យប្រតិបត្តិការទីផ្សារមូលបត្រ, ២០១៨ ព្រឹត្តិបត្រស្តីពីការជួញដូរមូលបត្រនៅទីផ្សារមូលបត្រកម្ពុជា ប្រចាំត្រីមាសទី១, ២,៣ និង ៤ ឆ្នាំ២០១៨
- បៀន សាំង, ២០១១, មូលដ្ឋានគ្រឹះនៃទីផ្សារមូលបត្រ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- សួន ចំរើន, ២០១៧, ទីផ្សារ និងស្ថាប័នហិរញ្ញវត្ថុ១,
- ហ៊ា លីគា. ២០១៧, កិច្ចដំណើរការទីផ្សារបន្ទាប់. មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៤, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- ញៀន វណ្ណៈ. ២០១៥. នីតិទីផ្សារមូលបត្រកម្ពុជា

**គេហទំព័រ**

- គេហទំព័រគណៈកម្មការមូលបត្រកម្ពុជា www.secc.gov.kh (ចូលទស្សនានៅថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២០)
- គេហទំព័រផ្សារមូលបត្រកម្ពុជា http://www.csx.com.kh (ចូលទស្សនាថ្ងៃទី០២ ខែ មិថុនា ឆ្នាំ២០២០)

# ឧបសម្ព័ន្ធ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា

លេខ:.....០០៦/២០.....គ.ម.ក./ប្រ.ក.

# ប្រកាស

# ស្ដីពី

# ការដាក់ឱ្យអនុវត្តនូវការកែប្រែវិធានប្រតិបត្តិការរក្សាទុកមូលបត្រ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

* * * * *

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្ដីពីការអនុវត្តច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញប្រកាសលេខ ០១១ គ.ម.ក.ប្រក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៩ ស្ដីពីការផ្ដល់ការអនុញ្ញាតធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ
- បានឃើញប្រកាសលេខ ០០៤ គ.ម.ក.ប្រ.ក. ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០ ស្ដីពីខ្លឹមសារគោលនៃវិធានប្រតិបត្តិការរបស់ទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងសេវារក្សាទុកមូលបត្រ

- បានឃើញប្រកាសលេខ ០១៩/១៧ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្ត វិធានប្រតិបត្តិការរក្សាទុកមូលបត្រ
- យោងតាមសំណើសុំអនុម័តលើការកែប្រែវិធានប្រតិបត្តិការរក្សាទុកមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៩
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៩

## សម្រេច

**ប្រការ១.-**

ដាក់ឱ្យអនុវត្តនូវប្រការ១៣ ថ្មី នៃវិធានប្រតិបត្តិការរក្សាទុកមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ ជំនួសប្រការ១៣ នៃវិធានប្រតិបត្តិការរក្សាទុកមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដែលជាឧបសម្ព័ន្ធនៃប្រកាសលេខ ០១៩/១៧ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការរក្សាទុកមូលបត្រ។

**ប្រការ២.-**

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា ប្រធាននាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត ប្រធាននាយកដ្ឋាន-អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា សមាជិក និងអ្នកចូលរួមក្នុងទីផ្សារមូលបត្រ ព្រមទាំងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃចន្ទ ១ រោច ខែ មាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**និងជាប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល ÷**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យសម្តេច លោកជំទាវ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី

"ដើម្បីជូនជ្រាប"
- ដូចប្រការ ២

"ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ឧបសម្ព័ន្ធប្រកាសលេខ០០៤៥/២០.ស.ស.ក.**

**ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ២០២០**

**ការកែប្រែវិធានប្រតិបត្តិការរក្សាទុកមូលបត្រ**

**របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា**

**ប្រការ១៣.ថ្មី.- ថ្លៃសេវាប្រតិបត្តិការរក្សាទុកមូលបត្រ**

សមាជិក ឬអ្នកចូលរួមត្រូវបង់ប្រាក់ថ្លៃសេវាជូន ផ.ម.ក. ដូចខាងក្រោម ÷

១-ថ្លៃសេវារក្សាទុកមូលបត្រ÷ ជាថ្លៃសម្រាប់ការដាក់ផ្ញើមូលបត្រដែលស្ថិតក្នុងនីតិវិធីនៃការបោះផ្សាយលក់មូលបត្រជាសាធារណៈ និងមូលបត្រដែលជាកម្មវត្ថុនៃសំណើលក់ជាឯកជន។ ថ្លៃសេវារក្សាទុកមូលបត្រប្រចាំខែ ត្រូវបង់នៅថ្ងៃទី១០ នៃខែបន្ទាប់ពីខែដែលថ្លៃសេវានោះបានកើតឡើងតាមលក្ខខណ្ឌដូចខាងក្រោម ÷

ក-អត្រា២០ (ម្ភៃ) រៀលលើមូលដ្ឋាននៃទឹកប្រាក់ ១០.០០០.០០០ (ដប់លាន) រៀល។ ក្នុងករណីនេះ ថ្លៃសេវាត្រូវកំណត់យកលើមូលដ្ឋានសមតុល្យប្រចាំថ្ងៃ ដែលបង្ហាញជូននៅក្នុងសៀវភៅគណនីមូលបត្រ។ ថ្លៃនេះមិនត្រូវលើសពី ១២០.០០០ (មួយរយម្ភៃពាន់) រៀលក្នុងមួយថ្ងៃឡើយ។

ខ-អ្នកត្រូវបង់ប្រាក់ជាសមាជិក ឬអ្នកចូលរួមដែលស្នើសុំដាក់ផ្ញើ។

២-ថ្លៃសេវាផ្ទេរមូលបត្ររវាងគណនី (Book Entry Fee) :

ក-ថ្លៃសេវាការផ្ទេរមូលបត្ររវាងគណនី ត្រូវគណនាលើមូលដ្ឋានទឹកប្រាក់នៃការជួញដូរដែលបានទូទាត់ តាមអត្រា ៥/១០.០០០ (ប្រាំភាគមួយម៉ឺន)ឬ0,0៥% (សូន្យក្បៀសសូន្យប្រាំភាគរយ) ចំពោះមូលបត្រកម្មសិទ្ធិ និង១,២៥/១០.០០០ (មួយក្បៀសម្ភៃប្រាំភាគមួយម៉ឺន) ឬ0,0១២៥% (សូន្យក្បៀសសូន្យមួយរយម្ភៃប្រាំភាគរយ) ចំពោះមូលបត្របំណុល ហើយទឹកប្រាក់ថ្លៃសេវាត្រូវកាត់យកមួយខ្ទង់ក្រោយក្បៀស។

ខ-អ្នកត្រូវបង់ថ្លៃសេវាជាសមាជិក ឬអ្នកចូលរួមដែលពាក់ព័ន្ធនឹងប្រតិបត្តិការផ្ទេរមូលបត្រដែលដាក់ផ្ញើ។

គ-ពេលវេលាបង់ថ្លៃសេវានៅម៉ោង ៨:៣០ ព្រឹក នៅកាលបរិច្ឆេទទូទាត់។

៣-ថ្លៃសេវាផ្សេងៗ :

ក-ថ្លៃសេវានៃការផ្ទេរមូលបត្រដែលដាក់ផ្ញើ មិនកើតចេញពីការជួញដូររួមមាន÷

- ការផ្ទេរមូលបត្រពីគណនីមួយទៅគណនីមួយទៀតរបស់បុគ្គលតែម្នាក់÷ថ្លៃសេវានៃការផ្ទេរគឺស្មើនឹង ១០០.០០០(មួយរយពាន់) រៀលក្នុងមួយប្រតិបត្តិការ ។
- ការផ្ទេរមូលបត្រដោយមូលហេតុសន្តតិកម្ម ប្រទានកម្មរវាងឪពុកម្តាយ ប្តីប្រពន្ធ កូន និងចៅដោយមានមូលហេតុត្រឹមត្រូវ ឬសេចក្តីសម្រេចរបស់តុលាការ÷ ថ្លៃសេវាត្រូវគណនាលើមូលដ្ឋានថ្លៃទីផ្សារនៃមូលបត្រ សរុបក្នុងថ្ងៃប្រតិបត្តិការផ្ទេរតាមអត្រា ៥/១០.០០០ (ប្រាំភាគមួយម៉ឺន)ឬ០,០៥% (សូន្យក្បៀសសូន្យប្រាំភាគរយ) ក្នុងមួយប្រតិបត្តិការដែលថ្លៃសេវានេះមិនត្រូវលើសពី ២០.០០០.០០០(ម្ភៃលាន) រៀល និងទាបបំផុតត្រឹម ១០០.០០០(មួយរយពាន់) រៀលក្នុងមួយប្រតិបត្តិការ។
- សមាជិក ឬអ្នកចូលរួម ដែលដាក់ផ្ញើមូលបត្រត្រូវបង់ថ្លៃសេវានេះជូនប្រតិបត្តិកររក្សាទុកមូលបត្រនៃ ផ.ម.ក នៅពេលស្នើសុំផ្ទេរមូលបត្រ ។

ខ-ថ្លៃសេវានៃការដកមូលបត្រដែលដាក់ផ្ញើគឺ ២០០.០០០ (ពីររយពាន់) រៀលក្នុងមួយប្រតិបត្តិការ។ សមាជិកឬអ្នកចូលរួមដែលដាក់ផ្ញើមូលបត្រ ត្រូវបង់សេវាថ្លៃនេះជូនប្រតិបត្តិកររក្សាទុកមូលបត្រនៃ ផ.ម.ក. នៅពេលស្នើសុំដកមូលបត្រ ។

* * * * *

**វគ្គ ០.១.៣**

- **ឧបសម្ព័ន្ធប្រកាសលេខ ០១៧/១៧ គ.ម.ក./ប្រ.ក. ចុះថ្ងៃអង្គារ ៩កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ដែលត្រូវនឹងថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការទីផ្សារមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា**
- **ឧបសម្ព័ន្ធប្រកាសលេខ ០០៣/១៩ គ.ម.ក./ប្រ.ក. ចុះថ្ងៃអង្គារ ៦កើត ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ដែលត្រូវនឹងថ្ងៃទី ០៦ ខែសីហា ឆ្នាំ២០១៩ ស្តីពីការដាក់ឱ្យអនុវត្តនូវការកែប្រែវិធានប្រតិបត្តិការទីផ្សារមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា**
- **ឧបសម្ព័ន្ធប្រកាសលេខ ០០២/២០ គ.ម.ក./ប្រ.ក. ចុះថ្ងៃចន្ទ ២ រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ដែលត្រូវនឹងថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីការដាក់ឱ្យអនុវត្តនូវការកែប្រែវិធានប្រតិបត្តិការទីផ្សារមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា**

# វិធានប្រតិបត្តិការទីផ្សារមូលបត្រ
# របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

* * * * *

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

### ប្រការ ១.- គោលបំណង

វិធាននេះមានគោលបំណងកំណត់ពីវិធីសាស្រ្ត យន្តការ នីតិវិធី និងការគ្រប់គ្រងការជួញដូរមូលបត្រនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (សរសេរកាត់ថា **ផ.ម.ក.**) ស្របតាមច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

### ប្រការ ២ -និយមន័យ

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់នៅក្នុងវិធាននេះ ត្រូវបានកំណត់នៅក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រម ដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន÷

- **សមាជិក** សំដៅដល់ក្រុមហ៊ុនមូលបត្រ ដែលទទួលបានអាជ្ញាបណ្ណពីគណៈកម្មការមូលបត្រកម្ពុជា (សរសេរកាត់ថា **គ.ម.ក.**) ហើយជាសមាជិកនៃប្រតិបត្តិករទីផ្សារមូលបត្ររបស់ **ផ.ម.ក.** និងមានសិទ្ធិប្រើប្រាស់នូវប្រព័ន្ធជួញដូរនិងប្រព័ន្ធកុំព្យូទ័រមួយចំនួនទៀតរបស់ **ផ.ម.ក.**។

- **បញ្ជា** សំដៅដល់បញ្ជាទិញ ឬលក់មូលបត្រដោយសមាជិក ដើម្បីធ្វើការជួញដូរមូលបត្រនៅប្រតិបត្តិករទីផ្សារមូលបត្រនៃ **ផ.ម.ក.**។

- **ថ្លៃជួញដូរ** សំដៅដល់ថ្លៃដែលទទួលបានពីការផ្គូផ្គងបញ្ជានៅក្នុងប្រព័ន្ធជួញដូររបស់ប្រតិបត្តិករទីផ្សារមូលបត្រនៃ **ផ.ម.ក.**។

- **ថ្លៃចុងក្រោយ** សំដៅដល់ថ្លៃជួញដូរចុងក្រោយ ឬថ្លៃមូលដ្ឋាន ករណីគ្មានថ្លៃជួញដូរនៅថ្ងៃជួញដូរនីមួយៗ។

- **ថ្លៃមូលដ្ឋាន** សំដៅដល់ថ្លៃគោលសម្រាប់គណនាដែនកំណត់ថ្លៃក្នុងការជួញដូរមូលបត្រប្រចាំថ្ងៃ។

- **ថ្លៃដុល** (Dirty Price) សំដៅដល់ថ្លៃនៃមូលបត្របំណុល ដែលគិតបញ្ចូលនូវការប្រាក់បង្គរ (Accrued Interest)។

- **ថ្លៃបើក** សំដៅដល់ថ្លៃជួញដូរដំបូងនៃមូលបត្រនៅថ្ងៃជួញដូរនីមួយៗ។

- **ថ្លៃបិទ** សំដៅដល់ថ្លៃដែលត្រូវបានកំណត់នៅពេលបិទទីផ្សារនៅថ្ងៃជួញដូរនីមួយៗ ដូចខាងក្រោម÷

១-ថ្លៃជួញដូរចុងក្រោយ ឬ

២-ថ្លៃពិសេស ឬ

៣-ថ្លៃបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង ក្នុងករណីគ្មានការជួញដូររហូតដល់ពេលបិទទីផ្សារ និងគ្មានថ្លៃពិសេស នៅថ្ងៃជួញដូរលើកដំបូង ឬ

៤-ថ្លៃមូលដ្ឋាន ក្នុងករណីគ្មានការជួញដូររហូតដល់ម៉ោងបិទទីផ្សារ និងគ្មានថ្លៃពិសេស។

- **ថ្លៃពិសេស** សំដៅដល់ថ្លៃដូចខាងក្រោម ក្នុងករណីមូលបត្រកម្មសិទ្ធិមិនត្រូវបានអនុវត្តការជួញដូររហូតដល់ម៉ោងបិទទីផ្សារ÷

១-ថ្លៃល្អបំផុតនៃសំណើលក់ (Best Ask) ដែលថ្លៃនៃសំណើលក់នេះទាបជាងថ្លៃមូលដ្ឋាន ឬថ្លៃបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង សម្រាប់ថ្ងៃជួញដូរលើកដំបូង ឬ

២-ថ្លៃល្អបំផុតនៃសំណើទិញ (Best Bid) ដែលថ្លៃនៃសំណើទិញនេះខ្ពស់ជាងថ្លៃមូលដ្ឋាន ឬថ្លៃបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង សម្រាប់ថ្ងៃជួញដូរលើកដំបូង ។

- **ថ្លៃបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង** (IPO Price) សំដៅដល់ថ្លៃមូលបត្រកម្មសិទ្ធិដែលបានកំណត់នៅក្នុងឯកសារផ្តល់ព័ត៌មាន ដែលទទួលបានការអនុញ្ញាត និងចុះបញ្ជីជាស្ថាពរនៅ **គ.ម.ក.**។

- **មូលបត្រចុះបញ្ជីលក់លើកដំបូង** (Initially Listed Securities) សំដៅដល់មូលបត្រដែលត្រូវបានចុះបញ្ជី សម្រាប់ជួញដូរជាផ្លូវការនៅ**ផ.ម.ក.**បន្ទាប់ពីត្រូវបានបោះផ្សាយលក់ជាសាធារណៈលើកដំបូង។

- **ថ្លៃរំពឹងទុក** (Expected Price) សំដៅដល់ថ្លៃជួញដូររំពឹងទុកដែលទទួលបានពីការផ្គូផ្គងបញ្ជាជាបន្តបន្ទាប់នៅក្នុងអំឡុងវគ្គបើក និងវគ្គបិទ ដោយប្រើវិធីសាស្ត្រដេញថ្លៃដោយយកថ្លៃតែមួយ ។

- **បរិមាណរំពឹងទុក** (Expected Volume) សំដៅដល់បរិមាណមូលបត្រដែលអាចផ្គូផ្គងបានដោយឈរលើមូលដ្ឋាននៃថ្លៃរំពឹងទុក។

- **ប្រតិបត្តិការគណនីអតិថិជន** សំដៅដល់ប្រតិបត្តិការទិញ ឬលក់មូលបត្របន្ទាប់ពីបានទទួលការបញ្ជាពីអតិថិជន។

- **ប្រតិបត្តិការគណនីសមាជិក** សំដៅដល់ប្រតិបត្តិការទិញ ឬលក់មូលបត្រសម្រាប់គណនីផ្ទាល់របស់សមាជិក។

- **ប្រព័ន្ធកុំព្យូទ័ររបស់ ផ.ម.ក.** សំដៅដល់ប្រព័ន្ធកុំព្យូទ័រ ដែលប្រតិបត្តិដោយប្រតិបត្តិករទីផ្សារមូលបត្រនៃ **ផ.ម.ក.** ក្នុងគោលបំណងធ្វើជាអន្តរការីនៃការជួញដូរមូលបត្រ។

- **ប្រព័ន្ធកុំព្យូទ័រសមាជិក** សំដៅដល់ប្រព័ន្ធកុំព្យូទ័ររបស់សមាជិក ដែលត្រូវបានអនុញ្ញាតឱ្យបញ្ជូនបញ្ជាទៅកាន់ប្រព័ន្ធកុំព្យូទ័ររបស់ **ផ.ម.ក.**។

- **ការជួញដូរមិនប្រក្រតី** សំដៅដល់ការជួញដូរទាំងឡាយដែលក្នុងនោះថ្លៃ ឬបរិមាណនៃការជួញដូរមូលបត្រមានការប្រែប្រួលខុសប្រក្រតីនៅក្នុងទីផ្សារ។

- **ការជួញដូរមិនស្មោះត្រង់** សំដៅដល់ការជួញដូរដែលធ្វើឱ្យថ្លៃទីផ្សារមានការប្រែប្រួលដោយមធ្យោបាយមិនស្មោះត្រង់ដូចជា÷ ការប្រើប្រាស់ព័ត៌មានផ្ទៃក្នុង ការប្រើឧបាយកលក្នុងទីផ្សារ ឬការប្រើប្រាស់ព័ត៌មានដែលមានលក្ខណៈក្លែងបន្លំ ឬដែលនាំអោយយល់ខុស។

- **ការឃ្លាំមើលទីផ្សារ** (Market Watch) សំដៅដល់ការតាមដានសភាពការណ៍ទីផ្សារ តាមរយៈការវិភាគអំពីប្រតិបត្តិការជួញដូរមូលបត្រនៅលើទីផ្សារ ស្ថានភាពនៃបញ្ជា និងព័ត៌មាននានាដែលពាក់ព័ន្ធនឹងឯកសារផ្តល់ព័ត៌មាន ពាក្យចចាមអារ៉ាម និងព័ត៌មានដែលទទួលបានពីប្រភពផ្សេងទៀត ជាដើម។

- **វិធីសាស្ត្រដេញថ្លៃដោយយកថ្លៃតែមួយ** សំដៅដល់វិធីសាស្ត្រដេញថ្លៃដែលរាល់បញ្ជាទិញនិងបញ្ជាលក់ទាំងអស់ ត្រូវផ្គូផ្គងព្រមគ្នានិងជួញដូរនៅថ្លៃតែមួយ។

- **វិធីសាស្ត្រដេញថ្លៃដោយយកថ្លៃច្រើន** សំដៅដល់វិធីសាស្ត្រដេញថ្លៃដែលបញ្ជាទិញ ឬលក់មួយត្រូវបានផ្គូផ្គង និងអាចជួញដូរនៅថ្លៃច្រើនផ្សេងៗគ្នា។

**ប្រការ ៣.- មូលបត្រដែលអាចជួញដូរបាន**

មូលបត្រដែលចុះបញ្ជីលក់នៅ**ផ.ម.ក.** ត្រូវជួញដូរនៅប្រតិបត្តិករទីផ្សារមូលបត្រនៃ **ផ.ម.ក.** ដោយគោរពតាមវិធាននេះ។

ការជួញដូរមូលបត្រក្នុងចំណោមសមាជិក ត្រូវបានធ្វើអន្តរការីកម្មដោយប្រតិបត្តិករទីផ្សារមូលបត្រនៃ **ផ.ម.ក.**។

**ប្រការ ៤.- ប្រភេទនៃបញ្ជា**

**ផ.ម.ក.** អនុញ្ញាតឱ្យមានប្រភេទបញ្ជាដូចខាងក្រោម÷

១-បញ្ជាដែនកំណត់ (Limit Order)÷ ជាបញ្ជាដែលមានថ្លៃជាក់លាក់មួយ ដើម្បីទិញឬលក់មូលបត្រនៅថ្លៃជាក់លាក់នោះ ឬនៅថ្លៃប្រសើរជាងថ្លៃជាក់លាក់នោះ។ ថ្លៃប្រសើរជាងថ្លៃជាក់លាក់ គឺជាថ្លៃទាបជាងថ្លៃជាក់លាក់នោះក្នុងករណីទិញ ឬជាថ្លៃខ្ពស់ជាងថ្លៃជាក់លាក់នោះក្នុងករណីលក់។

២-បញ្ជាទីផ្សារ (Market Order)÷ ជាបញ្ជាដើម្បីទិញឬលក់មូលបត្រកម្មសិទ្ធិ នៅថ្លៃល្អបំផុតដែលមានក្នុងទីផ្សារ ដោយគោរពតាមប្រការ ១០, ១១ និង១២។ បញ្ជាទីផ្សារមិនត្រូវបានអនុញ្ញាតសម្រាប់ប្រតិបត្តិការផ្តល់សន្ទនីយភាពមូលបត្រ និងការជួញដូរលើកដំបូងនៃមូលបត្រចុះបញ្ជីលក់លើកដំបូង។ នៅក្នុងវគ្គនិរន្តរ៍ បញ្ជាទីផ្សារអាចភ្ជាប់លក្ខខណ្ឌណាមួយ ដូចខាងក្រោម÷

ក-លក្ខខណ្ឌជួញដូរទាំងស្រុង ឬលុបចោល (Fill or Kill)÷ ជាលក្ខខណ្ឌដែលកំណត់ថាបញ្ជានឹងត្រូវលុបចោលភ្លាម ប្រសិនបើបរិមាណនៃបញ្ជានោះមិនត្រូវបានផ្គូផ្គងទាំងស្រុងភ្លាមៗ បន្ទាប់ពីត្រូវបានដាក់បញ្ចូលក្នុងប្រព័ន្ធជួញដូរ។

ខ-លក្ខខណ្ឌជួញដូរ ហើយលុបចោល (Fill and Kill)÷ ជាលក្ខខណ្ឌដែលកំណត់ថាបញ្ជានឹងត្រូវលុបចោលភ្លាមប្រសិនបើបរិមាណនៃបញ្ជានោះមិនត្រូវបានផ្គូផ្គងទាំងស្រុងឬមួយផ្នែកភ្លាមៗ បន្ទាប់ពីត្រូវបានដាក់បញ្ចូលក្នុងប្រព័ន្ធជួញដូរ។ ក្នុងករណីដែលបរិមាណនៃបញ្ជានោះត្រូវបានផ្គូផ្គងមួយផ្នែក បញ្ជាដែលមានបរិមាណនៅសល់នោះ នឹងត្រូវលុបចោលភ្លាម។

៣-បញ្ជាតាមការចរចា (Negotiated Order)÷ ជាបញ្ជាដើម្បីទិញឬលក់មូលបត្រ តាមវិធីសាស្ត្រជួញដូរតាមការចរចា (Negotiated Trading Method)។

**ប្រការ ៥.- សុពលភាពនៃបញ្ជា**

រាល់បញ្ជានីមួយៗ ត្រូវមានសុពលភាពចាប់ពីពេលដែលទទួលបាននៅក្នុងប្រព័ន្ធជួញដូររបស់ប្រតិបត្តិករទីផ្សារមូលបត្រនៃ **ផ.ម.ក.** រហូតដល់ពេលដែលបញ្ជានោះត្រូវបានអនុវត្តការជួញដូរនៅអំឡុងវគ្គជួញដូរនៃថ្ងៃតែមួយ។

ទោះបីមានចែងក្នុងកថាខណ្ឌទី ១ ខាងលើ សុពលភាពនៃបញ្ជានៃមូលបត្រណាមួយត្រូវបានព្យួរក្នុងករណីដែលការជួញដូរមូលបត្រនោះត្រូវបានព្យួរក្នុងអំឡុងម៉ោងជួញដូរ។

## ប្រការ ៦.- ការកែប្រែ ឬលុបបញ្ជាដែលបានបញ្ជូន

ប្រសិនបើបញ្ជាមិនទាន់ត្រូវបានអនុវត្តការជួញដូរ សមាជិកអាច÷

១-កែប្រែឬលុប ថ្លៃឬបរិមាណនៃបញ្ជាដែនកំណត់។

២-លុបបញ្ជាទីផ្សារ និងបញ្ជាតាមការចរចា។

## ប្រការ ៧.- នីតិវិធីនៃការដាក់បញ្ជា

ក្នុងករណីដែលសមាជិកមួយដាក់បញ្ជាទៅប្រតិបត្តិករទីផ្សារមូលបត្រនៃ **ផ.ម.ក.** សមាជិកនោះត្រូវអនុវត្តនីតិវិធីដូចខាងក្រោម÷

១-ពិនិត្យមើលសាច់ប្រាក់ ឬមូលបត្រដែលអតិថិជនមាន ដើម្បីធានាការទូទាត់ ឬការជួញដូរដែលពាក់ព័ន្ធនឹងបញ្ជានោះ។

២-ពិនិត្យព័ត៌មានលម្អិតនៃបញ្ជាដូចមានចែងក្នុងប្រការ ៨ ។

៣-ដាក់បញ្ជាចូលទៅក្នុងប្រព័ន្ធជួញដូររបស់ប្រតិបត្តិករទីផ្សារមូលបត្រនៃ **ផ.ម.ក.**។

## ប្រការ ៨.- ព័ត៌មានលម្អិតនៃបញ្ជា

បញ្ជាដែលដាក់ចូលទៅក្នុងប្រព័ន្ធជួញដូររបស់ប្រតិបត្តិករទីផ្សារមូលបត្រនៃ **ផ.ម.ក.** ត្រូវមានព័ត៌មានលម្អិត ដូចខាងក្រោម÷

១-ឈ្មោះមូលបត្រ។

២-បរិមាណ។

៣-ថ្លៃ ករណីក្រៅពីបញ្ជាទីផ្សារ។

៤-លេខកូដជួញដូរតាមការចរចា ចំពោះបញ្ជាតាមការចរចា។

៥-ការបញ្ជាក់ពីបញ្ជា÷ បញ្ជាទិញ ឬបញ្ជាលក់។

៦-ប្រភេទនៃប្រតិបត្តិការ÷ ប្រតិបត្តិការគណនីអតិថិជន ឬប្រតិបត្តិការគណនីសមាជិក។

៧-លេខអត្តសញ្ញាណសមាជិក។

៨- លេខអត្តសញ្ញាណវិនិយោគិន។

៩- លេខបញ្ជា។

១០- លេខគណនីជួញដូរ។

១១- ក្នុងករណីលុបឬកែប្រែបញ្ជាត្រូវបញ្ជាក់ថាជាការលុបឬជាការកែប្រែ ហើយត្រូវបញ្ជាក់លេខបញ្ជាដើមផងដែរ។

១២- លេខកូដវិនិយោគិន÷ ជារូបវន្តបុគ្គល ឬនីតិបុគ្គល។

១៣- លេខកូដប្រទេសរបស់វិនិយោគិន។

## ប្រការ ៩.- វិធីសាស្ត្រជួញដូរ

រាល់ការជួញដូរត្រូវធ្វើឡើងតាមវិធីសាស្ត្រ ដូចខាងក្រោម÷

១- វិធីសាស្ត្រដេញថ្លៃ (Auction Trading Method)។

២- វិធីសាស្ត្រជួញដូរតាមការចរចា (Negotiated Trading Method)។

## ប្រការ ១០.- វិធីសាស្ត្រដេញថ្លៃ

វិធីសាស្ត្រដេញថ្លៃ (Auction Trading Method) គឺជាវិធីសាស្ត្រផ្គូផ្គងបញ្ជាទិញនិងបញ្ជាលក់ដោយស្វ័យប្រវត្តិ តាមវិធីសាស្ត្រដេញថ្លៃដោយយកថ្លៃតែមួយ (Single Price Auction) ឬវិធីសាស្ត្រដេញថ្លៃដោយយកថ្លៃច្រើន (Multiple Price Auction) ។

អាទិភាពនៃបញ្ជាតាមវិធីសាស្ត្រដេញថ្លៃដោយយកថ្លៃតែមួយ និងវិធីសាស្ត្រដេញថ្លៃដោយយកថ្លៃច្រើន ត្រូវកំណត់ទៅតាមគោលការណ៍ដូចខាងក្រោម÷

១- បញ្ជាលក់ដែលមានថ្លៃទាបជាងមានអាទិភាពលើបញ្ជាលក់ដែលមានថ្លៃខ្ពស់ជាង ហើយបញ្ជាទិញដែលមានថ្លៃខ្ពស់ជាង មានអាទិភាពលើបញ្ជាទិញដែលមានថ្លៃទាបជាង។

២- ក្នុងករណីបញ្ជាមានថ្លៃដូចគ្នា បញ្ជាដែលទទួលបានមុនមានអាទិភាពលើបញ្ជា ដែលទទួលបានក្រោយ។

ទោះបីជាមានចែងក្នុងកថាខណ្ឌទី២នៃប្រការនេះក៏ដោយ អាទិភាពនៃបញ្ជាទិញនិងបញ្ជាលក់តាមរយៈវិធីសាស្ត្រដេញថ្លៃដោយយកថ្លៃតែមួយ ត្រូវបានកំណត់ដោយឡែក ក្នុងករណីនៃបញ្ជាព្រមពេលគ្នា÷

១- ត្រូវបានចាត់ទុកថាជាបញ្ជាព្រមពេលគ្នា ចំពោះករណីដូចខាងក្រោម÷

ក- រាល់បញ្ជាទិញ ដែលមានថ្លៃដែលត្រូវផ្គូផ្គងស្មើនឹងដែនកំណត់ថ្លៃខាងលើ (ថ្លៃមូលដ្ឋាន+១០%)។

ខ-រាល់បញ្ជាលក់ ដែលមានថ្លៃដែលត្រូវផ្គូផ្គងស្មើនឹងដែនកំណត់ថ្លៃខាងក្រោម (ថ្លៃមូលដ្ឋាន -១០%)។

២-ចំពោះបញ្ជាព្រមពេលគ្នា ដូចមានចែងនៅក្នុងចំណុចទី១ នៃកថាខណ្ឌនេះ បញ្ជាសម្រាប់គណនីអតិថិជនមានអាទិភាពលើបញ្ជាសម្រាប់គណនីសមាជិក។ ក្នុងករណីនេះ បញ្ជាដែលមានបរិមាណច្រើនជាងមានអាទិភាពលើបញ្ជាដែលមានបរិមាណតិចជាង។ ក្នុងករណីបញ្ជាមានបរិមាណស្មើគ្នា បញ្ជាដែល **ផ.ម.ក.** ទទួលបានមុនតាមរយៈប្រព័ន្ធជួញដូរត្រូវមានអាទិភាព។

៣-ការបែងចែកបរិមាណមូលបត្រសម្រាប់បញ្ជាព្រមពេលគ្នា ដូចមានចែងនៅក្នុងចំណុចទី២ នៃកថាខណ្ឌនេះ ត្រូវអនុវត្តតាមលំដាប់លំដោយអាទិភាព ដូចខាងក្រោម÷

ក-១០០ (មួយរយ) ដង នៃឯកតាជួញដូរ។

ខ-៥០០ (ប្រាំរយ) ដង នៃឯកតាជួញដូរ។

គ-១០០០ (មួយពាន់) ដង នៃឯកតាជួញដូរ។

ឃ-៥០ (ហាសិប) ភាគរយ នៃបរិមាណដែលនៅសល់។ ក្នុងករណីនេះ ប្រសិនបរិមាណនោះទាបជាងឯកតាជួញដូរ ត្រូវកំណត់យកត្រឹមឯកតាជួញដូរ។

ង-បរិមាណដែលនៅសល់ទាំងអស់ត្រូវផ្តល់ឱ្យតាមអាទិភាព។

## ប្រការ១១.- វិធីសាស្ត្រដេញថ្លៃដោយយកថ្លៃតែមួយ

ថ្លៃដូចខាងក្រោមនេះ ត្រូវកំណត់យកដោយប្រើប្រាស់វិធីសាស្ត្រដេញថ្លៃដោយយកថ្លៃតែមួយ (Single Price Auction)÷

១-ថ្លៃបើក។

២-ថ្លៃជួញដូរលើកដំបូងនៃមូលបត្រចុះបញ្ជីលក់លើកដំបូង។

៣-ថ្លៃបើកក្រោយពេលបើកទីផ្សារឡើងវិញ បន្ទាប់ពីបិទទីផ្សារបណ្តោះអាសន្ន ឬព្យួរការជួញដូររយៈពេលយូរ។

៤-ថ្លៃក្រោយពេលចាប់ផ្តើមការជួញដូរឡើងវិញ បន្ទាប់ពីផ្អាកការជួញដូរ។

៥-ថ្លៃនៅពេលបិទទីផ្សារ។

ករណីប្រើប្រាស់វិធីសាស្ត្រដេញថ្លៃដោយយកថ្លៃតែមួយ បញ្ជាទីផ្សារដែលបានដាក់ត្រូវចាត់ទុកថាមានថ្លៃណាមួយ ដូចខាងក្រោម÷

១-ក្នុងករណីមានតែបញ្ជាទីផ្សារទិញ និងបញ្ជាទីផ្សារលក់ ថ្លៃត្រូវបានកំណត់ដូចខាងក្រោម÷

ក-ថ្លៃចុងក្រោយ ប្រសិនបើបរិមាណខាងទិញស្មើបរិមាណខាងលក់។

ខ-ថ្លៃចុងក្រោយបូកមួយឯកតាគម្លាតថ្លៃ ដែលត្រូវស្ថិតក្នុងដែនកំណត់ថ្លៃខាងលើ ប្រសិនបើបរិមាណខាងទិញច្រើនជាងបរិមាណខាងលក់។

គ-ថ្លៃចុងក្រោយដកមួយឯកតាគម្លាតថ្លៃដែលត្រូវស្ថិតក្នុងដែនកំណត់ថ្លៃខាងក្រោមប្រសិនបើបរិមាណខាងទិញតិចជាងបរិមាណខាងលក់។

២-ចំពោះករណីផ្សេងទៀត ក្រៅពីចំណុចទី១នៃកថាខណ្ឌនេះ ថ្លៃនៃបញ្ជាទិញគឺជាថ្លៃដែលខ្ពស់ជាងគេក្នុងចំណោមថ្លៃខាងក្រោម÷

ក-ថ្លៃចុងក្រោយ។

ខ-ថ្លៃដែលស្ថិតនៅមួយឯកតាគម្លាតថ្លៃខ្ពស់ជាងថ្លៃនៃបញ្ជាដែនកំណត់ទិញដែលខ្ពស់បំផុត ដែលត្រូវស្ថិតក្នុងដែនកំណត់ថ្លៃខាងលើ។

គ-ថ្លៃនៃបញ្ជាដែនកំណត់លក់ដែលខ្ពស់បំផុត។

៣-ចំពោះករណីផ្សេងទៀត ក្រៅពីចំណុចទី១នៃកថាខណ្ឌនេះ ថ្លៃនៃបញ្ជាទីផ្សារលក់គឺជាថ្លៃដែលទាបជាងគេក្នុងចំណោមថ្លៃខាងក្រោម÷

ក-ថ្លៃចុងក្រោយ។

ខ-ថ្លៃដែលស្ថិតនៅមួយឯកតាគម្លាតថ្លៃទាបជាងថ្លៃនៃបញ្ជាដែនកំណត់លក់ដែលទាបបំផុតដែលត្រូវ ស្ថិតក្នុងដែនកំណត់ថ្លៃខាងក្រោម។

គ-ថ្លៃនៃបញ្ជា ដែនកំណត់ទិញដែលទាបបំផុត។

ការជួញដូរតាមវិធីសាស្ត្រដេញថ្លៃដោយយកថ្លៃតែមួយ ត្រូវអនុវត្តតាមថ្លៃកំណត់មួយ ដែលហៅថាថ្លៃជួញដូរ (Trading Price) ដែលត្រូវកំណត់ដូចខាងក្រោម÷

១-ក្នុងករណី "ថ្លៃផ្គូផ្គង" (Matching Price) មានតែមួយ ថ្លៃជួញដូរគឺជាថ្លៃផ្គូផ្គង ដែលនៅថ្លៃនោះបរិមាណសរុបនៃបញ្ជាលក់ត្រូវបានផ្គូផ្គងនឹងបរិមាណសរុបនៃបញ្ជាទិញ ដោយអនុវត្តទៅតាមលំដាប់នៃអាទិភាពដូចខាងក្រោម÷

ក-អាទិភាពទី ១÷ បរិមាណសរុបនៃបញ្ជាលក់ដែលមានថ្លៃទាបជាងថ្លៃផ្គូផ្គង និងបរិមាណសរុបនៃបញ្ជាទិញដែលមានថ្លៃខ្ពស់ជាងថ្លៃផ្គូផ្គង។

ខ-អាទិភាពទី ២÷ ក្នុងករណីដែលបញ្ជាលក់ និងបញ្ជាទិញត្រូវបានដាក់នៅចំថ្លៃផ្គូផ្គង បរិមាណមូលបត្រត្រូវបានផ្គូផ្គងដូចខាងក្រោម÷

-បរិមាណសរុបនៃបញ្ជាលក់ ឬបរិមាណសរុបនៃបញ្ជាទិញនោះ និង

-ចាប់ពី ១ (មួយ)ឯកតាមូលបត្រនៃបញ្ជាម្ខាងទៀត។

២-ក្នុងករណីដែលមានចំនួនថ្លៃផ្គូផ្គងលើសពី ១ (មួយ) ថ្លៃជួញដូរត្រូវបានជ្រើសរើសក្នុងចំណោមថ្លៃដូចខាងក្រោម÷

ក-ថ្លៃចុងក្រោយ ឬថ្លៃបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូងនៅថ្ងៃជួញដូរដំបូង ប្រសិនបើ មានថ្លៃផ្គូផ្គងណាមួយស្មើនឹងថ្លៃចុងក្រោយ ឬថ្លៃបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូងនេះ។

ខ-ថ្លៃដែលនៅកៀកជាងគេធៀបនឹងថ្លៃចុងក្រោយ ឬថ្លៃបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូងនៅថ្ងៃជួញដូរដំបូង ប្រសិនបើគ្មានថ្លៃផ្គូផ្គងណាដែលស្មើនឹងថ្លៃចុងក្រោយ ឬថ្លៃបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូងនេះ។

## ប្រការ ១២.- វិធីសាស្ត្រដេញថ្លៃដោយយកថ្លៃច្រើន

ថ្លៃផ្សេងទៀតក្រៅពីថ្លៃដែលចែងនៅក្នុងកថាខណ្ឌទី១ នៃប្រការ១១ ត្រូវកំណត់តាមវិធីសាស្ត្រដេញថ្លៃដោយយកថ្លៃច្រើន (Multiple Price Auction)។

ក្នុងករណីដែលថ្លៃត្រូវបានកំណត់ស្របតាមកថាខណ្ឌទី១ បញ្ជាទីផ្សារដែលបានដាក់ត្រូវចាត់ទុកថាមានថ្លៃណាមួយដូចខាងក្រោម រហូតដល់បរិមាណបញ្ជាសរុបត្រូវបានផ្គូផ្គងអស់÷

១-ថ្លៃខ្ពស់ជាងគេក្នុងចំណោមថ្លៃខាងក្រោម ករណីបញ្ជាទីផ្សារទិញ÷

ក-ថ្លៃចុងក្រោយ នៅពេលគ្មានបញ្ជាដែនកំណត់ទិញ ឬថ្លៃបញ្ជាដែនកំណត់ទិញដែលខ្ពស់បំផុតបូក ១ (មួយ)ឯកតាគម្លាតថ្លៃ ដែលត្រូវស្ថិតក្នុងដែនកំណត់ថ្លៃខាងលើ នៅពេលមានបញ្ជាដែនកំណត់ទិញ។

ខ-ថ្លៃនៃបញ្ជាដែនកំណត់លក់ដែលខ្ពស់បំផុត។

២-ថ្លៃទាបជាងគេក្នុងចំណោមថ្លៃខាងក្រោម ចំពោះករណីបញ្ជាទីផ្សារលក់÷

ក-ថ្លៃចុងក្រោយ នៅពេលគ្មានបញ្ជាដែនកំណត់លក់ ឬថ្លៃនៃបញ្ជាដែនកំណត់លក់ដែលទាបបំផុតដក ១ (មួយ)ឯកតាគម្លាតថ្លៃ ដែលត្រូវស្ថិតក្នុងដែនកំណត់ថ្លៃខាងក្រោម នៅពេលមានបញ្ជាដែនកំណត់លក់។

ខ-ថ្លៃនៃបញ្ជាដែនកំណត់ទិញដែលទាបបំផុត។

ការជួញដូរតាមវិធីសាស្ត្រដេញថ្លៃដោយយកថ្លៃច្រើន ត្រូវគោរពតាមអាទិភាពនៃបញ្ជាដូចដែលបានចែងនៅ កថាខណ្ឌទី២ នៃប្រការ១០ ហើយការជួញដូរត្រូវអនុវត្តនៅថ្លៃនៃបញ្ជាដែលទទួលបានមុន នៅពេលដែលថ្លៃទិញខ្ពស់បំផុតផ្គូផ្គងជាមួយថ្លៃលក់ទាបបំផុត។

### ប្រការ ១៣.- វិធីសាស្ត្រជួញដូរតាមការចរចា

វិធីសាស្ត្រជួញដូរតាមការចរចា (Negotiated Trading Method) គឺជាវិធីសាស្ត្រផ្គូផ្គងបញ្ជាតាមការចរចាទិញនិងលក់មួយគូ បន្ទាប់ពីភាគីទាំងពីរបានចរចា និងព្រមព្រៀងលើលក្ខខណ្ឌទាំងឡាយនៃការជួញដូរ។

ការជួញដូរដែលបានព្រមព្រៀងដូចបានចែងក្នុងកថាខណ្ឌទី១ខាងលើនេះ មានអានុភាពលុះត្រាតែ បញ្ជាជួញដូរតាមការចរចាត្រូវបានដាក់មកប្រតិបត្តិករទីផ្សារមូលបត្រនៃ **ផ.ម.ក.** និងផ្គូផ្គងដោយជោគជ័យ។

បញ្ជាជួញដូរតាមការចរចាទាំងសងខាង ត្រូវមានព័ត៌មានលម្អិតដូចគ្នាទាំងស្រុងគឺ ឈ្មោះមូលបត្រ បរិមាណ ថ្លៃ និងលេខកូដជួញដូរតាមការចរចា។

### ប្រការ ១៤ .- ថ្ងៃ និងម៉ោងជួញដូរ

ថ្ងៃជួញដូរចាប់ផ្តើមពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ លើកលែងថ្ងៃឈប់សម្រាកជាសាធារណៈ ដោយអនុលោមតាមច្បាប់ស្តីពីការងារ។

ម៉ោងជួញដូរចាប់ផ្តើមពីម៉ោង ៨:០០នាទី ព្រឹក រហូតដល់ម៉ោង ៣:០០នាទី រសៀល ដែលបែងចែកជាបីវគ្គដោយឈរលើមូលដ្ឋាននៃវិធីសាស្ត្រនៃការដេញថ្លៃ ដូចខាងក្រោម÷

| **វគ្គ** | **ម៉ោងទទួលបញ្ជា** | **ម៉ោងអនុវត្តការជួញដូរ** | **វិធីសាស្ត្រ** |
|---|---|---|---|
| វគ្គបើក | ៨:០០ ព្រឹក - ៩:០០ ព្រឹក | ៩:០០ ព្រឹក | ដេញថ្លៃដោយយកថ្លៃតែមួយ |
| វគ្គនិរន្តរ៍ | ៩:០០ ព្រឹក- ២:៥០ រសៀល | | ដេញថ្លៃដោយយកថ្លៃច្រើន |
| វគ្គបិទ | ២:៥០ រសៀល - ៣:០០ រសៀល | ៣:០០ រសៀល | ដេញថ្លៃដោយយកថ្លៃតែមួយ |

ប្រសិនមិនមានការផ្គូផ្គងបញ្ជានៅម៉ោង ៩:០០នាទី ព្រឹក វគ្គបើកនឹងត្រូវពន្យាររហូតដល់មានការផ្គូផ្គងនៅក្នុងថ្ងៃដដែល។

ចំពោះវិធីសាស្ត្រជួញដូរតាមការចរចា÷ ម៉ោងជួញដូរចាប់ផ្តើមពីម៉ោង ៩:០០នាទី ព្រឹកដល់ម៉ោង ៣:០០នាទី រសៀល។

# ជំពូកទី ២
# លក្ខខណ្ឌនៃការជួញដូរមូលបត្រកម្មសិទ្ធិ

## ប្រការ ១៥.- ឯកតាបញ្ជា បញ្ជាអប្បបរមា និងឯកតាគម្លាតថ្លៃ

ឯកតាបញ្ជាគឺ ១ (មួយ) ឯកតាមូលបត្រកម្មសិទ្ធិ។

សម្រាប់ការជួញដូរមូលបត្រកម្មសិទ្ធិតាមវិធីសាស្ត្រដេញថ្លៃ ឯកតាគម្លាតថ្លៃត្រូវកំណត់ដូចខាងក្រោម÷

១- ១០ (ដប់)រៀល ចំពោះមូលបត្រកម្មសិទ្ធិដែលមានថ្លៃទាបជាង ៤.០០០ (បួនពាន់)រៀល ក្នុង ១ (មួយ) ឯកតាមូលបត្រកម្មសិទ្ធិ។

២- ២០ (ម្ភៃ) រៀល ចំពោះមូលបត្រកម្មសិទ្ធិដែលមានថ្លៃស្មើ ឬខ្ពស់ជាង៤.០០០ (បួនពាន់) រៀល ប៉ុន្តែទាបជាង ២០.០០០ (ពីរម៉ឺន) រៀល ក្នុង ១ (មួយ) ឯកតាមូលបត្រកម្មសិទ្ធិ។

៣- ៥០ (ហាសិប) រៀល ចំពោះមូលបត្រកម្មសិទ្ធិដែលមានថ្លៃស្មើ ឬខ្ពស់ជាង ២០.០០០ (ពីរម៉ឺន) រៀល ប៉ុន្តែទាបជាង ៤០.០០០ (បួនម៉ឺន) រៀល ក្នុង ១ (មួយ) ឯកតាមូលបត្រកម្មសិទ្ធិ។

៤- ១០០ (មួយរយ) រៀល ចំពោះមូលបត្រកម្មសិទ្ធិដែលមានថ្លៃស្មើឬខ្ពស់ជាង ៤០.០០០ (បួនម៉ឺន) រៀល ប៉ុន្តែទាបជាង ១០០.០០០ (មួយសែន) រៀល ក្នុង ១ (មួយ) ឯកតាមូលបត្រកម្មសិទ្ធិ។

៥- ២០០ (ពីររយ) រៀល ចំពោះមូលបត្រកម្មសិទ្ធិដែលមានថ្លៃស្មើឬខ្ពស់ជាង ១០០.០០០ (មួយសែន) រៀល ប៉ុន្តែទាបជាង ២០០.០០០ (ពីរសែន) រៀល ក្នុង ១ (មួយ) ឯកតាមូលបត្រកម្មសិទ្ធិ។

៦- ៥០០ (ប្រាំរយ) រៀល ចំពោះមូលបត្រកម្មសិទ្ធិដែលមានថ្លៃស្មើឬខ្ពស់ជាង ២០០.០០០ (ពីរសែន) រៀល ប៉ុន្តែទាបជាង ៤០០.០០០ (បួនសែន) រៀល ក្នុង ១ (មួយ) ឯកតាមូលបត្រកម្មសិទ្ធិ។

៧- ១.០០០ (មួយពាន់) រៀល ចំពោះមូលបត្រកម្មសិទ្ធិដែលមានថ្លៃស្មើ ឬខ្ពស់ជាង ៤០០.០០០ (បួនសែន) រៀល ក្នុង ១ (មួយ) ឯកតាមូលបត្រកម្មសិទ្ធិ។

សម្រាប់ការជួញដូរមូលបត្រកម្មសិទ្ធិតាមវិធីសាស្ត្រជួញដូរតាមការចរចាបញ្ជាអប្បបរមាគឺ៥០.០០០ (ប្រាំម៉ឺន) ឯកតាមូលបត្រកម្មសិទ្ធិ ឬ២០០.០០០.០០០ (ពីររយលាន) រៀល យកមួយណាដែលតូចជាង ហើយឯកតាគម្លាតថ្លៃ គឺ ១ (មួយ)រៀល។

**ប្រការ ១៦.- ថ្លៃមូលដ្ឋាន**

ថ្លៃមូលដ្ឋានសម្រាប់ការជួញដូរមូលបត្រចុះបញ្ជីលក់លើកដំបូង សំដៅដល់ថ្លៃជួញដូរដំបូងដែលត្រូវបានកំណត់នៅចន្លោះពី ៩០% (កៅសិបភាគរយ) និង ១៥០% (មួយរយហាសិបភាគរយ) នៃថ្លៃ បោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង។

ថ្លៃមូលដ្ឋានរបស់មូលបត្រកម្មសិទ្ធិសម្រាប់ថ្ងៃជួញដូរនីមួយៗ ត្រូវកំណត់ដូចខាងក្រោមលើកលែងតែមានការកំណត់ផ្សេងពីនេះ ដោយ **គ.ម.ក.**÷

១-ក្រៅពីថ្លៃមូលដ្ឋានរបស់មូលបត្រកម្មសិទ្ធិដូចមានក្នុងចំនុច ២ ដល់ ៤ ខាងក្រោម ថ្លៃមូលដ្ឋាននៃមូលបត្រកម្មសិទ្ធិសម្រាប់ថ្ងៃជួញដូរនីមួយៗ គឺជាថ្លៃបិទនៃថ្ងៃជួញដូរចុងក្រោយ។

២-ក្នុងករណីមូលបត្រកម្មសិទ្ធិដែលបានចែកភាគលាភជាមូលបត្រកម្មសិទ្ធិ ថ្លៃមូលដ្ឋានគឺជាថ្លៃដែលទទួលបានតាមរូបមន្តដូចខាងក្រោម÷

| |
|---|
| មូលធនូបនីយកម្មទីផ្សារមុនបែងចែកភាគលាភជាមូលបត្រកម្មសិទ្ធិ / ចំនួនមូលបត្រកម្មសិទ្ធិបន្ទាប់ពីបែងចែកភាគលាភជាមូលបត្រកម្មសិទ្ធិ |

| |
|---|
| **ចំណាំ÷**មូលធនូបនីយកម្មទីផ្សារមុនបែងចែកភាគលាភជាមូលបត្រកម្មសិទ្ធិ =ថ្លៃបិទ x ចំនួនមូលបត្រកម្មសិទ្ធិមុនបែងចែកភាគលាភជាមូលបត្រកម្មសិទ្ធិ |

៣- ក្នុងករណីមានការបង្កើនដើមទុនតាមរយៈការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិបន្ថែម ថ្លៃមូលដ្ឋានគឺជាថ្លៃទទួលបានតាមរូបមន្តដូចខាងក្រោម÷

| |
|---|
| [មូលធនូបនីយកម្មទីផ្សារមុនបង្កើនដើមទុន + (ថ្លៃមូលបត្រកម្មសិទ្ធិបោះផ្សាយលក់ x ចំនួនមូលបត្រកម្មសិទ្ធិដែលបានបោះផ្សាយលក់បន្ថែម)] / ចំនួនមូលបត្រកម្មសិទ្ធិបន្ទាប់ពីបង្កើនដើមទុន |

៤- ក្នុងករណីមូលបត្រកម្មសិទ្ធិដែលមានការបម្លែង (ការបំបែក ការបង្រួម ឬកាត់បន្ថយដើមទុនមូលបត្រកម្មសិទ្ធិ)ថ្លៃមូលដ្ឋានគឺជាថ្លៃដែលទទួលបានតាមរូបមន្តដូចខាងក្រោម÷

| |
|---|
| ថ្លៃបិទនៃថ្ងៃជួញដូរចុងក្រោយ x អនុបាតបម្លែង (Split Ratio)<br>(អនុបាតបម្លែង = ចំនួនមូលបត្រកម្មសិទ្ធិមុនបម្លែង / ចំនួនមូលបត្រកម្មសិទ្ធិក្រោយបម្លែង) |

ក្នុងករណីថ្លៃមូលបត្រដូចមានចែងក្នុងកថាខណ្ឌទី ១ ខាងលើ ទាបជាងឯកតាគម្លាតថ្លៃ នោះថ្លៃមូលដ្ឋានត្រូវកំណត់ស្មើនឹងឯកតាគម្លាតថ្លៃ។

## ប្រការ ១៧.- ដែនកំណត់ថ្លៃប្រចាំថ្ងៃ

ដែនកំណត់ថ្លៃប្រចាំថ្ងៃ សម្រាប់មូលបត្រកម្មសិទ្ធិ ត្រូវស្មើនឹងថ្លៃមូលដ្ឋាន ±១០% (បូកឬដកដប់ភាគរយ) ដោយតម្លៃ១០% នៃថ្លៃមូលដ្ឋានត្រូវបង្គត់ចុះតាមឯកតាគម្លាតថ្លៃ មុននឹងយកទៅបូកឬដកនឹងថ្លៃមូលដ្ឋាន។ ក្នុងករណីថ្លៃមូលដ្ឋានទាបជាង ១០០ (មួយរយ) រៀល ដែនកំណត់ថ្លៃប្រចាំថ្ងៃគឺស្មើនឹង ១០ (ដប់) រៀល។

ទោះបីមានចែងក្នុងកថាខណ្ឌទី១ ខាងលើ ដែនកំណត់ថ្លៃប្រចាំថ្ងៃមិនត្រូវបានកំណត់ទេចំពោះមូលបត្រកម្មសិទ្ធិដែលត្រូវដកចេញពីការចុះបញ្ជីលក់មូលបត្រ (Delisting) ហើយត្រូវបានអនុញ្ញាតឱ្យជួញដូរក្នុងអំឡុងពេលមួយកំណត់ នៅមុនពេលដកចេញពីការចុះបញ្ជីលក់មូលបត្រ។

ទោះបីមានចែងក្នុងកថាខណ្ឌទី១ និងទី២ខាងលើ បន្ទាប់ពីមានការឯកភាពពីអគ្គនាយកនៃ**គ.ម.ក.** **ផ.ម.ក.**អាចកំណត់យកដែនកំណត់ថ្លៃប្រចាំថ្ងៃផ្សេងពីនេះក្នុងករណីដូចខាងក្រោម÷

១-ករណីមូលបត្រកម្មសិទ្ធិត្រូវបានអនុញ្ញាតឱ្យចុះបញ្ជីឡើងវិញ។

២-ករណីមូលបត្រកម្មសិទ្ធិត្រូវបានអនុញ្ញាតឱ្យចាប់ផ្តើមជួញដូរឡើងវិញ បន្ទាប់ពីត្រូវបានព្យួរអស់មួយរយៈពេលវែង។

៣-ករណីផ្សេងទៀតមានការលំបាកខ្លាំងក្នុងការអនុវត្តដែនកំណត់ថ្លៃប្រចាំថ្ងៃ។

## ប្រការ ១៨.- ការកែតម្រូវលើកំហុសប្រតិបត្តិការជួញដូរ

ក្នុងករណីដែល **ផ.ម.ក.** មានកំហុសឆ្គងក្នុងដំណើរការធ្វើអន្តរការីកម្មនៃការជួញដូរមូលបត្រកម្មសិទ្ធិ ឬក្នុងករណីដែលសមាជិកណាមួយមានកំហុសឆ្គងក្នុងដំណើរការដាក់បញ្ជាដែនកំណត់ ឬបញ្ជាទីផ្សារពាក់ព័ន្ធនឹងមូលបត្រកម្មសិទ្ធិ ព័ត៌មានលម្អិតអំពីការជួញដូរនេះអាចកែតម្រូវបាន។

កំហុសប្រតិបត្តិការត្រូវបានចាត់ថ្នាក់ជា÷ កំហុសរបស់ **ផ.ម.ក.** ឬកំហុសរបស់សមាជិក។

**ផ.ម.ក.** ត្រូវកែតម្រូវលើកំហុសប្រតិបត្តិការតាមវិធីសាស្ត្រដូចខាងក្រោម÷

១-ក្នុងករណីជាកំហុសប្រតិបត្តិការរបស់ **ផ.ម.ក.**÷ ក្នុងករណីនេះ **ផ.ម.ក.** ត្រូវធ្វើការកែតម្រូវដោយយោងតាមព័ត៌មានដើមនៃបញ្ជា ហើយតម្រូវឱ្យសមាជិកដែលបានបញ្ជូនបញ្ជានោះទទួលយកការជួញដូរមូលបត្រដែលពាក់ព័ន្ធសម្រាប់គណនីផ្ទាល់របស់ខ្លួន។ ក្នុងករណីដែលមានការខាតបង់ដែលបណ្តាលមកពីការកែតម្រូវនេះ **ផ.ម.ក.** ត្រូវធ្វើការប៉ះប៉ូវឱ្យសមាជិកនោះវិញ។

២-ក្នុងករណីជាកំហុសប្រតិបត្តិការរបស់សមាជិក÷ កំហុសឆ្គងត្រូវធ្វើការកែតម្រូវ បន្ទាប់ពីសមាជិកនោះទទួលយកការជួញដូរដែលមានកំហុសជាប្រតិបត្តិការផ្ទាល់របស់ខ្លួន។ ក្នុងករណីនេះ សមាជិកដែលពាក់ព័ន្ធត្រូវដាក់ពាក្យស្នើសុំកែតម្រូវលើកំហុសប្រតិបត្តិការ និងភ្ជាប់មកជាមួយនូវសេចក្តីថ្លែងដែល

បញ្ជាក់ពីមូលហេតុ ឬឯកសារភស្តុតាង ផ្ញើជូន **ផ.ម.ក.** ឱ្យបានមុនម៉ោង ៣:៣០នាទី រសៀលនៃថ្ងៃជួញដូរបន្ទាប់។

## ជំពូកទី ៣
## លក្ខខណ្ឌនៃការជួញដូរមូលបត្របំណុល

### ប្រការ ១៩.- វិធីសាស្ត្រកំណត់ថ្លៃជួញដូរមូលបត្របំណុល

ថ្លៃជួញដូរមូលបត្របំណុលត្រូវកំណត់តាមវិធីសាស្ត្រដេញថ្លៃ និងវិធីសាស្ត្រជួញដូរតាមការចរចា ដូចមានចែងក្នុងជំពូកទី១នៃវិធាននេះ លើកលែងតែករណីមានថ្លៃផ្គូផ្គងចាប់ពីពីរឡើងនៅក្នុងការដេញថ្លៃដោយយកថ្លៃតែមួយ ថ្លៃជួញដូរគឺជាមធ្យមនព្វន្តនៃថ្លៃផ្គូផ្គងខ្ពស់បំផុតនិងថ្លៃផ្គូផ្គងទាបបំផុត។ ក្នុងករណីថ្លៃទទួលបានពីការគណនានេះមិនចំនឹងឯកតាគម្លាតថ្លៃ ថ្លៃជួញដូរត្រូវបង្គត់ឡើងតាមឯកតាគម្លាតថ្លៃ។

### ប្រការ ២០.- ឯកតាបញ្ជា បញ្ជាអតិបរមា ឯកតាគម្លាតថ្លៃ និងថ្លៃបញ្ជា

ឯកតាបញ្ជានៃមូលបត្របំណុលគឺ ១ (មួយ) ឯកតាមូលបត្របំណុល។

បញ្ជាអតិបរមាសម្រាប់ការជួញដូរតាមវិធីសាស្ត្រដេញថ្លៃគឺ ១០.០០០ (មួយម៉ឺន) ឯកតាមូលបត្របំណុល។

ឯកតាគម្លាតថ្លៃគឺ ១ (មួយ) រៀល។សម្រាប់ការជួញដូរមូលបត្របំណុល ថ្លៃបញ្ជា និងថ្លៃជួញដូរគឺជាថ្លៃដុល។

### ប្រការ ២១.- ដែនកំណត់ថ្លៃប្រចាំថ្ងៃ

ដែនកំណត់ថ្លៃប្រចាំថ្ងៃមិនត្រូវអនុវត្តចំពោះការជួញដូរមូលបត្របំណុល។

## ជំពូកទី ៤
## ការគ្រប់គ្រងទីផ្សារ

### ប្រការ ២២.- ការផ្សាយជាសាធារណៈនូវព័ត៌មានទីផ្សារ

**ផ.ម.ក.** ធ្វើការផ្សព្វផ្សាយជាសាធារណៈនូវទិន្នន័យទីផ្សារដូចខាងក្រោម÷

១-ថ្លៃបើក និង ថ្លៃបិទ។

២-បរិមាណ និង តម្លៃសរុបនៃការជួញដូរ។

៣-ថ្លៃរំពឹងទុក និង បរិមាណរំពឹងទុក។

**ផ.ម.ក.** អាចធ្វើការផ្សព្វផ្សាយជាសាធារណៈ នូវព័ត៌មានផ្សេងទៀតដែលមានប្រយោជន៍សម្រាប់ការសម្រេចចិត្តវិនិយោគ ដើម្បីការពារផលប្រយោជន៍វិនិយោគិន។

**ប្រការ ២៣.- ព័ត៌មានដែលត្រូវជូនដំណឹងទៅសមាជិក**

**ផ.ម.ក.** ត្រូវជូនដំណឹងទៅសមាជិករបស់ខ្លួននូវព័ត៌មាននីមួយៗដូចខាងក្រោម៖

១-វិធានប្រតិបត្តិការរបស់ **ផ.ម.ក.** និងវិសោធនកម្មដែលអាចកើតមាន។

២-មូលបត្រចុះបញ្ជីលក់ដំបូង មូលបត្រចុះបញ្ជីលក់បន្ថែម មូលបត្រដកចេញពីការចុះបញ្ជីលក់ និងមូលបត្រដែលត្រូវបានព្យួរការជួញដូរ។

៣-ការបិទទីផ្សារជាបណ្តោះអាសន្ន ការផ្អាកដំណើរការទីផ្សារ និងការផ្លាស់ប្តូរម៉ោងជួញដូរ។

៤-សមាជិកដែលត្រូវបានអនុញ្ញាត ឬសមាជិកដែលបានដកខ្លួនពីសមាជិកភាព ឬត្រូវបាន ដកចេញពីសមាជិកភាព។

៥-សមាជិកដែលត្រូវបានព្យួរពីការជួញដូរ និងការអនុញ្ញាតឱ្យជួញដូរឡើងវិញ។

៦-ព័ត៌មានលម្អិតនៃការជួញដូរ រួមមាន ៖ ឈ្មោះមូលបត្រ បរិមាណនិងថ្លៃជួញដូរ ប្រភេទបញ្ជាទិញឬលក់ប្រតិបត្តិការសម្រាប់គណនីសមាជិក ឬគណនីអតិថិជន។

**ផ.ម.ក.** ត្រូវរក្សាទុករាល់ព័ត៌មានទាក់ទងនឹងបញ្ជា ការកែតម្រូវកំហុសប្រតិបត្តិការ និងព័ត៌មានលម្អិតលើការជួញដូរសម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ។

**ប្រការ ២៤.- ប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យារបស់សមាជិក**

សមាជិកទាំងអស់ត្រូវរៀបចំប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យារបស់ខ្លួន ដោយអនុលោមទៅតាមច្បាប់ បទប្បញ្ញត្តិពាក់ព័ន្ធ និងវិធាននេះ។

**ប្រការ ២៥.- កាលបរិច្ឆេទអិចឌីវីដឺនដ៍ ឬអិចរាយថ៍**

កាលបរិច្ឆេទអិចឌីវីដឺនដ៍ (Ex-Dividend) ឬអិចរាយថ៍ (Ex-Right) គឺកាលបរិច្ឆេទជួញដូរនៅរយៈកាល ១ (មួយ) ថ្ងៃ មុនកាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះភាគហ៊ុនិកដែលត្រូវទទួលបានភាគលាភ ឬសិទ្ធិ (Record Date)។

**ប្រការ ២៦.- អ្នកតំណាងនៅក្នុងទីផ្សារ**

សមាជិកនីមួយៗត្រូវតែងតាំងអ្នកតំណាងនៅក្នុងទីផ្សារយ៉ាងហោចណាស់ ១ (មួយ) រូប ដែលនឹងត្រូវបណ្តុះបណ្តាលដោយ **ផ.ម.ក.** ដើម្បីប្រើប្រាស់ប្រព័ន្ធជួញដូររបស់ប្រតិបត្តិករទីផ្សារមូលបត្រនៃ **ផ.ម.ក.** ដែលរៀបចំសម្រាប់សមាជិក។ **ផ.ម.ក.** អាចតម្រូវឱ្យអ្នកតំណាងនោះ មកធ្វើការនៅក្នុងបន្ទប់ជួញដូររបស់ **ផ.ម.ក.** ក្នុងករណីចាំបាច់។

សមាជិកនីមួយៗ ត្រូវដាក់ពាក្យស្នើសុំចុះឈ្មោះអ្នកតំណាងនៅក្នុងទីផ្សាររបស់ខ្លួននៅ **ផ.ម.ក.**។ មានតែអ្នកតំណាងនៅក្នុងទីផ្សារទេ ដែលត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ប្រព័ន្ធកុំព្យូទ័ររបស់សមាជិកដែលស្ថិតនៅក្នុងបន្ទប់ជួញដូររបស់ **ផ.ម.ក.**។

**ប្រការ ២៧.- ថ្លៃសេវាជួញដូរមូលបត្រ**

សមាជិកត្រូវបង់ថ្លៃសេវាប្រតិបត្តិការដែលពាក់ព័ន្ធនឹងសេវាដែលបានផ្តល់ឱ្យស្របតាមវិធាននេះ។

របៀបគណនាប្រាក់ថ្លៃសេវាជួញដូរ អ្នកបង់ប្រាក់ និងពេលវេលាបង់ប្រាក់ត្រូវបានកំណត់ដូចខាងក្រោម÷

១-អត្រា÷ ប្រាក់ថ្លៃសេវាសម្រាប់ជួញដូរមូលបត្រ ត្រូវគណនាលើទឹកប្រាក់នៃការជួញដូរដែលបានទូទាត់ (ប្រាក់ថ្លៃសេវាដែលគណនាត្រូវកាត់យកមួយខ្ទង់ក្រោយក្បៀស) តាមអត្រា ៧,៥/១០.០០០ ឬ ០,០៧៥ % (សូន្យក្បៀសសូន្យចិតសិបប្រាំភាគរយ) សម្រាប់មូលបត្រកម្មសិទ្ធិ និងតាមអត្រា ២,៥/១០.០០០ ឬ ០,០២៥% (សូន្យក្បៀសសូន្យម្ភៃប្រាំភាគរយ) សម្រាប់មូលបត្របំណុល។

២-អ្នកត្រូវបង់ប្រាក់÷ ក្រុមហ៊ុនមូលបត្រដែលជាសមាជិករបស់ **ផ.ម.ក.**។

៣-ពេលវេលាបង់ប្រាក់÷ ម៉ោង ៨:៣០នាទី ព្រឹក នៃកាលបរិច្ឆេទទូទាត់។

## ជំពូកទី ៥

## ការតាមដានការជួញដូរមូលបត្រ

**ប្រការ ២៨.- យន្តការបង្ការរបស់ ផ.ម.ក.**

ដើម្បីធានាបាននូវបរិស្ថានជួញដូរដែលមានយុត្តិធម៌ និងការពារវិនិយោគិន **ផ.ម.ក.** អាចដាក់ចេញនូវយន្តការបង្ការមួយចំនួនដើម្បីទប់ស្កាត់ការជួញដូរមូលបត្រមិនស្មោះត្រង់ ឬមិនប្រក្រតី។

**ប្រការ ២៩.- ការឃ្លាំមើលទីផ្សារ**

**ជ.ម.ក.** ធ្វើការឃ្លាំមើលទីផ្សារ ដើម្បីកំណត់អត្តសញ្ញាណមូលបត្រដែលជាប់សង្ស័យថាមានការជួញដូរមិនប្រក្រតី ដោយប្រើប្រាស់នូវព័ត៌មានមួយចំនួនដូចជា របៀបនៃការជួញដូរ បម្រែបម្រួលថ្លៃ ទំហំនៃការជួញដូរ ព្រមទាំងកម្រិតនៃទំនាក់ទំនងរវាងថ្លៃទីផ្សារនិងការជួញដូរ និងព័ត៌មានលម្អិតនៃពាក្យចចាមអារ៉ាម។

* * *

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មការមូលបត្រកម្ពុជា**
លេខ: ០០៤/១៧ ......គ.ម.ក. /ប្រ.ក.

# ប្រកាស
## ស្តីពី
## ការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការផាត់ទាត់និងទូទាត់មូលបត្រ

*****

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុថ្ងៃះទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញប្រកាសលេខ ០១១ គ.ម.ក.ប្រក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការផ្តល់ការអនុញ្ញាតធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ
- បានឃើញប្រកាសលេខ ០០៤ គ.ម.ក.ប្រ.ក. ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០ ស្តីពីខ្លឹមសារគោលនៃវិធានប្រតិបត្តិការរបស់ទីផ្សារមូលបត្រ ប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ និងសេវារក្សាទុកមូលបត្រ


អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: #99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia
ទូរសព្ទ : ៨៥៥-២៣-៨៨៥-៦១១ Phone : 855-23-885-611
E-mail : info@secc.gov.kh
ទូរសារ : ៨៥៥-២៣-៨៨៥-៦២២ Fax : 855-23-885-622
Website : www.secc.gov.kh

- បានឃើញប្រកាសលេខ ០០៥/១១ គ.ម.ក.ប្រក. ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការជាត់ទាត់និងទូទាត់មូលបត្រ
- យោងសំណើសុំវិសោធនកម្មប្រកាសលេខ ០០៥/១១ គ.ម.ក.ប្រ.ក. ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការជាត់ទាត់និងទូទាត់មូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៧
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជានាថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៧។

## សម្រេច

**ប្រការ ១.-**

ដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការជាត់ទាត់និងទូទាត់មូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ២.-**

ប្រកាសលេខ ០០៥/១១ គ.ម.ក.ប្រ.ក. ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការជាត់ទាត់និងទូទាត់មូលបត្រ និងប្រការ ២ នៃប្រកាសលេខ ០០៣/១៧ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តនូវការកែប្រែវិធានប្រតិបត្តិការរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ត្រូវទុកជានិរាករណ៍។

**ប្រការ ៣.-**

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា ប្រធាននាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត ប្រធាននាយកដ្ឋាន-អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា សមាជិក និងអ្នកចូលរួមក្នុងទីផ្សារមូលបត្រ ព្រមទាំងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ.......................ខែ............ ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦..... ខែ.......... ឆ្នាំ..........

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**និងជាប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា**

**បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
 "ដើម្បីជូនជ្រាប"
- ដូចប្រការ ៣
 "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ឧបសម្ព័ន្ធប្រកាសលេខ...០១៥/១៣.........**
**ចុះថ្ងៃទី...២៦... ខែ...ធ្នូ... ឆ្នាំ...២០១៣**

# ស្តីពី
# វិធានប្រតិបត្តិការផាត់ទាត់និងទូទាត់មូលបត្រ
# របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

* * * * *

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

### ប្រការ ១.-គោលបំណង

គោលបំណងនៃវិធានប្រតិបត្តិការផាត់ទាត់និងទូទាត់មូលបត្រនេះ គឺដើម្បីកំណត់នូវគោលការណ៍នានាដែលចាំបាច់សម្រាប់ការផាត់ទាត់និងទូទាត់មូលបត្រ នៅក្នុងប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (សរសេរកាត់ថា **ផ.ម.ក.**) ស្របតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

### ប្រការ ២.-និយមន័យ

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់នៅក្នុងវិធាននេះ ត្រូវបានកំណត់នៅក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ច្បាប់ស្តីពីមូលបត្ររដ្ឋ និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

-**សមាជិក** សំដៅដល់ក្រុមហ៊ុនមូលបត្រដែលទទួលបានអាជ្ញាបណ្ណពីគណៈកម្មការមូលបត្រកម្ពុជា (សរសេរកាត់ថា **គ.ម.ក.**) ដោយមានសិទ្ធិប្រើប្រាស់ទាំងស្រុងនូវប្រព័ន្ធរបស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ **ផ.ម.ក.**។

-**អ្នកចូលរួម** សំដៅដល់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ បុគ្គលបោះផ្សាយលក់មូលបត្រ បុគ្គលចុះបញ្ជីលក់មូលបត្រជាដើម ដែលមានសិទ្ធិប្រើប្រាស់តែមួយផ្នែកនូវប្រព័ន្ធរបស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ **ផ.ម.ក.**។

-**ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ** សំដៅដល់ធនាគារពាណិជ្ជដែលបានការទទួលស្គាល់ពី **គ.ម.ក.** ដូចមានចែងក្នុងប្រកាសស្តីពីការទទួលស្គាល់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ។

**ប្រការ៣.-ប្រតិបត្តិការផាត់ទាត់និងទូទាត់**

ការជួញដូរមូលបត្រចុះបញ្ជី ត្រូវតែប្រតិបត្តិតាមការទូទាត់ធម្មតា។ ការទូទាត់ធម្មតា គឺជាការទូទាត់ដែលត្រូវធ្វើឡើងពីរថ្ងៃបន្ទាប់ពីថ្ងៃជួញដូរ (T+2)។

## ជំពូកទី២

## ការទូទាត់រវាងប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ និងសមាជិក ឬអ្នកចូលរួម

**ប្រការ ៤.-កាតព្វកិច្ចទូទាត់របស់សមាជិក ឬអ្នកចូលរួម**

សមាជិក ឬអ្នកចូលរួមនៃប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ **ផ.ម.ក.** ត្រូវធ្វើការទូទាត់លើប្រតិបត្តិការដែលបានជួញដូរឱ្យបាននៅកាលបរិច្ឆេទទូទាត់។

សមាជិក ឬអ្នកចូលរួមនៃប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ **ផ.ម.ក.** មិនអាចប្រគល់ភារកិច្ចទូទាត់ប្រតិបត្តិការរបស់ខ្លួនទៅឱ្យសមាជិក ឬអ្នកចូលរួមដទៃទៀតឡើយ។

**ប្រការ ៥.-កាលបរិច្ឆេទផាត់ទាត់និងទូទាត់រវាងសមាជិក ឬអ្នកចូលរួម**

លើកលែងតែមានការកំណត់ផ្សេងពីនេះដោយ **គ.ម.ក.** ការទូទាត់ត្រូវធ្វើឡើងពីរថ្ងៃនៃថ្ងៃជួញដូរបន្ទាប់ពីថ្ងៃដែលមូលបត្រនោះត្រូវបានជួញដូរ (T+2)។ ថ្ងៃបិទទីផ្សារមិនត្រូវបានរាប់បញ្ចូលក្នុងចំនួនថ្ងៃអាជីវកម្មទេ។

**ប្រការ ៦.-ការជ្រើសរើសភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ**

សមាជិក ឬអ្នកចូលរួមត្រូវជ្រើសរើសភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.** សម្រាប់បំពេញកាតព្វកិច្ចទូទាត់សាច់ប្រាក់។

**ប្រការ ៧.-ការបើកគណនីទូទាត់សម្រាប់ការទូទាត់សាច់ប្រាក់**

សមាជិក ឬអ្នកចូលរួមនៃប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ **ផ.ម.ក.** ត្រូវបើកគណនីសាច់ប្រាក់ក្នុងនាមខ្លួនផ្ទាល់ នៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ដូចមានចែងក្នុងប្រការ ៦ នៃវិធាននេះ ដើម្បីបំពេញកាតព្វកិច្ចទូទាត់សាច់ប្រាក់។

បន្ទាប់ពីបានបើកគណនីសាច់ប្រាក់ ឬមានការផ្លាស់ប្តូរគណនីសាច់ប្រាក់ សមាជិក ឬអ្នកចូលរួមត្រូវរាយការណ៍អំពីឈ្មោះនៃភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្ររបស់ខ្លួន និងលេខគណនី ជូនដល់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ **ផ.ម.ក.** យ៉ាងហោចណាស់ ៥ (ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការមុនថ្ងៃចាប់ផ្តើមការជួញដូរ។

ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ **ផ.ម.ក.** ត្រូវបើកគណនីទូទាត់សាច់ប្រាក់នៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ដើម្បីបំពេញកាតព្វកិច្ចទូទាត់សាច់ប្រាក់។

ការទូទាត់សាច់ប្រាក់ត្រូវបានធ្វើឡើង តាមរយៈការផ្ទេរសាច់ប្រាក់ពីគណនីសាច់ប្រាក់របស់សមាជិក ឬអ្នកចូលរួម ទៅគណនីទូទាត់សាច់ប្រាក់របស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ **ផ.ម.ក.**។ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ **ផ.ម.ក.** ត្រូវផ្ទេរសាច់ប្រាក់ដែលទទួលបាននេះ ទៅសមាជិក ឬអ្នកចូលរួមដែលត្រូវទទួលបានការទូទាត់សាច់ប្រាក់។

## ប្រការ ៨.-ការបើកគណនីមូលបត្រសម្រាប់ការទូទាត់មូលបត្រ

សមាជិក ឬអ្នកចូលរួមត្រូវបើកគណនីមូលបត្រ ស្របតាមវិធានប្រតិបត្តិការរក្សាទុកមូលបត្រ នៃប្រតិបត្តិកររក្សាទុកមូលបត្រ ដើម្បីបំពេញកាតព្វកិច្ចទូទាត់មូលបត្រ។

ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ **ផ.ម.ក.** ត្រូវបើកគណនីទូទាត់មូលបត្រនៅប្រតិបត្តិកររក្សាទុកមូលបត្រ ដើម្បីបំពេញកាតព្វកិច្ចទូទាត់មូលបត្រ។

ការទូទាត់មូលបត្រត្រូវធ្វើឡើង តាមរយៈការផ្ទេរក្នុងបញ្ជី (Book-EntryTransfer) ពីគណនីមូលបត្ររបស់សមាជិក ឬអ្នកចូលរួម ទៅគណនីទូទាត់មូលបត្ររបស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ **ផ.ម.ក.**។ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ **ផ.ម.ក.** ត្រូវផ្ទេរមូលបត្រដែលទទួលបាននេះ ទៅសមាជិក ឬអ្នកចូលរួម ដែលត្រូវទទួលបានការទូទាត់មូលបត្រ។

## ប្រការ ៩.-ការតម្កល់ធានាការជួញដូរ

មុនអនុវត្តបញ្ជាសម្រាប់គណនីអតិថិជន ឬសម្រាប់គណនីផ្ទាល់ខ្លួន សមាជិកត្រូវពិនិត្យការតម្កល់ធានាការជួញដូរមូលបត្រឱ្យបានត្រឹមត្រូវ ដូចតទៅ÷

១- សម្រាប់បញ្ជាទិញមូលបត្រ ត្រូវមានការតម្កល់ធានាការជួញដូរយ៉ាងតិច ១០០% (មួយរយភាគរយ) ជាសាច់ប្រាក់។ ចំពោះបញ្ជាទិញមូលបត្រកម្មសិទ្ធិ សាច់ប្រាក់តម្កល់ធានាការជួញដូរនេះ អាចគិតបញ្ចូលផងដែរនូវសាច់ប្រាក់ត្រូវទទួលបានពីបញ្ជាលក់ដែលបានផ្គូផ្គងដោយជោគជ័យ។

២- សម្រាប់បញ្ជាលក់មូលបត្រ ត្រូវមានការតម្កល់ធានាការជួញដូរយ៉ាងតិច ១០០% (មួយរយភាគរយ) ជាមូលបត្រដែលត្រូវដាក់លក់នោះ។ ចំពោះបញ្ជាលក់មូលបត្រកម្មសិទ្ធិ មូលបត្រតម្កល់ធានាការជួញដូរអាចគិតបញ្ចូលផងដែរនូវមូលបត្រដូចគ្នាត្រូវទទួលបានពីបញ្ជាទិញដែលបានផ្គូផ្គងដោយជោគជ័យ។

សមាជិកត្រូវធានាឱ្យបានថា ការតម្កល់ធានាការជួញដូរត្រូវបានរក្សាទុក ឬបង្កកសម្រាប់ការទូទាត់ ឬរហូតដល់បញ្ជានោះអស់សុពលភាព។

**ប្រការ ១០.-នីតិវិធីនៃប្រតិបត្តិការផាត់ទាត់និងទូទាត់**

ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ **ផ.ម.ក.** ត្រូវគណនាចំនួនមូលបត្រ និងសាច់ប្រាក់ដែលត្រូវទូទាត់ចុងក្រោយដោយសមាជិក ឬអ្នកចូលរួម ដោយធ្វើការបន្សុទ្ធ ឬកាត់កង (Netting) ចំនួនមូលបត្រ និងសាច់ប្រាក់ដែលត្រូវទូទាត់ក្នុងថ្ងៃដូចគ្នា របស់សមាជិក ឬអ្នកចូលរួម នីមួយៗ។

ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ **ផ.ម.ក.** ត្រូវជូនដំណឹងអំពីព័ត៌មានដូចខាងក្រោមដល់សមាជិក ឬអ្នកចូលរួម នៅកាលបរិច្ឆេទផាត់ទាត់ និងកាលបរិច្ឆេទទូទាត់÷

១- កាលបរិច្ឆេទផាត់ទាត់ និងកាលបរិច្ឆេទទូទាត់។

២- បរិមាណនៃមូលបត្រនីមួយៗ ដែលត្រូវទូទាត់ដោយសមាជិកផ្ទាល់ ឬអ្នកចូលរួម ឬក្នុងនាមអតិថិជន។

៣- ទឹកប្រាក់ដែលត្រូវទូទាត់ដោយសមាជិក ឬអ្នកចូលរួមផ្ទាល់ ឬក្នុងនាមអតិថិជន។

បរិមាណមូលបត្រ និងចំនួនសាច់ប្រាក់ដែលនឹងត្រូវទូទាត់ ត្រូវគណនាស្របតាមវិធីសាស្ត្រនីមួយៗ ដូចខាងក្រោម÷

១- ចំពោះមូលបត្រ÷ ត្រូវបានគណនាដោយធ្វើការផាត់ទាត់បរិមាណលក់សរុប និងបរិមាណទិញសរុបនៃមូលបត្រនីមួយៗ សម្រាប់សមាជិក ឬអ្នកចូលរួម ដែលពាក់ព័ន្ធ។

២- ចំពោះសាច់ប្រាក់÷ ត្រូវបានគណនាដោយធ្វើការផាត់ទាត់តម្លៃទិញសរុប និងតម្លៃលក់សរុប សម្រាប់សមាជិក ឬអ្នកចូលរួម នីមួយៗដែលពាក់ព័ន្ធ។

សមាជិក ឬអ្នកចូលរួម ត្រូវផ្ទេរមូលបត្រ និងសាច់ប្រាក់ដែលត្រូវទូទាត់ ទៅគណនីរបស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ **ផ.ម.ក.** នៅមុនម៉ោង ៨:៣០ ព្រឹក នៅកាលបរិច្ឆេទទូទាត់ (Settlement Date) ហើយប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ **ផ.ម.ក.** ត្រូវធ្វើការទូទាត់មូលបត្រនិងសាច់ប្រាក់បន្តទៅឱ្យសមាជិក ឬអ្នកចូលរួម ដែលត្រូវទទួលការទូទាត់ បន្ទាប់ពីម៉ោង ៨:៣០ ព្រឹក នៅថ្ងៃដដែលនៅកាលបរិច្ឆេទទូទាត់។

**ប្រការ ១១.-ការប្រគល់ឯកសារទូទាត់**

ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ **ផ.ម.ក.** ត្រូវផ្តល់នូវឯកសារបង្គាប់ទូទាត់ ដែលរួមមានព័ត៌មានលម្អិតលើមូលបត្រ និងសាច់ប្រាក់ដែលត្រូវទូទាត់ជូនដល់សមាជិក ឬអ្នកចូលរួម ក្រោយការបិទទីផ្សារ តាមរយៈប្រព័ន្ធកុំព្យូទ័រ។

សមាជិក ឬអ្នកចូលរួម ត្រូវពិនិត្យអំពីមូលបត្រ និងសាច់ប្រាក់ដែលត្រូវទូទាត់ នៅលើឯកសារបង្គាប់ទូទាត់ និងត្រូវធ្វើការទូទាត់ទៅតាមពេលវេលាកំណត់។

សមាជិក ឬអ្នកចូលរួម ត្រូវប្រគល់ឯកសារទូទាត់ ដែលមានព័ត៌មានលម្អិត និងពេលវេលានៃការទូទាត់ជាដើម ជូនដល់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ ផ.ម.ក. ក្រោយពីការទូទាត់។

**ប្រការ ១២.-វិធានការវិន័យចំពោះការបរាជ័យនៃការទូទាត់**

ក្នុងករណីដែលសមាជិក ឬអ្នកចូលរួមណាមួយគ្មានលទ្ធភាពធ្វើការទូទាត់ការជួញដូររបស់ខ្លួន ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ ផ.ម.ក. អាចលុបចោលនូវការជួញដូរដែលបានប្រតិបត្តិហើយទាំងស្រុង ឬមួយផ្នែកនៅក្នុងប្រតិបត្តិករទីផ្សារនៃ ផ.ម.ក. ឬ/និងព្យួរការជួញដូររបស់សមាជិក ឬអ្នកចូលរួមនោះក្នុងរយៈពេលកំណត់មួយ។

ក្នុងករណីដែលមានកង្វះខាតសាច់ប្រាក់ក្នុងការទូទាត់ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ ផ.ម.ក. អាចប្រើប្រាស់មធ្យោបាយផ្សេងៗ ដើម្បីធានាការទូទាត់ លើកលែងតែមានការកំណត់ផ្សេងទៀត។

ក្នុងករណីដែលមានកង្វះខាតមូលបត្រសម្រាប់ទូទាត់ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ ផ.ម.ក. ត្រូវធ្វើការទូទាត់ ដោយសុំខ្ចីនូវមូលបត្រប្រភេទដូចគ្នាពីសមាជិក ឬអ្នកចូលរួមផ្សេងទៀត។ ប្រសិនបើការសុំខ្ចី និងការឱ្យខ្ចីមិនអាចធ្វើទៅបាន ការទូទាត់នឹងត្រូវលុបចោល។

ប្រសិនបើ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ ផ.ម.ក. មិនអាចរកមធ្យោបាយដើម្បីធ្វើការទូទាត់ ដូចមានចែងក្នុងកថាខណ្ឌទី ២ និងទី ៣ ខាងលើ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ ផ.ម.ក. អាចចាត់វិធានការ ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃប្រការនេះ។

**ប្រការ ១៣.- អ្នកតំណាងទូទាត់**

សមាជិក ឬអ្នកចូលរួមនីមួយៗ ត្រូវតែងតាំង និងចុះឈ្មោះអ្នកតំណាងទូទាត់យ៉ាងហោចណាស់ ១ (មួយ) រូប ដែលត្រូវទទួលការបណ្តុះបណ្តាលពីប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ ផ.ម.ក. និងដែលមានសិទ្ធិធ្វើប្រតិបត្តិការទូទាត់ឱ្យសមាជិក ឬអ្នកចូលរួមនោះ ជាមួយប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ ផ.ម.ក.។

អ្នកតំណាងទូទាត់របស់សមាជិកនោះ អាចជាអ្នកតំណាងទីផ្សារដែលត្រូវបានតែងតាំងដោយសមាជិកស្របតាមវិធានប្រតិបត្តិការទីផ្សារមូលបត្ររបស់ ផ.ម.ក.។

## ជំពូកទី ៣
## ថ្លៃសេវាផាត់ទាត់និងទូទាត់

**ប្រការ ១៤.-ថ្លៃសេវាផាត់ទាត់និងទូទាត់មូលបត្រ**

សមាជិក ឬអ្នកចូលរួមត្រូវបង់ថ្លៃសេវាផាត់ទាត់និងទូទាត់ ជូនប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ ផ.ម.ក. តាមអត្រា និងពេលវេលាដូចខាងក្រោម÷

១-ថ្លៃសេវាសម្រាប់សេវាផាត់ទាត់និងទូទាត់មូលបត្រ ត្រូវយកលើតម្លៃជួញដូរដែលត្រូវបានទូទាត់ (ប្រាក់សេវាត្រូវកាត់កៀសមកត្រឹមមួយខ្ទង់) តាមអត្រា ២,៥/១០.០០០ (ពីរកៀសប្រាំភាគមួយម៉ឺន) ឬ០,០២៥% (សូន្យកៀសសូន្យម្ភៃប្រាំភាគរយ) ចំពោះមូលបត្រកម្មសិទ្ធិ និង ១,២៥/១០.០០០ (មួយកៀសម្ភៃប្រាំភាគមួយម៉ឺន) ឬ ០,០១២៥% (សូន្យកៀសសូន្យមួយរយម្ភៃប្រាំភាគរយ) ចំពោះមូលបត្របំណុល។

២-អ្នកបង់ថ្លៃសេវា គឺសមាជិក ឬអ្នកចូលរួមនៃប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ **ផ.ម.ក.**។

៣-ពេលវេលានៃការបង់ថ្លៃសេវា គឺនៅម៉ោង ៨:៣០ ព្រឹក នៃកាលបរិច្ឆេទទូទាត់។

* * *